សេវាអប់រំពិសេស

… សេវា.. មិនមែនទីកន្លែង

# សេចក្តីជូនដំណឹងស្តីពីកិច្ចការពារតាមនីតិវិធីនៃការអប់រំពិសេសសម្រាប់សិស្ស និងក្រុមគ្រួសាររបស់ពួកគេ

លក្ខខណ្ឌតម្រូវក្រោម Part B នៃច្បាប់ស្តីពីការអប់រំបុគ្គលមានពិការភាព បទប្បញ្ញត្តិសហព័ន្ធ និងច្បាប់រដ្ឋដែលគ្រប់គ្រងការអប់រំពិសេស

SUPERINTENDENT OF PUBLIC INSTRUCTION WASHINGTON

***Randy I. Dorn***
State Superintendent
of Public Instruction

**បានកែសម្រួលនៅខែតុលា ឆ្នាំ 2013**

# សេចក្តីជូនដំណឹងស្តីពីកិច្ចការពារតាមនីតិវិធី
# នៃការអប់រំពិសេស
# សម្រាប់សិស្ស និងក្រុមគ្រួសាររបស់ពួកគេ

**ការអប់រំពិសេស**
**ការិយាល័យគ្រប់គ្រងសេចក្តីណែនាំសាធារណៈ**
**(Office of Superintendent of Public Instruction)**
**បណ្ឌិត Douglas H. Gill**
**នាយកផ្នែកអប់រំពិសេស**

---

Randy I. Dorn
អ្នកគ្រប់គ្រងការណែនាំសាធារណៈ

Ken Kanikeberg
ប្រធានបុគ្គល

Gil Mendoza
ជំនួយការអ្នកគ្រប់គ្រង
កម្មវិធីពិសេស និងគណនេយ្យភាពសហព័ន្ធ

---

**បានកែសម្រួលនៅខែតុលា ឆ្នាំ2013**

ការិយាល័យគ្រប់គ្រងសេចក្តីណែនាំសាធារណៈ
(Office of Superintendent of Public Instruction)
Old Capitol Building
P.O. Box47200
Olympia, WA 98504-7200

សម្រាប់ព័ត៌មានបន្ថែមអំពី

ឯកសារនេះ សូមទំនាក់ទំនងផ្នែកអប់រំពិសេសនៃ OSPI

អ៊ីម៉ែល: speced@k12.wa.us

ទូរស័ព្ទ: (360) 725-6075

ឯកសារនេះ អាចរកបាននៅលើគេហទំព័រ៖

http://www.k12.wa.us/SpecialEd/Families/Rights.aspx

ឯកសារនេះ អាចរកបាននៅក្នុងទម្រង់ផ្សេងទៀត តាមការស្នើសុំដោយទំនាក់ទំនង៖

The Washington School for the Blind, Braille Access Center
http://www.wssb.wa.gov/Content/offcampus/bac.asp
(360)696-6321 x158

OSPI ផ្តល់ភាពស្មើគ្នាចំពោះកម្មវិធី និងសេវាទាំងឡាយ ដោយគ្មានការរើសអើងភេទ ជាតិសាសន៍ លទ្ធជំនឿសាសនា ពណ៌សម្បុរ ជាតិកំណើត អាយុ អតីតយុទ្ធជនដែលចាកចេញពីជីវិតកងទ័ព ឬស្ថានភាពជាយោធា ទំនោរផ្លូវភេទរួមទាំងការបង្ហាញ ឬអត្តសញ្ញាណយេនឌ័រ ពិការភាពសរសៃប្រសាទវិញ្ញាណ ផ្លូវចិត្ត ឬរាងកាយណាមួយ ឬការប្រើប្រាស់មគ្គុទេសន៍សុនខដែលទទួលបានការបណ្តុះបណ្តាល ឬសេវាសត្វសម្រាប់ជួយដល់ជនពិការភាព។ សំណួរ និងត្អូញត្អែរពីការរើសអើងគួរតែបញ្ជូនទៅកាន់នាយកផ្នែកសមធម៌ និងសិទ្ធិជនស៊ីវិល តាមលេខទូរស័ព្ទលេខ (360) 725-6162 ឬប្រអប់សំបុត្រលេខ 47200 Olympia WA 98504-7200។

**ព័ត៌មានទូទៅ** 1
សេចក្តីផ្តើម 1
តើសេចក្តីប្រកាសនេះធ្វើឡើងសម្រាប់អ្នកណា 1
សម្រាប់ព័ត៌មានបន្ថែម 1
**សេចក្តីជូនដំណឹងស្តីពីកិច្ចការពារតាមនីតិវិធី** 2
**សេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុន** 2
**ភាសាកំណើត** 4
**សារអេឡិចត្រូនិក** 4
**ការយល់ព្រមរបស់មាតាបិតា - និយមន័យ** 5
**ការយល់ព្រមរបស់មាតាបិតា - លក្ខខណ្ឌតម្រូវ** 5
ការយល់ព្រមសម្រាប់ការវាយតម្លៃបឋម 5
ច្បាប់ពិសេសសម្រាប់ការវាយតម្លៃបឋមលើអ្នកស្ថិតក្រោមអាណាព្យាបាលរបស់រដ្ឋ 6
ការយល់ព្រមរបស់មាតាបិតាសម្រាប់សេវាបឋម និងការលុបចោលការយល់ព្រមបន្តសេវា 7
ការយល់ព្រមរបស់មាតាបិតាសម្រាប់ការវាយតម្លៃឡើងវិញ 8
ការកត់ត្រាទុកជាឯកសារនូវកិច្ចខិតខំប្រឹងប្រែងសមស្របក្នុងការទទួលបានការយល់ព្រមពីមាតាបិតា 9
ព័ត៌មានផ្សេងទៀតទាក់ទងនឹងការយល់ព្រម 9
**ការវាយតម្លៃការអប់រំដោយឯករាជ្យ** 10
និយមន័យ 10
សិទ្ធិរបស់មាតាបិតាក្នុងការទទួលបាន IEE ដោយចំណាយសាធារណៈ 10
ការវាយតម្លៃផ្តួចផ្តើមដោយមាតាបិតា 11

សំណើសុំការវាយតម្លៃដោយមន្ត្រីរដ្ឋបាលសវនាការ (ALJ) .......... 11
លក្ខណៈវិនិច្ឆ័យរបស់ស្រុករដ្ឋបាលសាលា .......... 12
**ការរក្សាការសម្ងាត់នៃព័ត៌មាន .......... 12**
និយមន័យ .......... 12
**ព័ត៌មានដែលអាចសម្គាល់អត្តសញ្ញាណបុគ្គល .......... 13**
**សេចក្តីជូនដំណឹងចំពោះមាតាបិតា .......... 13**
**សិទ្ធិក្នុងការប្រើប្រាស់ .......... 14**
កំណត់ត្រានៃការប្រើប្រាស់ .......... 15
ឯកសារអំពីកុមារលើសពីម្នាក់ .......... 15
បញ្ជីរាយប្រភេទ និងទីតាំងព័ត៌មាន .......... 15
ការបង់ថ្លៃ .......... 15
**ការកែប្រែឯកសារតាមសំណើរបស់មាតាបិតា .......... 15**
ឱកាសសម្រាប់សវនាការ នីតិវិធីសវនាការ និងលទ្ធផលនៃសវនាការ .......... 16
**ការយល់ព្រមឲ្យបញ្ចេញព័ត៌មានដែលអាចសម្គាល់អត្តសញ្ញាណបុគ្គល .......... 17**
**កិច្ចការពារព័ត៌មានអត្តសញ្ញាណផ្ទាល់ខ្លួន .......... 17**
**ការបំផ្លាញ ការឃាត់ទុក និងការរក្សាទុកព័ត៌មាន .......... 18**
**នីតិវិធីដោះស្រាយវិវាទការអប់រំពិសេស .......... 18**
**ការសម្រុះសម្រួល .......... 18**
ទូទៅ .......... 18
ភាពមិនលំអៀងនៃអ្នកសម្របសម្រួល .......... 19
កិច្ចព្រមព្រៀងធ្វើឡើងក្នុងដំណើរការសម្រុះសម្រួល .......... 20

**ភាពខុសគ្នារវាងការស៊ើបអង្កេត និងសវនការនីតិវិធីត្រឹមត្រូវតាមច្បាប់ស្ដីពីបណ្ដឹងការអប់រំពិសេសរបស់ពលរដ្ឋ ..... 20**

**នីតិវិធីសម្រាប់បណ្ដឹងពលរដ្ឋ ..... 21**

ការដាក់ពាក្យបណ្ដឹង ..... 21

ការស៊ើបអង្កេតពីបណ្ដឹង ..... 22

ការស៊ើបអង្កេត ការពន្យារពេល សេចក្ដីសម្រេចជាលាយលក្ខណ៍អក្សរ ..... 22

ឧបាស្រ័យបណ្ដឹង ..... 23

បណ្ដឹងអប់រំពិសេសរបស់ពលរដ្ឋ និងសវនការនីតិវិធីត្រឹមត្រូវតាមច្បាប់ ..... 23

**នីតិវិធីនៃសវនាការត្រឹមត្រូវតាមផ្លូវច្បាប់ ..... 23**

ទូទៅ ..... 24

ការដាក់សំណើសុំ ..... 24

សេចក្ដីជូនដំណឹងដែលចាំបាច់មុនសវនាការលើសំណើសុំសវនាការត្រឹមត្រូវតាមផ្លូវច្បាប់ ..... 25

ភាពគ្រប់គ្រាន់នៃសំណើសុំសវនាការ ..... 25

ការកែប្រែសំណើសុំសវនាការ ..... 25

ការឆ្លើយតបរបស់ស្រុករដ្ឋបាលសាលាចំពោះសំណើសុំសវនាការត្រឹមត្រូវតាមផ្លូវច្បាប់ ..... 26

ការឆ្លើយតបរបស់ភាគីម្ខាងទៀតចំពោះសំណើសុំសវនាការត្រឹមត្រូវតាមផ្លូវច្បាប់ ..... 26

**ពាក្យសុំគំរូ ..... 27**

**ការកំណត់សិទ្ធិទទួលសេវាអប់រំរបស់សិស្សក្នុងពេលរង់ចាំសវនាការត្រឹមត្រូវតាមផ្លូវច្បាប់ ..... 27**

**ដំណើរការដោះស្រាយ ..... 29**

ការប្រជុំស្វែងរកដំណោះស្រាយ ..... 29

រយៈពេលរកដោះស្រាយ ..... 29

ការកែសម្រួលចំពោះរយៈពេលរកដំណោះស្រាយ 30ថ្ងៃប្រតិទិន ..... 31

កិច្ចព្រមព្រៀងនៃដំណោះស្រាយជាលាយលក្ខណ៍អក្សរ ....................................................32
រយៈពេលត្រួតពិនិត្យកិច្ចព្រមព្រៀង....................................................32
**សវនាការត្រឹមត្រូវតាមផ្លូវច្បាប់ឥតលំអៀង....................................................32**
ទូទៅ....................................................32
មន្ត្រីរដ្ឋបាលសវនាការ (ALJ)....................................................32
កម្មវត្ថុនៃសវនាការត្រឹមត្រូវតាមផ្លូវច្បាប់ ....................................................33
ពេលកំណត់សម្រាប់ការស្នើសុំសវនាការ....................................................33
ករណីលើកលែងសម្រាប់ពេលកំណត់....................................................33
**សិទ្ធិសវនាការនានា....................................................34**
ទូទៅ....................................................34
ការបង្ហាញព័ត៌មានបន្ថែម....................................................34
សិទ្ធិរបស់មាតាបិតានៅក្នុងសវនាការ ....................................................35
**ពេលកំណត់ និងភាពសមរម្យនៃសវនាការ ....................................................35**
**សេចក្តីសម្រេចនៃសវនាការ....................................................35**
សេចក្តីសម្រេចរបស់មន្ត្រីរដ្ឋបាលសវនាការ (ALJ) ....................................................35
ខតាមការសន្មត់នៃច្បាប់....................................................36
សំណើដោយឡែកសុំធ្វើសវនាការលើកិច្ចដំណើរការត្រឹមត្រូវតាមច្បាប់....................................................36
លទ្ធផល និងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាយោបល់ និងសាធារណៈជនទូទៅ....................................................36
**សេចក្តីសម្រេចស្ថាពរ, បណ្តឹងឧទ្ធរណ៍....................................................36**
**បណ្តឹងរដ្ឋប្បវេណី រួមទាំងរយៈពេលនៃការដាក់បណ្តឹងទាំងនោះ ....................................................37**
ទូទៅ....................................................37
អាជ្ញាយុកាល ....................................................37

នីតិវិធីបន្ថែម ....... 38
វិធាននៃការបកស្រាយ ....... 38
**ប្រាក់ថ្លៃឈ្នួលមេធាវី ....... 38**
ទូទៅ ....... 38
ការសម្រេចអំពីប្រាក់ថ្លៃឈ្នួលមេធាវី ....... 39
**នីតិវិធីដាក់វិន័យសម្រាប់សិស្សដែលមានសិទ្ធិទទួលបានការអប់រំពិសេស ....... 41**
**សិទ្ធិអំណាចរបស់បុគ្គលិកសាលា ....... 41**
ការកំណត់ករណីនីមួយៗដាច់ដោយឡែក ....... 41
ទូទៅ ....... 41
អំណាចបន្ថែម ....... 42
សេវាកម្មនានា ....... 42
**ការផ្លាស់ប្តូរការកំណត់សិទ្ធិទទួលសេវាអប់រំដោយសារចំណាត់ការវិន័យ ....... 43**
ការជូនដំណឹង ....... 44
ការកំណត់ពីអាការៈនៃពិការភាព ....... 44
ការកំណត់ឥរិយាបទដែលជាសញ្ញាណបណ្តាលមកពីពិការភាពរបស់សិស្ស ....... 45
ស្ថានភាពពិសេស ....... 45
និយមន័យ ....... 46
**ការកំណត់បរិយាកាស ....... 46**
**នីតិវិធីសវនាការលើកិច្ចដំណើរការត្រឹមត្រូវតាមច្បាប់សម្រាប់វិន័យ ....... 51**
សិទ្ធិអំណាចរបស់មន្ត្រីរដ្ឋបាលសវនាការ (ALJ) ....... 47
**កន្លែងអប់រំកូនអ្នកក្នុងពេលធ្វើសវនការនីតិវិធីត្រឹមត្រូវតាមច្បាប់នាប់របស់ ....... 49**

**កិច្ចការពារសម្រាប់សិស្សដែលមិនគ្រប់លក្ខណៈសម្បត្តិទទួលការអប់រំពិសេស និងសេវាពាក់ព័ន្ធផ្សេងៗ ........ 49**
ទូទៅ ........ 49
មូលដ្ឋាននៃការដឹងឮសម្រាប់បញ្ហាវិន័យ ........ 49
ករណីលើកលែង ........ 50
លក្ខខណ្ឌត្រូវអនុវត្តក្នុងករណីគ្មានមូលដ្ឋាននៃការដឹងឮ ........ 50
**ការបញ្ជូនបន្ត និងវិធានការរបស់អាជ្ញាធរអនុវត្តច្បាប់ និងអាជ្ញាធរយុត្តិធម៌ ........ 51**
ការបញ្ជូនកំណត់ត្រា ........ 51
**លក្ខខណ្ឌតម្រូវនៃការស្វែងរកទីកន្លែងសិក្សាដោយឪពុកម្តាយរបស់សិស្ស ក្នុងសាលាឯកជនដោយការចំណាយសាធារណៈ ........ 51**
ការសងប្រាក់សម្រាប់ការចុះឈ្មោះចូលរៀននៅសាលាឯកជន ........ 52
កម្រិតនៃការសងប្រាក់ ........ 52
**ប្រភពជំនួយ ........ 54**

# ព័ត៌មានទូទៅ

## សេចក្តីផ្តើម

ច្បាប់ស្តីពីការអប់រំបុគ្គលមានពិការភាព(IDEA) ឆ្នាំ2004 ដែលទាក់ទងនឹងការអប់រំសិស្សមានពិការភាព តម្រូវឲ្យសាលាផ្តល់ការជូនដំណឹងដល់អ្នក មាតាបិតាសិស្សពិការ ឬសង្ឃ័យមានពិការភាព ដោយមានការពន្យល់ពេញលេញអំពីសិទ្ធិ ដែលមានសម្រាប់អ្នកក្រោម IDEA និងបទប្បញ្ញត្តិស្តីពីការអប់រំរបស់នាយកដ្ឋានសហរដ្ឋអាមេរិក។ ការិយាល័យគ្រប់គ្រងសេចក្តីណែនាំសាធារណៈ (OSPI) មានវិធានរដ្ឋ ដែលគ្រប់គ្រងលើការផ្តល់ការអប់រំពិសេស។ វិធានទាំងនេះ អាចស្វែងរកបាននៅក្នុងជំពូក 392-172A នៃច្បាប់រដ្ឋបាលរបស់ទីក្រុងវ៉ាស៊ីងតោន (WAC)។ ឯកសារនេះអនុលោមតាមសេចក្តីជូនដំណឹងស្តីពីកិច្ចការពារតាមនីតិវិធីគំរូរបស់នាយកដ្ឋានអប់រំសហរដ្ឋអាមេរិក ដែលបានកែសម្រួលនៅខែមិថុនា ឆ្នាំ 2009។

## តើសេចក្តីប្រកាសនេះធ្វើឡើងសម្រាប់អ្នកណា

សេចក្តីជូនដំណឹងនេះ ធ្វើឡើងសម្រាប់មាតាបិតា មាតាបិតាជំនួស និងសិស្សពេញវ័យ។ ពាក្យ "អ្នក" ឬ "មាតាបិតា" និង "កូនអ្នក" ក៏អាចសម្តៅទៅលើមាតាបិតាជំនួស និងសិស្សពេញវ័យផងដែរ។ នៅក្នុងសេចក្តីជូនដំណឹងនេះ "ស្រុករដ្ឋបាលសាលា" ឬ "ស្រុករដ្ឋបាល" រួមមានសាលារដ្ឋ ដែលប្រតិបត្តិការដោយឯករាជ្យ (Charter school) និងសាលារដ្ឋដទៃទៀតដូចជា៖ ស្រុករដ្ឋបាលសាលាដែលផ្តល់សេវាអប់រំ និងទីភ្នាក់ងារផ្តល់សេវាអប់រំ។

## សម្រាប់ព័ត៌មានបន្ថែម

ព័ត៌មានបន្ថែមអំពីសេវាអប់រំពិសេស និងកិច្ចការពារតាមនីតិវិធីទាំងនេះ អាចទទួលបាន តាមរយៈការទំនាក់ទំនងនាយកផ្នែកអប់រំពិសេសនៃស្រុករដ្ឋបាលសាលារបស់អ្នក មណ្ឌលព័ត៌មាន និងការបណ្តុះបណ្តាលមាតាបិតារបស់រដ្ឋ អង្គការផ្តល់ជំនួយដល់គ្រួសារដែលមានពិការភាព (Partnerships for Action Voices for Empowerment (Washington Pave)) ឬតាមរយៈ OSPI។ OSPI មានគេហទំព័រដែលនិយាយពីការអប់រំពិសេសនៅ ៖ http://www.k12.wa.us/SpecialEd/default.aspx។ OSPI មានអ្នកគ្រប់គ្រងកម្មវិធី និងមន្ត្រីស៊ើបអង្កេតបណ្តឹងតវ៉ាអំពីការអប់រំពិសេស ដើម្បីជួយអ្នកជាមួយនឹងចម្ងល់អំពីកម្មវិធីអប់រំពិសេសរបស់កូនអ្នក។ អ្នកអាចទំនាក់ទំនងមកកាន់ការិយាល័យ OSPI ផ្នែកអប់រំពិសេសតាមរយៈលេខទូរស័ព្ទ (360) 725-6075, TTY (360) 586-0126 ឬអ៊ីម៉ែល speced@k12.wa.us។

## <u>សេចក្តីជូនដំណឹងស្តីពីកិច្ចការពារតាមនីតិវិធី</u>

### <u>34 CFR § 300.504; WAC 392-172A-05015</u>

សេចក្តីជូនដំណឹងនេះ ត្រូវតែផ្តល់ជូនអ្នកមួយច្បាប់ (១) នៅរៀងរាល់មួយឆ្នាំសិក្សាម្តង និង (២) នៅពេលមានការបញ្ជូនដំបូង ឬសំណើសុំវាយតម្លៃរបស់អ្នក (៣) នៅពេលស្រុករដ្ឋបាលសាលាទទួលបានបណ្តឹងពលរដ្ឋទាក់ទងនឹងការអប់រំពិសេសដំបូងរបស់អ្នកនៅក្នុងឆ្នាំសិក្សា (៤) ក្រោយពេលស្រុករដ្ឋបាលសាលាទទួលបាន សំណើសុំសវនាការត្រឹមត្រូវតាមច្បាប់ដំបូងរបស់អ្នកក្នុងឆ្នាំសិក្សា (៥) នៅពេលសេចក្តីសម្រេចមួយត្រូវបានធ្វើឡើងដើម្បីចាត់វិធានការណ៍វិន័យ ដែលធ្វើឲ្យមានការផ្លាស់ប្តូរការកំណត់សិទ្ធិទទួលបានសេវា **<u>និង</u>** (៦) តាមការស្នើសុំរបស់អ្នក។

សេចក្តីជូនដំណឹងស្តីពីកិច្ចការពារតាមនីតិវិធីនេះ រួមបញ្ចូលនូវការពន្យល់ពេញលេញពីកិច្ចការពារតាមនីតិវិធីទាំងឡាយណាដែលទាក់ទងនឹងការកំណត់សិទ្ធិទទួលសេវាអប់រំដោយឯកតោភាគី សម្រាប់កូនអ្នកនៅសាលាឯកជន ដែលជាបន្ទុកចំណាយសាធារណៈ នីតិវិធីនៃបណ្តឹងតវ៉ាពលរដ្ឋទាក់ទងនឹងការអប់រំពិសេស ការយល់ព្រមដែលបានជូនដំណឹង កិច្ចការពារតាមនីតិវិធីដែលមានចែងនៅក្នុងបទប្បញ្ញត្តិ IDEA ក្នុង Subpart E នៃ Part B និងបញ្ញត្តិស្តីពីការរក្សាការសម្ងាត់នៃព័ត៌មានដែលមាននៅក្នុងបទប្បញ្ញត្តិ IDEA ក្នុង Subpart នៃ Part B។ ស្រុករដ្ឋបាលសាលាអាចជ្រើសប្រើប្រាស់សេចក្តីជូនដំណឹងនេះ ឬបង្កើតសេចក្តីជូនដំណឹងស្តីពីកិច្ចការពារតាមនីតិវិធីផ្ទាល់ខ្លួនសម្រាប់មាតាបិតា។

## <u>សេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុន</u>

### <u>34 CFR §300.503; WAC 392-172A-05010</u>

ស្រុករដ្ឋបាលសាលារបស់អ្នកត្រូវតែផ្តល់ព័ត៌មានជូនអ្នកជាលាយលក្ខណ៍អក្សរ អំពីសេចក្តីសម្រេចសំខាន់ៗ ដែលធ្វើឲ្យប៉ះពាល់ដល់កម្មវិធីអប់រំពិសេសរបស់កូនអ្នក។ នេះ ហៅថា សេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុន ហើយវាជាឯកសារមួយ ដែលឆ្លុះបញ្ចាំងពីសេចក្តីសម្រេច ដែលធ្វើឡើងនៅកិច្ចប្រជុំមួយ ឬដោយស្រុករដ្ឋបាលសាលាដើម្បីឆ្លើយតបទៅនឹងសំណើសុំរបស់អ្នក។ **ស្រុករដ្ឋបាលសាលាតម្រូវឲ្យផ្ញើជូនអ្នកនូវសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុនមួយច្បាប់ ក្រោយពេលធ្វើសេចក្តីសម្រេច ប៉ុន្តែមុនពេលអនុវត្តសេចក្តីសម្រេចនេះ**។ ទាំងនេះគឺជាសេចក្តីសម្រេចទាក់ទងនឹងសំណើសុំ ឬការបដិសេធផ្តួចផ្តើម ឬផ្លាស់ប្តូរអត្តសញ្ញាណកម្ម ការវាយតម្លៃ ការកំណត់សិទ្ធិទទួលសេវាអប់រំ ឬការផ្តល់ការអប់រំសាធារណៈសមស្របដោយឥតគិតថ្លៃ (FAPE) ដល់កូនអ្នក។

សេចក្ដីជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុន រួមមាន៖

- ចំណុចដែលស្រុករដ្ឋបាលសាលាកំពុងលើកសំណើ ឬបដិសេធមិនធ្វើ។
- ការពន្យល់ពីមូលហេតុ ដែលស្រុករដ្ឋបាលសាលាកំពុងលើកសំណើ ឬបដិសេធមិនព្រមចាត់វិធានការណ៍។
- ការបរិយាយអំពីជម្រើសណាមួយផ្សេងទៀត ដែលពិចារណាដោយក្រុមការងារនៃកម្មវិធីអប់រំឯកត្តបុគ្គល (IEP) និងមូលហេតុនៃការបដិសេធជម្រើសទាំងនោះ។
- ការបរិយាយអំពីនីតិវិធីវាយតម្លៃ ការប៉ាន់ប្រមាណ ឯកសារ ឬរបាយការណ៍នីមួយៗដែលប្រើប្រាស់ជាមូលដ្ឋានសម្រាប់សកម្មភាព។
- ការបរិយាយអំពីកត្តាណាមួយផ្សេងទៀត ដែលទាក់ទងនឹងសកម្មភាព។
- ការបរិយាយអំពីនីតិវិធីវាយតម្លៃណាមួយ ដែលស្រុករដ្ឋបាលសាលាស្នើឡើងដើម្បីធ្វើការវាយតម្លៃបឋម និងការ វាយតម្លៃឡើងវិញណាមួយ។
- សេចក្ដីថ្លែងការណ៍អំពីកិច្ចការពារតាមនីតិវិធីសម្រាប់មាតាបិតា ដែលមានរៀបរាប់នៅក្នុងកូនសៀវភៅនេះ។
- វិធីដែលអ្នកអាចទទួលបានកូនសៀវភៅនៃសេចក្ដីជូនដំណឹងស្ដីពីកិច្ចការពារតាមនីតិវិធីនេះមួយច្បាប់ ឬរួមទាំងកូនសៀវភៅនៃសេចក្ដីជូនដំណឹងស្ដីពីកិច្ចការពារតាមនីតិវិធីនេះ ប្រសិនបើអ្នកមិនទាន់ទទួលបានមួយច្បាប់ទេ **និង**
- ប្រភពសម្រាប់ឲ្យអ្នកទំនាក់ទំនងដើម្បីទទួលបានជំនួយលើការស្វែងយល់កិច្ចការពារតាមនីតិវិធីទាំងនេះ។

ឧទាហរណ៍អំពីពេលដែលអ្នកទទួលបានសេចក្ដីជូនដំណឹងជាលាយលក្ខណ៍ជាមុនគឺ៖

- ស្រុករដ្ឋបាលសាលាមានបំណងចង់វាយតម្លៃ ឬវាយតម្លៃឡើងវិញលើកូនអ្នក ឬស្រុករដ្ឋបាលសាលាកំពុងបដិសេធក្នុងការវាយតម្លៃ ឬវាយតម្លៃឡើងវិញលើកូនអ្នក។
- កម្មវិធី IEP ឬការកំណត់សិទ្ធិទទួលសេវាអប់រំរបស់កូនអ្នកកំពុងមានការកែប្រែ។
- អ្នកបានស្នើឲ្យមានការកែប្រែ ហើយស្រុករដ្ឋបាលសាលាកំពុងបដិសេធធ្វើការកែប្រែ។
- អ្នកបានផ្ដល់សេចក្ដីជូនដំណឹងជាលាយលក្ខណ៍អក្សរដល់ស្រុករដ្ឋបាលសាលាថា អ្នកកំពុងលុបចោលការព្រមព្រៀងឲ្យកូនអ្នក ទទួលបានសេវាអប់រំពិសេស។

សេចក្ដីជូនដំណឹងជាលាយលក្ខណ៍ជាមុនត្រូវសរសេរជាភាសា ដែលសាធារណៈជនទូទៅអាចយល់បាន និងផ្ដល់ជូនជាភាសាកំណើតរបស់អ្នក ឬមធ្យោបាយទំនាក់ទំនងដទៃទៀត ដែលអ្នកប្រើប្រាស់

លុះត្រាតែវាមិនអាចធ្វើទៅបាន។ ប្រសិនបើភាសាកំណើត ឬមធ្យោបាយទំនាក់ទំនងដទៃទៀតរបស់អ្នកមិនមែនជាភាសាសរសេរ ស្រុករដ្ឋបាលសាលាត្រូវចាត់វិធានការណ៍ធានាថា៖ (១) សេចក្តីជូនដំណឹងត្រូវបានបកប្រែដោយផ្ទាល់មាត់ ឬតាមមធ្យោបាយផ្សេងទៀត ជាភាសាកំណើតរបស់អ្នក ឬមធ្យោបាយទំនាក់ទំនងផ្សេងទៀត (២) អ្នកយល់ពីខ្លឹមសារនៅក្នុងសេចក្តីជូនដំណឹងនោះ និង (៣) មានភ័ស្តុតាងបញ្ជាក់ជាលាយលក្ខណ៍អក្សរថា បានបំពេញតាមលក្ខខណ្ឌតម្រូវក្រោមចំណុច (១) និង (២)។

## ភាសាកំណើត

### 34 CFR §300.29; WAC 392-172A-01120

*ភាសាកំណើត* នៅពេលប្រើប្រាស់ទាក់ទងនឹងបុគ្គល ដែលមានចំណេះដឹងផ្នែកភាសា អង់គ្លេសនៅមានកម្រិត មានន័យថា៖

1. ភាសា ដែលប្រើប្រាស់ជាធម្មតាដោយបុគ្គលនោះ ឬក្នុងករណីជាកុមារគឺជា ភាសាដែលប្រើប្រាស់ជាធម្មតាដោយមាតាបិតារបស់កុមារ។
2. គ្រប់ទំនាក់ទំនងដោយផ្ទាល់ទាំងអស់ជាមួយកុមារ (រួមទាំងការវាយតម្លៃកុមារ) ភាសាដែលប្រើប្រាស់ជាធម្មតាដោយកុមារនោះនៅក្នុងផ្ទះ ឬបរិស្ថានសិក្សា។

ចំពោះបុគ្គលថ្លង់ ឬខ្វាក់ ឬសម្រាប់បុគ្គលដែលគ្មានភាសាសរសេរ មធ្យោបាយទំនាក់ទំនងគឺជាអ្វីដែលបុគ្គលនោះប្រើប្រាស់ជាធម្មតា (ដូចជា ភាសាសញ្ញា អក្សរមនុស្សខ្វាក់ ឬទំនាក់ទំនងផ្ទាល់ មាត់)។

## សារអេឡិចត្រូនិក

### 34 CFR §300.505; WAC 392-172A-05020

ប្រសិនបើស្រុករដ្ឋបាលសាលារបស់អ្នកផ្តល់ឲ្យមាតាបិតានូវជម្រើសក្នុងការទទួលឯកសារតាមរយៈ អ៊ីម៉ែល អ្នកអាចជ្រើសរើសទទួលឯកសារដូចខាងក្រោម តាមរយៈអ៊ីម៉ែល៖

1. ការជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុន
2. សេចក្តីជូនដំណឹងស្តីពីកិច្ចការពារតាមនីតិវិធី **និង**
3. សេចក្តីជូនដំណឹងទាក់ទងនឹងសំណើសុំសវនាការត្រឹមត្រូវតាមច្បាប់

## ការយល់ព្រមរបស់មាតាបិតា - និយមន័យ

### 34 CFR §300.9; WAC 392-172A-01040

*ការយល់ព្រម* មានន័យថា៖

1. អ្នកត្រូវបានជូនដំណឹងយ៉ាងពេញលេញជាភាសាកំណើតរបស់អ្នក ឬតាមមធ្យោបាយទំនាក់ទំនងដទៃទៀត (ដូចជា ភាសាសញ្ញា អក្សរមនុស្សខ្វាក់ ឬទំនាក់ទំនងដោយផ្ទាល់មាត់) ពីព័ត៌មានទាំងឡាយដែលទាក់ទងនឹងសកម្មភាព ដែលអ្នកផ្តល់ការយល់ព្រម។
2. អ្នកយល់ និងឯកភាពជាលាយលក្ខណ៍អក្សរចំពោះសកម្មភាពនោះ ហើយការយល់ព្រមរៀបរាប់អំពីសកម្មភាពនោះ និងកត់ត្រាជាឯកសារ (ប្រសិនបើមាន) ដែលនឹងត្រូវផ្សព្វផ្សាយ ហើយទៅកាន់អ្នកណាម្នាក់ **និង**
3. អ្នកយល់ថា ការយល់ព្រមធ្វើឡើងដោយស្ម័គ្រចិត្តពីអ្នក ហើយអ្នកអាចលុបចោល (ដកហូត) ការយល់ព្រមរបស់អ្នកវិញនៅពេលណាក៏បាន។

ប្រសិនបើអ្នកមានបំណងចង់លុបចោលការយល់ព្រមក្រោយពីកូនអ្នកបានចាប់ ផ្តើមទទួលសេវាអប់រំពិសេសនោះ អ្នកត្រូវតែធ្វើឡើងជាលាយលក្ខណ៍អក្សរ។ ការដកការយល់ព្រមរបស់អ្នកមិនលុបចោល (បដិសេធ) នូវសកម្មភាពមួយដែលបានចាប់ផ្តើម បន្ទាប់ពីអ្នកបានផ្តល់ការយល់ព្រម និងមុនពេលដែលអ្នកដកការយល់ព្រមនោះ។ លើសពីនេះ ស្រុករដ្ឋបាលសាលាមិនត្រូវបានតម្រូវឲ្យកែប្រែ (ផ្លាស់ប្តូរ) ឯកសារអប់រំរបស់កូនអ្នក ដើម្បីលុបចោលឯកសារយោងណាមួយទាក់ទងនឹងការទទួលសេវាអប់រំពិសេសរបស់កូនអ្នកឡើយ។

## ការយល់ព្រមរបស់មាតាបិតា - លក្ខខណ្ឌតម្រូវ

### 34 CFR §300.300; WAC 392-172A-03000

#### ការយល់ព្រមសម្រាប់ការវាយតម្លៃបឋម

ស្រុករដ្ឋបាលសាលារបស់អ្នកមិនអាចធ្វើការវាយតម្លៃបឋមលើកូនអ្នក ដើម្បីកំណត់សិទ្ធិទទួលបានការអប់រំពិសេស និងសេវាពាក់ព័ន្ធនោះទេ លុះត្រាតែស្រុករដ្ឋបាលសាលាផ្តល់ការជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុន ដែលរៀបរាប់អំពីសកម្មភាពវាយតម្លៃដែលបានស្នើឡើង និងទទួលបានការយល់ព្រមជាលាយលក្ខណ៍អក្សរដល់អ្នក។ ស្រុករដ្ឋបាលសាលារបស់អ្នកត្រូវតែខិតខំព្យាយាមឲ្យបានសមស្របដើម្បីទទួលបានការយល់ព្រមដែលបានជូនដំណឹង សម្រាប់ការវាយតម្លៃបឋមដើម្បីសម្រេចថាតើកូនអ្នកមានសិទ្ធិទទួលការអប់រំពិសេសឬយ៉ាងណា។

អ្នកយល់ព្រមលើការវាយតម្លៃបឋមមិនមែនមានន័យថា អ្នកបានផ្តល់ការយល់ព្រមដល់ស្រុករដ្ឋបាលសាលា ឲ្យចាប់ផ្តើមផ្តល់ការអប់រំពិសេស និងសេវាពាក់ព័ន្ធដល់កូនរបស់អ្នកឡើយ។ ស្រុករដ្ឋបាលសាលាក៏ត្រូវទទួលការយល់ព្រមពីអ្នកផងដែរ ដើម្បីផ្តល់ការអប់រំពិសេស និងសេវាពាក់ព័ន្ធដល់កូនអ្នកសម្រាប់ពេលដំបូង។

ប្រសិនបើកូនអ្នកចុះឈ្មោះចូលរៀននៅសាលារដ្ឋ ឬអ្នកកំពុងព្យាយាមចុះឈ្មោះកូននៅក្នុងសាលារដ្ឋ ហើយអ្នកបានបដិសេធផ្តល់ការយល់ព្រម ឬអ្នកខកខានមិនបានឆ្លើយតបទៅនឹងសំណើសុំផ្តល់ការយល់ព្រមលើការវាយតម្លៃបឋម ស្រុករដ្ឋបាលសាលារបស់អ្នក**អាច** ប៉ុន្តែមិនតម្រូវឲ្យព្យាយាមទទួលការយល់ព្រមពីអ្នក ដោយប្រើប្រាស់ការសម្រុះសម្រួល ឬនីតិវិធីសវនាការត្រឹមត្រូវតាមច្បាប់ ដូចបានរៀបរាប់នៅក្នុងផ្នែកបន្ទាប់នៃសេចក្តីជូនដំណឹងនេះ។ ស្រុករដ្ឋបាលសាលារបស់អ្នកនឹងមិនរំលោភបំពានលើកាតព្វកិច្ចរបស់ខ្លួនក្នុងការកំណត់ទីតាំង កំណត់អត្តសញ្ញាណ និងវាយតម្លៃកូនអ្នកនោះទេ ប្រសិនបើស្រុករដ្ឋបាលសាលាជ្រើសរើសមិនបន្តការវាយតម្លៃលើកូនអ្នកនៅក្នុងស្ថានភាពនេះ។

## ច្បាប់ពិសេសសម្រាប់ការវាយតម្លៃបឋមលើអ្នកស្ថិតក្រោមអាណាព្យាបាលរបស់រដ្ឋ

ប្រសិនបើកូនអ្នកស្ថិតក្រោមអាណាព្យាបាលរបស់រដ្ឋ ហើយមិនបានរស់នៅជាមួយអ្នក ស្រុករដ្ឋបាលសាលាមិនត្រូវការការយល់ព្រមពីអ្នកសម្រាប់ការវាយតម្លៃបឋម ក្នុងការកំណត់ថាតើកូនអ្នកមានសិទ្ធិទទួលការអប់រំពិសេសឬយ៉ាងណានោះទេ ប្រសិនបើ៖

1. ទោះបីមានការព្យាយាមសមហេតុផលក៏ដោយ ក៏ស្រុករដ្ឋបាលសាលាមិនអាចស្វែងរកអ្នកបានទេ។
2. សិទ្ធិរបស់អ្នកជាមាតាបិតាត្រូវបានបញ្ចប់ យោងតាមច្បាប់រដ្ឋ **ឬ**
3. ចៅក្រមមួយរូបបានផ្ទេរសិទ្ធិក្នុងការធ្វើសេចក្តីសម្រេចលើការអប់រំ ទៅឲ្យបុគ្គលម្នាក់ទៀតក្រៅពីអ្នក ហើយបុគ្គលនោះបានផ្តល់ការយល់ព្រមសម្រាប់ការវាយតម្លៃបឋម។

*អ្នកស្ថិតក្រោមអាណាព្យាបាលរបស់រដ្ឋ* ដូចបានប្រើប្រាស់ក្នុង IDEA មានន័យថា ជាកុមារដែល ៖

1. ជាកូនធម៌ម្នាក់ ដែលមិនត្រូវបានដាក់ឲ្យនៅជាមួយឪពុកម្តាយធម៌។
2. ត្រូវបានចាត់ទុកថាជាកុមារស្ថិតក្រោមអាណាព្យាបាលរបស់រដ្ឋ ក្រោមច្បាប់ Washington State **ឬ**
3. ស្ថិតនៅក្នុងការគ្រប់គ្រងរបស់ក្រសួងសេវាសង្គម និងសុខភាព ឬទីភ្នាក់ងារសុខមាលភាពកុមារ សាធារណៈរបស់រដ្ឋមួយផ្សេងទៀត។

*អ្នកស្ថិតក្រោមអាណាព្យាបាលរដ្ឋ* មិនរាប់បញ្ចូលកូនធម៌ ដែលមានឪពុកម្តាយធម៌ទេ។

## <u>ការយល់ព្រមរបស់មាតាបិតាសម្រាប់សេវាបឋម និងការលុបចោលការយល់ព្រមបន្តសេវា</u>

ស្រុករដ្ឋបាលសាលារបស់អ្នកត្រូវតែខិតខំប្រឹងប្រែងឲ្យបានសមស្របក្នុងការទទួលការយល់ព្រមជាលាយលក្ខណ៍អក្សរ ដែលបានជូនដំណឹងរបស់អ្នក ហើយត្រូវតែទទួលការយល់ព្រមជាលាយលក្ខណ៍អក្សរដែលបានជូនដំណឹងរបស់អ្នកមុនពេលផ្តល់ការអប់រំពិសេស
និងសេវាពាក់ព័ន្ធដល់កូនអ្នក <u>សម្រាប់ពេលដំបូង</u>។

ប្រសិនបើអ្នកមិនឆ្លើយតបទៅនឹងសំណើសុំឲ្យផ្តល់ការយល់ព្រម ដើម្បីឲ្យកូនអ្នកទទួលការអប់រំពិសេស និងសេវាពាក់ព័ន្ធសម្រាប់ពេលដំបូងទេ ឬប្រសិនបើអ្នកបដិសេធផ្តល់ការយល់ព្រមនេះ ស្រុករដ្ឋបាលសាលារបស់អ្នក<u>មិនអាច</u>ប្រើប្រាស់នីតិវិធីសម្រុះសម្រួល ដើម្បីព្យាយាមទទួលការព្រមព្រៀងរបស់អ្នក ឬប្រើប្រាស់នីតិវិធីសវនាការត្រឹមត្រូវតាមច្បាប់ ដើម្បីទទួលបានការសម្រេចមួយពីមន្ត្រីរដ្ឋបាលសវនាការ ដើម្បីផ្តល់ការអប់រំពិសេស និងសេវាពាក់ព័ន្ធដល់កូនអ្នក។

ប្រសិនបើអ្នកបដិសេធ ឬមិនឆ្លើយតបទៅនឹងសំណើសុំឲ្យផ្តល់ការយល់ព្រម ដើម្បីឲ្យកូនអ្នកទទួលបានការអប់រំពិសេស និងសេវាពាក់ព័ន្ធសម្រាប់ពេលដំបូង ស្រុករដ្ឋបាលសាលាមិនអាចផ្តល់ការអប់រំពិសេស និងសេវាពាក់ព័ន្ធដល់កូនអ្នកបានទេ។ នៅក្នុងស្ថានភាពនេះ ស្រុករដ្ឋបាលសាលារបស់អ្នក៖

1. មិនរំលោភទៅលើលក្ខខណ្ឌតម្រូវក្នុងការផ្តល់ការអប់រំសាធារណៈសមស្របដោយឥតគិតថ្លៃ (FAPE) សម្រាប់កូនអ្នក ដោយសារការខកខានក្នុងការផ្តល់សេវាទាំងនោះដល់កូនអ្នក **<u>និង</u>**
2. មិនតម្រូវឲ្យមានការប្រជុំ IEP ឬបង្កើតកម្មវិធី IEP សម្រាប់ការអប់រំពិសេស និងសេវាពាក់ព័ន្ធសម្រាប់កូនអ្នក ដែលការយល់ព្រមរបស់អ្នកត្រូវបានស្នើសុំ។

នៅពេលអ្នកផ្តល់ការយល់ព្រមជាលាយលក្ខណ៍អក្សរឲ្យកូនអ្នកទទួលបានការអប់រំពិសេស និងសេវាពាក់ព័ន្ធ ហើយស្រុករដ្ឋបាលសាលាចាប់ផ្តើមផ្តល់សេវាអប់រំពិសេស កូនអ្នក នឹងនៅតែមានសិទ្ធិទទួលបានសេវាអប់រំពិសេស រហូតដល់៖

1. ពួកគេត្រូវបានវាយតម្លៃឡើងវិញ ហើយរកឃើញថា លែងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការទទួលសេវាអប់រំពិសេស។
2. ពួកគេបញ្ចប់ការសិក្សាដោយមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិជាធម្មតា។
3. ពួកគេមានអាយុ 21ឆ្នាំ (ឬប្រសិនបើកូនអ្នកដល់អាយុ 21ឆ្នាំ ក្រោយថ្ងៃទី30 ខែសីហា ពួកគេមានសិទ្ធិទទួលបានសេវានានារហូតដល់ដំណាច់ឆ្នាំសិក្សា) **<u>ឬ</u>**
4. អ្នកជូនដំណឹងដល់ស្រុករដ្ឋបាលសាលាអំពីការលុបចោលជាលាយលក្ខណ៍នូវការយល់ព្រមរបស់ខ្លួនសម្រាប់ការបន្តផ្តល់សេវាអប់រំពិសេស។

ប្រសិនបើអ្នកលុបចោលការយល់ព្រមរបស់ខ្លួនជាលាយលក្ខណ៍អក្សរសម្រាប់ការបន្តផ្តល់សេវា បន្ទាប់ពីស្រុករដ្ឋបាលសាលាបានផ្តួចផ្តើមឲ្យមានសេវាអប់រំពិសេសរួចមក ស្រុករដ្ឋបាលសាលាត្រូវតែផ្តល់ *ការជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុន* ដល់អ្នកតាមពេលវេលាសមស្រប មុនពេលដែលវាឈប់ផ្តល់សេវាអប់រំពិសេសដល់កូនអ្នក។ សេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុននឹងរួមបញ្ចូលទាំងកាលបរិច្ឆេទ ដែលស្រុករដ្ឋបាលសាលាឈប់ផ្តល់សេវាទាំងនោះ ដល់កូនអ្នក ហើយជូនដំណឹង អ្នកថា ស្រុករដ្ឋបាលសាលា៖

1. មិនរំលោភបំពានលើលក្ខខណ្ឌនៃការផ្តល់ការអប់រំសាធារណៈសមស្របដោយឥតគិតថ្លៃ (FAPE) ដល់កូនអ្នក ដោយសារការខកខានមិនបានផ្តល់សេវាទាំងនោះដល់កូនអ្នក **ឬ**
2. មិនតម្រូវឲ្យមានការប្រជុំ IEP ឬបង្កើតកម្មវិធី IEP ដើម្បីផ្តល់ការអប់រំពិសេស និងសេវាពាក់ព័ន្ធបន្ថែមសម្រាប់កូនអ្នក។

ស្រុករដ្ឋបាលសាលាមិនអាចប្រើប្រាស់កិច្ចដំណើរការត្រឹមត្រូវតាមច្បាប់ ដើម្បីបញ្ឈប់ការលុបចោលជាលាយលក្ខណ៍អក្សររបស់អ្នក ឬមិនអាចប្រើប្រាស់នីតិវិធីសម្រុះសម្រួល ដើម្បីទទួលបានការព្រមព្រៀងពីអ្នកក្នុងការបន្តផ្តល់សេវាអប់រំពិសេសដល់កូនរបស់អ្នកឡើយ។ បន្ទាប់ពីស្រុករដ្ឋបាលសាលាឈប់ផ្តល់សេវាអប់រំពិសេសដល់កូនអ្នក កូនអ្នកលែងត្រូវបានចាត់ទុកថា មានសិទ្ធិទទួលបានការអប់រំពិសេសទៀតហើយ និងត្រូវស្ថិតនៅក្រោមលក្ខខណ្ឌតម្រូវតែមួយ ដែលអនុវត្តចំពោះសិស្សទាំងអស់។ អ្នក ឬអ្នកដទៃទៀត ដែលស្គាល់កូនអ្នក រួមទាំងស្រុករដ្ឋបាលសាលាផងនោះ អាចបញ្ជូនកុមារទៅធ្វើការវាយតម្លៃបឋមវិញ នៅពេលណាមួយ បន្ទាប់ពីអ្នកលុបចោលការយល់ព្រមឲ្យកូនអ្នកទទួលបានការអប់រំពិសេស។

## <u>ការយល់ព្រមរបស់មាតាបិតាសម្រាប់ការវាយតម្លៃឡើងវិញ</u>

ប្រសិនបើការធ្វើតេស្តថ្មីត្រូវធ្វើឡើងជាផ្នែកមួយនៃការវាយតម្លៃកូនអ្នកឡើងវិញនោះ ស្រុករដ្ឋបាលសាលារបស់អ្នកត្រូវតែទទួលបានការយល់ព្រម ដែលបានជូនដំណឹង មុនពេលវាយតម្លៃកូនអ្នកឡើងវិញ លុះត្រាតែស្រុករដ្ឋបាលសាលារបស់អ្នកអាចបង្ហាញឲ្យឃើញថា៖

1. វាចាត់វិធានការណ៍សមស្រប ដើម្បីទទួលបានការយល់ព្រមពីអ្នកក្នុងការវាយតម្លៃកូនអ្នកឡើងវិញ **<u>និង</u>**
2. អ្នកមិនបានឆ្លើយតប។

ប្រសិនបើអ្នកបដិសេធមិនយល់ព្រមធ្វើតេស្តថ្មី ដែលជាផ្នែកមួយនៃការវាយតម្លៃឡើងវិញលើកូនអ្នក ស្រុករដ្ឋបាលសាលាអាច ប៉ុន្តែមិនតម្រូវឲ្យធ្វើការវាយតម្លៃឡើងវិញលើកូនអ្នក ដោយប្រើប្រាស់នីតិវិធីសម្រុះសម្រួល ដើម្បីស្វែងរកការព្រមព្រៀងពីអ្នក ឬប្រើប្រាស់នីតិវិធីសវនាការត្រឹមត្រូវតាមច្បាប់ក្នុងការបញ្ឈប់ការបដិសេធចំពោះការយល់ព្រមលើការវាយតម្លៃឡើងវិញលើកូនអ្នក។ ទាក់ទងនឹងការវាយតម្លៃដំបូង ស្រុករដ្ឋបាលសាលារបស់អ្នកមិនរំលោភបំពានលើកាតព្វកិច្ចរបស់ខ្លួន ក្រោម Part B នៃច្បាប់ IDEA ទេ ប្រសិនបើស្រុករដ្ឋបាលសាលាបដិសេធធ្វើការវាយតម្លៃឡើងវិញ ដោយប្រើប្រាស់នីតិវិធីសម្រុះ សម្រួល ឬនីតិវិធីត្រឹមត្រូវតាមច្បាប់នោះ។

## <u>ការកត់ត្រាទុកជាឯកសារនូវកិច្ចខិតខំប្រឹងប្រែងសមស្របក្នុងការទទួលបានការយល់ព្រមពីមាតាបិតា</u>

សាលារបស់អ្នកត្រូវតែរក្សាទុកឯកសារនៃការខិតខំប្រឹងប្រែងសមស្រប ដើម្បីទទួលបានការយល់ព្រមលើការវាយតម្លៃបឋមរបស់អ្នក ដើម្បីផ្តល់ការអប់រំពិសេស និងសេវាពាក់ព័ន្ធសម្រាប់ពេលដំបូង ធ្វើការវាយតម្លៃឡើងវិញដែលទាក់ទងនឹងការធ្វើតេស្តថ្មី និងដើម្បីស្វែងរកមាតាបិតារបស់កូនស្ថិតក្រោមអាណាព្យាបាលរបស់រដ្ឋសម្រាប់ការវាយតម្លៃបឋម។ ការកត់ត្រានេះ ត្រូវរួមមានកំណត់ត្រាការខិតខំប្រឹងប្រែងរបស់ស្រុករដ្ឋបាលសាលាលើចំណុចខាងក្រោមដូចជា ៖

1. កំណត់ហេតុពិស្តារកត់ត្រាការហៅទូរស័ព្ទ ឬការព្យាយាមហៅទូរស័ព្ទ និងលទ្ធផលនៃការហៅទូរស័ព្ទទាំងនោះ។
2. លិខិតឆ្លើយឆ្លងថតចម្លងដែលបានផ្ញើជូនអ្នក និងការឆ្លើយតបដែលបានទទួលណាមួយ **<u>និង</u>**
3. កំណត់ត្រាពិស្តារនៃការចុះជួបដល់ផ្ទះ ឬកន្លែងការងាររបស់អ្នក និងលទ្ធផលពីជំនួបទាំងនោះ។

## <u>ព័ត៌មានផ្សេងទៀតទាក់ទងនឹងការយល់ព្រម</u>

ការយល់ព្រមរបស់អ្នកមិនតម្រូវឲ្យមាន នៅមុនពេលស្រុករដ្ឋបាលសាលាអាច៖

1. ពិនិត្យឡើងវិញនូវទិន្នន័យមានស្រាប់ ដែលជាផ្នែកមួយនៃការវាយតម្លៃ ឬវាយតម្លៃឡើងវិញលើកូនអ្នក **<u>ឬ</u>**
2. ផ្តល់តេស្តសាកល្បងដល់កូនអ្នក ឬការវាយតម្លៃផ្សេងទៀតដែលផ្តល់ជូនគ្រប់កុមារ លុះត្រាតែតម្រូវឲ្យមានការយល់ព្រមពីមាតាបិតារបស់គ្រប់កុមារ មុនពេលធ្វើតេស្ត ឬការវាយតម្លៃនោះ។

ស្រុករដ្ឋបាលសាលារបស់អ្នកមិនអាចប្រើប្រាស់ការបដិសេធចំពោះការយល់ព្រមរបស់អ្នកលើសេវា ឬសកម្មភាពមួយ ដើម្បីបដិសេធអ្នក ឬកូនអ្នកក្នុងការទទួលបានសេវា អត្ថប្រយោជន៍ ឬសកម្មភាពណាមួយផ្សេងទៀតឡើយ។

ប្រសិនបើអ្នកចុះឈ្មោះកូននៅក្នុងសាលាឯកជនដោយចំណាយផ្ទាល់ខ្លួន ឬប្រសិនបើអ្នកផ្តល់ការសិក្សាឲ្យកូននៅផ្ទះ ហើយអ្នកមិនផ្តល់ការយល់ព្រមឲ្យវាយតម្លៃបឋម ឬវាយតម្លៃឡើងវិញលើកូនអ្នក ឬអ្នកខកខានមិនបានឆ្លើយតបទៅនឹងសំណើសុំផ្តល់ការយល់ព្រមរបស់អ្នក ស្រុករដ្ឋបាលសាលាមិនអាចប្រើប្រាស់នីតិវិធីសម្រុះសម្រួល ដើម្បីទទួលបានការយល់ព្រមពីអ្នក ឬប្រើប្រាស់នីតិវិធីសវនាការត្រឹមត្រូវតាមច្បាប់ក្នុងការបញ្ឈប់ការបដិសេធរបស់អ្នកឡើយ។ ស្រុករដ្ឋបាលសាលា ក៏មិនត្រូវបានតម្រូវឲ្យចាត់ទុកកូនអ្នកថា មានសិទ្ធិទទួលបានសេវាស្មើភាពពីសាលាឯកជន ដែលជាសេវាផ្តល់សម្រាប់សិស្សសាលាឯកជនមួយចំនួន ដែលមានសិទ្ធិទទួលការអប់រំពិសេសនោះទេ។

## ការវាយតម្លៃការអប់រំដោយឯករាជ្យ

### 34 CFR §300.502; WAC 392-172A-05005

អ្នកមានសិទ្ធិទទួលបានការវាយតម្លៃការអប់រំដោយឯករាជ្យ (IEE) លើកូនអ្នក ប្រសិនបើអ្នកមិនយល់ស្របនឹងការវាយតម្លៃដែលបានធ្វើឡើងដោយស្រុករដ្ឋបាលសាលារបស់អ្នក។ ប្រសិនបើអ្នកស្នើសុំ IEE ស្រុករដ្ឋបាលសាលាត្រូវតែផ្តល់ជូនអ្នកនូវព័ត៌មានអំពីទីកន្លែងដែលអ្នកអាចទទួលបាន IEE និងពីលក្ខណៈវិនិច្ឆ័យរបស់ស្រុករដ្ឋបាលសាលាដែលអនុវត្តចំពោះ IEE។

### និយមន័យ

- *ការវាយតម្លៃការអប់រំដោយឯករាជ្យ* (IEE) មានន័យថា ជាការវាយតម្លៃមួយដែលធ្វើឡើងដោយអនុរក្សមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលមិនបម្រើការឲ្យស្រុករដ្ឋបាលសាលាដែលទទួលខុសត្រូវចំពោះការអប់រំកូនអ្នក។
- *ចំណាយសាធារណៈ:* មានន័យថា ស្រុករដ្ឋបាលសាលាបង់ថ្លៃសម្រាប់ការវាយតម្លៃពេញលេញ ឬធានាថា ការវាយតម្លៃនេះ ផ្តល់ជូនអ្នកដោយឥតគិតថ្លៃ។

### សិទ្ធិរបស់មាតាបិតាក្នុងការទទួលបាន IEE ដោយចំណាយសាធារណៈ

អ្នកមានសិទ្ធទទួលបាន IEE លើកូនអ្នកដោយចំណាយសាធារណៈ ប្រសិនបើអ្នកមិនយល់ស្របនឹងការវាយតម្លៃកូនអ្នកដែលធ្វើឡើងដោយស្រុករដ្ឋបាលសាលារបស់អ្នក ដោយផ្អែកលើលក្ខខណ្ឌខាងក្រោម ៖

1. ប្រសិនបើអ្នកស្នើសុំធ្វើ IEE លើកូនអ្នកដោយចំណាយសាធារណៈនោះ ស្រុករដ្ឋបាលសាលារបស់អ្នកនៅក្នុងរយៈពេល 15ថ្ងៃប្រតិទិននៃសំណើសុំរបស់អ្នកត្រូវតែ ៖ (ក) ដាក់សំណើសុំ

សវនាការតាមផ្លូវច្បាប់ដើម្បីបង្ហាញថា ការវាយតម្លៃរបស់ពួកគេលើកូនអ្នកគឺ សមស្រប ឬការវាយតម្លៃលើកូនអ្នកដែលអ្នកទទួលបាន មិនបានបំពេញទៅតាមលក្ខណៈវិនិច្ឆ័យរបស់ស្រុករដ្ឋបាលសាលា **ឬក៏** (ខ) យល់ស្របផ្តល់ IEE ដោយចំណាយសាធារណៈ។

2. ប្រសិនបើស្រុករដ្ឋបាលសាលារបស់អ្នកស្នើសុំឲ្យមានសវនាការតាមផ្លូវច្បាប់ ហើយសេចក្តីសម្រេចចុងក្រោយគឺថា ការវាយតម្លៃរបស់ស្រុករដ្ឋបាលសាលាលើកូនអ្នកគឺសមស្របនោះ អ្នកនៅតែមានសិទ្ធិទទួលបាន IEE ប៉ុន្តែមិនស្ថិតនៅក្នុងចំណាយសាធារណៈឡើយ។
3. ប្រសិនបើអ្នកស្នើសុំ IEE លើកូនអ្នក ស្រុករដ្ឋបាលសាលារបស់អ្នកអាចនឹងសួរពីមូលហេតុដែលអ្នកជំទាស់នឹងការវាយតម្លៃដែលធ្វើឡើងដោយស្រុករដ្ឋបាលសាលា។ ប៉ុន្តែស្រុករដ្ឋបាលសាលាមិនតម្រូវឲ្យមានការពន្យល់ និងមិនអាចពន្យារពេលដោយមិនសមហេតុផលក្នុងការផ្តល់ IEE ដល់កូនអ្នកដោយចំណាយសាធារណៈ ឬដាក់សំណើសុំសវនាការតាមផ្លូវច្បាប់ ដើម្បីការពារការវាយតម្លៃរបស់ស្រុករដ្ឋបាលសាលាលើកូនអ្នកឡើយ។

អ្នកមានសិទ្ធិទទួលបាន IEE របស់កូនអ្នកតាមចំណាយសាធារណៈតែម្តងប៉ុណ្ណោះ នៅរាល់ពេលដែលស្រុករដ្ឋបាលសាលារបស់អ្នកធ្វើការវាយតម្លៃកូនអ្នក ដែលអ្នកមិនយល់ស្របជាមួយ។

## ការវាយតម្លៃផ្តួចផ្តើមដោយមាតាបិតា

ប្រសិនបើអ្នកទទួលបាន IEE លើកូនអ្នកតាមចំណាយសាធារណៈ ឬអ្នកផ្តល់ជូនស្រុករដ្ឋបាលសាលានូវ IEE ដែលអ្នកបានទទួលដោយចំណាយផ្ទាល់ខ្លួននោះ៖

1. ស្រុករដ្ឋបាលសាលារបស់អ្នកត្រូវតែពិចារណាលើលទ្ធផលនៃ IEE ក្នុងសេចក្តីសម្រេចណាមួយដែលធ្វើឡើងដោយគោរពតាមបញ្ញត្តិនៃការអប់រំសាធារណៈសមរម្យដោយឥតគិតថ្លៃ (FAPE) សម្រាប់កូនអ្នកប្រសិនបើវាបំពេញទៅតាមលក្ខណៈវិនិច្ឆ័យរបស់ស្រុករដ្ឋបាលសាលាសម្រាប់ IEE **ហើយ**
2. អ្នក ឬស្រុករដ្ឋបាលសាលារបស់អ្នកអាចនឹងបង្ហាញ IEE ជាភស្តុតាងនៅសវនាការតាមផ្លូវច្បាប់ទាក់ទិននឹងកូនអ្នក។

## សំណើសុំការវាយតម្លៃដោយមន្ត្រីរដ្ឋបាលសវនាការ (ALJ)

ប្រសិនបើ ALJ ស្នើសុំ IEE លើកូនអ្នកជាផ្នែកមួយនៃសវនាការតាមផ្លូវច្បាប់ ចំណាយនៃការវាយតម្លៃនេះត្រូវតែជាចំណាយសាធារណៈ។

### <u>លក្ខណៈវិនិច្ឆ័យរបស់ស្រុករដ្ឋបាលសាលា</u>

ប្រសិនបើ IEE ស្ថិតនៅក្នុងចំណាយសាធារណៈ លក្ខណៈវិនិច្ឆ័យដែលការវាយតម្លៃនោះទទួលបានរួមទាំងទីកន្លែងនៃការវាយតម្លៃ និងលក្ខណៈសម្បត្តិរបស់អនុរក្ស ត្រូវតែដូចគ្នានឹងលក្ខណៈវិនិច្ឆ័យដែលស្រុករដ្ឋបាលសាលាប្រើប្រាស់នៅពេលខ្លួនផ្តួចផ្តើមធ្វើការវាយតម្លៃ (ទៅដល់ទំហំដែលលក្ខណៈវិនិច្ឆ័យទាំងនោះ ស្របទៅតាមសិទ្ធិរបស់អ្នកក្នុងការទទួលបាន IEE)។

លើកលែងតែចំពោះលក្ខណៈវិនិច្ឆ័យដែលបានរៀបរាប់ខាងលើ ស្រុករដ្ឋបាលសាលាមិនអាចដាក់លក្ខខណ្ឌ ឬកំណត់ពេលវេលាទាក់ទងនឹងការធ្វើ IEE ដោយចំណាយសាធារណៈឡើយ។

## <u>ការរក្សាការសម្ងាត់នៃព័ត៌មាន</u>

IDEA ផ្តល់ជូនអ្នកនូវសិទ្ធិទាក់ទងនឹងឯកសារអប់រំពិសេសរបស់កូនអ្នក។ សិទ្ធិទាំងនេះ គឺបន្ថែមទៅលើសិទ្ធិដែលអ្នកមានក្រោមច្បាប់ស្តីពីសិទ្ធិអប់រំគ្រួសារ និងឯកជនភាព (FERPA) ដែលជាច្បាប់មួយដែលផ្តល់ការការពារចំពោះឯកសារអប់រំ ដល់សិស្សទាំងអស់។

### <u>និយមន័យ</u>

**34 CFR §300.611; WAC 392-172A-05180**

ដូចប្រើនៅក្នុងជំពូកស្តីពី**ការរក្សាការសម្ងាត់នៃព័ត៌មាន៖**

- *ការបំផ្លាញចោល* មានន័យថា ការបំផ្លាញចោល ឬការដកចេញដាក់ស្តែងនូវព័ត៌មានសម្គាល់ខ្លួនបុគ្គលពីព័ត៌មាន ដើម្បីឲ្យព័ត៌មាននោះមិនអាចសម្គាល់អត្តសញ្ញាណបុគ្គលបានតទៅទៀត។
- *ឯកសារអប់រំ* មានន័យថា ប្រភេទនៃឯកសារដែលមានចែងនៅក្នុងនិយមន័យនៃ "ឯកសារអប់រំ" នៅក្នុង 34 CFR Part 99 (បទប្បញ្ញត្តិអនុវត្តច្បាប់ស្តីពីសិទ្ធិអប់រំគ្រួសារ និងឯកជនភាពឆ្នាំ 1974, 20 U.S.C. 1232g (FERPA))។
- *ទីភ្នាក់ងារចូលរួម* មានន័យ ស្រុករដ្ឋបាលសាលា ទីភ្នាក់ងារ ឬគ្រឹះស្ថានដែលប្រមូល រក្សាទុក ឬប្រើប្រាស់ព័ត៌មានដែលអាចសម្គាល់អត្តសញ្ញាណបុគ្គលបាន ឬកន្លែងដែលអាចយកព័ត៌មានបានក្រោម Part B ឬ IDEA។

## <u>ព័ត៌មានដែលអាចសម្គាល់អត្តសញ្ញាណបុគ្គល</u>

### <u>34 CFR §300.32; WAC 392-172A-01140</u>

*ព័ត៌មានដែលអាចសម្គាល់អត្តសញ្ញាណបុគ្គល* មានន័យថាជាព័ត៌មានដែលមាន ៖

1. ឈ្មោះកូនអ្នក ឈ្មោះអ្នកជាមាតាបិតា ឬឈ្មោះសមាជិកគ្រួសារណាម្នាក់ផ្សេងទៀត
2. អាសយដ្ឋានកូនអ្នក
3. ព័ត៌មានដែលអាចសម្គាល់អត្តសញ្ញាណបុគ្គលដូចជា លេខសន្តិសុខសង្គម ឬអត្តលេខសិស្សរបស់កូនអ្នក **ឬ**
4. បញ្ជីវាយលក្ខណៈភិនភាគផ្ទាល់ខ្លួនឬព័ត៌មានផ្សេងទៀតដែលធ្វើឲ្យអាចសម្គាល់អត្តសញ្ញាណកូនអ្នក ដោយមានភាពច្បាស់លាស់គួរសម។

## <u>សេចក្តីជូនដំណឹងចំពោះមាតាបិតា</u>

### <u>34 CFR §300.612; WAC 392-172A-05185</u>

OSPI ផ្តល់សេចក្តីជូនដំណឹងតាមរយៈបទប្បញ្ញត្តិរបស់ខ្លួន ដើម្បីជម្រាបជូនអ្នកឲ្យពេញលេញអំពីការរក្សាការសម្ងាត់នៃព័ត៌មានដែលអាចសម្គាល់អត្តសញ្ញាណបុគ្គលរួមមាន ៖

1. ការបរិយាយអំពីវិសាលភាពដែលសេចក្តីជូនដំណឹងនេះ ត្រូវផ្តល់ឲ្យជាភាសាកំណើតរបស់ក្រុមពលរដ្ឋនានានៅក្នុងរដ្ឋ Washington។
2. ការបរិយាយអំពីកុមារដែលព័ត៌មានសម្គាល់អត្តសញ្ញាណបុគ្គលរបស់ពួកគេត្រូវបានរក្សាទុក ប្រភេទនៃព័ត៌មានដែលចង់បាន វិធីសាស្ត្រដែលរដ្ឋ Washington ចង់ប្រើប្រាស់ក្នុងការប្រមូលព័ត៌មាន (រួមទាំងប្រភពនៃការប្រមូលព័ត៌មាននេះ) និងការប្រើប្រាស់នានានៃព័ត៌មាននេះ។
3. ការសង្ខេបពីគោលនយោបាយ និងនីតិវិធីនានាដែលស្រុករដ្ឋបាលសាលាត្រូវតែអនុវត្តតាមទាក់ទងនឹងការស្តុកទុក ការបង្ហាញទៅភាគីទីបី ការរក្សាទុក និងការបំផ្លាញចោលព័ត៌មានដែលអាចសម្គាល់អត្តសញ្ញាណបុគ្គល **<u>និង</u>**
4. ការបរិយាយអំពីសិទ្ធិទាំងអស់របស់មាតាបិតា និងសិស្សទាក់ទងនឹងព័ត៌មាននេះ រួមទាំងសិទ្ធិនានាក្រោមច្បាប់ស្តីពីសិទ្ធិអប់រំគ្រួសារ និងឯកជនភាព (FERPA) និងបទប្បញ្ញត្តិអនុវត្តរបស់វានៅក្នុង 34 CFR Part 99។

មុនពេលសកម្មភាពចំបងណាមួយក្នុងការកំណត់អត្តសញ្ញាណ ទីតាំង ឬការវាយតម្លៃនៅទូទាំងរដ្ឋ (ដែលត្រូវគេស្គាល់ផងដែរថា "សេវា Child Find") សេចក្តីជូនដំណឹងមួយត្រូវតែបោះពុម្ពនៅក្នុងកាសែត ឬផ្សព្វផ្សាយលើសារព័ត៌មានដទៃទៀត ឬទាំងពីរ ដែលបានចែកចាយគ្រប់គ្រាន់ដើម្បីជូនដំណឹងដល់មាតាបិតាទូទាំងរដ្ឋពីសកម្មភាពសម្រាប់កំណត់ទីតាំង កំណត់អត្តសញ្ញាណ និងវាយតម្លៃកុមារដែលត្រូវការសេវាអប់រំពិសេស និងសេវាពាក់ព័ន្ធ។

## សិទ្ធិក្នុងការប្រើប្រាស់

### 34 CFR §300.613-617; WAC 392-172A-05190–05210

អ្នកមានសិទ្ធិត្រួតពិនិត្យ និងពិនិត្យឡើងវិញលើឯកសារអប់រំរបស់កូនអ្នកដែលបានប្រមូល រក្សាទុក ឬប្រើប្រាស់ដោយស្រុករដ្ឋបាលសាលារបស់អ្នកក្រោម Part B នៃ IDEA។ ស្រុករដ្ឋបាលសាលាត្រូវតែគោរពតាមសំណើសុំរបស់អ្នកក្នុងការត្រួតពិនិត្យ និងពិនិត្យឡើងវិញលើឯកសារអប់រំណាមួយអំពីកូនអ្នកដោយគ្មានការពន្យារពេលមិនចាំបាច់ និងមុនការប្រជុំណាមួយទាក់ទងនឹងកម្មវិធីអប់រំសម្រាប់បុគ្គល (IEP) ឬសវនាការតាមផ្លូវច្បាប់ដែលគ្មានលំអៀងណាមួយ (រួមមានការប្រជុំស្វែងរកដំណោះស្រាយ ឬសវនាការតាមផ្លូវច្បាប់នៃការអប់រំពិសេសទាក់ទិននឹងវិន័យ) ហើយទោះក្នុងករណីណាក៏ដោយ មិនត្រូវលើសពី 45ថ្ងៃប្រតិទិនក្រោយពីអ្នកបានធ្វើការស្នើសុំ។

សិទ្ធិរបស់អ្នកក្នុងការត្រួតពិនិត្យ និងពិនិត្យឡើងវិញលើឯកសារអប់រំរួមមាន ៖

1. សិទ្ធិរបស់អ្នកក្នុងការទទួលបានការឆ្លើយតបពីស្រុករដ្ឋបាលសាលា ចំពោះសំណើសមហេតុផលរបស់អ្នកសម្រាប់ការពន្យល់ និងបកស្រាយឯកសារទាំងនេះ។
2. សិទ្ធិរបស់អ្នកក្នុងការស្នើសុំឲ្យស្រុករដ្ឋបាលសាលាផ្តល់ជូននូវឯកសារថតចម្លង ប្រសិនបើអ្នកមិនអាចត្រួតពិនិត្យ និងពិនិត្យឡើងវិញលើឯកសារទាំងនេះ ប្រកបដោយប្រសិទ្ធភាព លុះត្រាតែអ្នកទទួលបានច្បាប់ចម្លងទាំងនោះ **និង**
3. សិទ្ធិរបស់អ្នកក្នុងការឲ្យតំណាងរបស់អ្នកត្រួតពិនិត្យ និងពិនិត្យឡើងវិញលើឯកសារទាំងនេះ។

ស្រុករដ្ឋបាលសាលានឹងសន្មត់ថា អ្នកមានអំណាចត្រួតពិនិត្យ និងពិនិត្យឡើងវិញលើឯកសារពាក់ព័ន្ធនឹងកូនអ្នក លុះត្រាតែគេឲ្យដំណឹងថា អ្នកមិនមានអំណាចនៅក្រោមច្បាប់អនុវត្តដែលគ្រប់គ្រងបញ្ហាដូចជា អាណាព្យាបាលភាព ការរស់នៅបែកគ្នា ឬការលែងលះ។

### កំណត់ត្រានៃការប្រើប្រាស់

ស្រុករដ្ឋបាលសាលានីមួយៗ ត្រូវតែរក្សាទុកកំណត់ត្រារបស់គូភាគី ដែលអាចប្រើប្រាស់ឯកសារអប់រំដែលបានប្រមូល រក្សាទុក ឬប្រើប្រាស់ក្រោម Part B នៃ IDEA រួមមានឈ្មោះភាគី កាលបរិច្ឆេទឲ្យចូលប្រើប្រាស់ និងគោលបំណងដែលភាគីនេះ ត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់ឯកសារ។ ស្រុករដ្ឋបាលសាលាមិនត្រូវបានតម្រូវឲ្យរក្សាទុកនូវកំណត់ត្រានៃការប្រើប្រាស់នេះ សម្រាប់មាតាបិតា ឬនិយោជិតស្របច្បាប់នៃស្រុករដ្ឋបាលសាលាឡើយ។

### ឯកសារអំពីកុមារលើសពីម្នាក់

ប្រសិនបើឯកសារអប់រំណាមួយមានព័ត៌មានសិស្សលើសពីម្នាក់ អ្នកមានសិទ្ធិត្រួតពិនិត្យ និងពិនិត្យឡើងវិញតែលើព័ត៌មានដែលទាក់ទងនឹងកូនអ្នក ឬត្រូវបានជូនដំណឹងអំពីព័ត៌មាននោះ ក្នុងករណីដែលស្រុករដ្ឋបាលសាលាមិនអាចបង្ហាញព័ត៌មាននោះ ដល់អ្នកដោយគ្មានបង្ហើបប្រាប់ពីព័ត៌មានដែលអាចសម្គាល់អត្តសញ្ញាណបុគ្គលរបស់សិស្សមួយផ្សេងទៀត។

### បញ្ជីរាយប្រភេទ និងទីតាំងព័ត៌មាន

ប្រសិនបើអ្នកស្នើសុំវា ស្រុករដ្ឋបាលសាលាត្រូវតែផ្តល់ជូនអ្នកនូវបញ្ជីរាយប្រភេទ និងទីតាំងឯកសារអប់រំដែលបានប្រមូល រក្សាទុក ឬប្រើប្រាស់ដោយស្រុករដ្ឋបាលសាលា។

### ការបង់ថ្លៃ

ស្រុករដ្ឋបាលសាលាអាចនឹងគិតថ្លៃថតចម្លងឯកសារដែលបានធ្វើឡើងសម្រាប់អ្នកក្រោម Part B នៃ IDEA ប្រសិនបើថ្លៃសេវានេះ មិនរារាំងអ្នកពីការប្រើប្រាស់សិទ្ធិរបស់អ្នកក្នុងការត្រួតពិនិត្យ និងពិនិត្យឡើងវិញលើឯកសារទាំងនេះ។ វាមិនអាចគិតថ្លៃសម្រាប់ការរុករក ឬទាញយកព័ត៌មាននៅក្រោម IDEA ឡើយ។

## ការកែប្រែឯកសារតាមសំណើរបស់មាតាបិតា

### 34 CFR §300.618 – §300.621; WAC 392-172A-05125

ប្រសិនបើអ្នកជឿជាក់ថា ព័ត៌មាននៅក្នុងឯកសារអប់រំទាក់ទងនឹងកូនអ្នក ដែលត្រូវបានប្រមូល រក្សាទុក ឬប្រើប្រាស់ក្រោម IDEA មិនត្រឹមត្រូវ នាំឲ្យភាន់ច្រឡំ ឬរំលោភលើឯកជនភាព ឬសិទ្ធិផ្សេងទៀតរបស់កូនអ្នក អ្នកអាចស្នើសុំឲ្យស្រុករដ្ឋបាលសាលាកែប្រែព័ត៌មាននោះ។

ស្រុករដ្ឋបាលសាលាត្រូវតែសម្រេចថាតើត្រូវកែប្រែព័ត៌មានទៅតាមសំណើរបស់អ្នកក្នុងរយៈពេលមួយសមរម្យក្រោយពេលទទួលបានសំណើរបស់អ្នក។

**ឱកាសសម្រាប់សវនាការ នីតិវិធីសវនាការ និងលទ្ធផលនៃសវនាការ**

ប្រសិនបើស្រុករដ្ឋបាលសាលារបស់អ្នកបដិសេធមិនព្រមកែប្រែព័ត៌មាន ទៅតាមការស្នើសុំរបស់អ្នក ពួកគេត្រូវជូនដំណឹងអ្នកពីសេចក្តីសម្រេចនោះ រួចប្រាប់អ្នកអំពីសិទ្ធិទទួលបានសវនាការរបស់អ្នក ដោយស្រុករដ្ឋបាលសាលា។

អ្នកមានសិទ្ធស្នើសុំសវនាការ សម្រាប់សួរដេញដោលព័ត៌មាននៅក្នុងឯកសារអប់របស់កូនអ្នក ដើម្បីធានាថា វាត្រឹមត្រូវ មិនធ្វើឲ្យភាន់ច្រឡំ ឬក៏រំលោភលើឯកជនភាព ឬសិទ្ធិផ្សេងទៀតរបស់កូនអ្នក។ សវនាការសម្រាប់តវ៉ាព័ត៌មាននៅក្នុងឯកសារ ត្រូវតែធ្វើឡើងតាមនីតិវិធីសវនាការរបស់ស្រុករដ្ឋបាលសាលាក្រោម FERPA។ នេះ មិនមែនជាសវនាការតាមផ្លូវច្បាប់នៃការអប់រំពិសេសឡើយ។

ជាលទ្ធផលនៃសវនាការ ប្រសិនបើស្រុករដ្ឋបាលសាលាសម្រេចថា ព័ត៌មាននេះ<u>មិន</u>ត្រឹមត្រូវ ធ្វើឲ្យភាន់ច្រឡំ ឬក៏រំលោភលើឯកជនភាព ឬសិទ្ធិផ្សេងទៀតរបស់កុមារ ពួកគេត្រូវតែកែប្រែព័ត៌មានឲ្យបានសមស្រប ហើយជូនដំណឹងអ្នកពីការកែប្រែទាំងនេះ ជាលាយលក្ខណ៍អក្សរ។

ជាលទ្ធផលនៃសវនាការ ប្រសិនបើស្រុករដ្ឋបាលសាលាសម្រេចថា ព័ត៌មាននេះ<u>មិនមែន</u>មិនត្រឹមត្រូវ មិនធ្វើឲ្យភាន់ច្រឡំ ឬក៏មិនរំលោភលើឯកជនភាព ឬសិទ្ធិផ្សេងទៀតរបស់កុមារ ពួកគេត្រូវតែជូនដំណឹងអ្នកថា អ្នកមានសិទ្ធិដាក់សេចក្តីអះអាងនៅក្នុងឯកសារអប់រំរបស់កូនអ្នក ផ្តល់ជាមតិយោបល់លើព័ត៌មាន ឬផ្តល់មូលហេតុណាមួយដែលអ្នកមិនយល់ស្របនឹងសេចក្តីសម្រេចរបស់ស្រុករដ្ឋបាលសាលា។

ប្រសិនបើអ្នកជ្រើសរើសចង់ដាក់បញ្ចូលសេចក្តីអះអាងនៅក្នុងឯកសាររបស់កូនអ្នកនោះ សេចក្តីអះអាងនេះត្រូវតែ ៖

1. រក្សាទុកដោយស្រុករដ្ឋបាលសាលា ជាផ្នែកមួយនៃឯកសាររបស់កូនអ្នក ដរាបណាឯកសារ ឬផ្នែកដែលបានតវ៉ាត្រូវបានរក្សាទុក **<u>និង</u>**
2. ប្រសិនបើស្រុករដ្ឋបាលសាលាបង្ហាញពីឯកសាររបស់កូនអ្នក ឬផ្នែកដែលបានសួរដេញដោលទៅឲ្យភាគីណាមួយនោះ សេចក្តីអះអាងនេះ ក៏ត្រូវតែបង្ហាញទៅភាគីនោះដែរ។

## ការយល់ព្រមឲ្យបញ្ចេញព័ត៌មានដែលអាចសម្គាល់អត្តសញ្ញាណបុគ្គល

**34 CFR §300.622; WAC 392-172A-05225**

យើងខ្ញុំត្រូវតែទទួលបានការយល់ព្រមជាលាយលក្ខណ៍អក្សររបស់អ្នក មុននឹងបង្ហាញព័ត៌មានដែលអាចសម្គាល់អត្តសញ្ញាណបុគ្គល ទៅឲ្យអ្នកដទៃ លុះត្រាតែការបង្ហាញព័ត៌មានដែលមាននៅក្នុងឯកសារអប់រំរបស់កូនអ្នកត្រូវបានអនុញ្ញាត ដោយគ្មានការយល់ព្រមពីមាតាបិតាក្រោម FERPA។ ជាទូទៅការយល់ព្រមរបស់អ្នកមិនចាំបាច់ឡើយ មុនពេលដែលព័ត៌មានសម្គាល់អត្តសញ្ញាណបុគ្គលត្រូវបានបញ្ចេញជូនដល់មន្ត្រីរបស់ទីភ្នាក់ងារចូលរួម សម្រាប់គោលបំណងបំពេញទៅតាមលក្ខខណ្ឌតម្រូវនៃ Part B នៃ IDEA។ ប៉ុន្តែការយល់ព្រមរបស់អ្នក ឬការយល់ព្រមរបស់កូនអ្នកប្រសិនបើពួកគេឈានដល់អាយុជានីតិជន ត្រូវតែបានទទួល មុនពេលដែលព័ត៌មានសម្គាល់អត្តសញ្ញាណបុគ្គលត្រូវបានបញ្ចេញទៅឲ្យមន្ត្រីរបស់ទីភ្នាក់ងារចូលរួម ដែលបានផ្តល់ ឬបង់សេវាផ្លាស់ប្តូរ។ លើសពីនេះ ប្រសិនបើកូនអ្នករៀនសាលាឯកជន ការយល់ព្រមរបស់អ្នកត្រូវតែបានទទួល មុនពេលដែលព័ត៌មានសម្គាល់អត្តសញ្ញាណបុគ្គលណាមួយអំពីកូនអ្នកត្រូវបានបញ្ចេញឲ្យ រវាងមន្ត្រីនៅក្នុងស្រុករដ្ឋបាលសាលាដែលសាលាឯកជននោះស្ថិតនៅ និងមន្ត្រីនៅក្នុងស្រុករដ្ឋបាលសាលាដែលកូនអ្នករស់នៅ ប្រសិនបើអ្នកមិនមានគម្រោងចង់ចុះឈ្មោះកូនអ្នកនៅក្នុងស្រុករដ្ឋបាលសាលាដែលអ្នករស់នៅ។

## កិច្ចការពារព័ត៌មានអត្តសញ្ញាណផ្ទាល់ខ្លួន

**34 CFR §300.623; WAC 392-172A-05230**

ស្រុករដ្ឋបាលសាលារបស់លោកអ្នក ចាំបាច់ត្រូវការពារការសម្ងាត់នៃព័ត៌មានអត្តសញ្ញាណផ្ទាល់ខ្លួននៅក្នុងដំណាក់កាលប្រមូល រក្សាទុក បង្ហាញ និងបំផ្លាញ។ មន្ត្រីម្នាក់នៅស្រុករដ្ឋបាលសាលាចាំបាច់ត្រូវទទួលខុសត្រូវលើការធានានូវការសម្ងាត់នៃរាល់ព័ត៌មានអត្តសញ្ញាណផ្ទាល់ខ្លួន។ បុគ្គលទាំងអស់ដែលប្រមូល ឬប្រើព័ត៌មានអត្តសញ្ញាណផ្ទាល់ខ្លួនចាំបាច់ត្រូវទទួលការបណ្តុះបណ្តាល ឬការបង្ហាត់បង្រៀន ពាក់ព័ន្ធនឹងការសម្ងាត់ក្រោម Part B នៃ IDEA និង FERPA ។

ស្រុករដ្ឋបាលសាលានីមួយៗចាំបាច់រក្សាទុក សម្រាប់ការត្រួតពិនិត្យសាធារណៈ នូវបញ្ជីបច្ចុប្បន្ននៃឈ្មោះ និងមុខតំណែងរបស់និយោជិតទាំងឡាយណាក្នុងទីភ្នាក់ងារដែលអាចទទួលបានព័ត៌មានអត្តសញ្ញាណផ្ទាល់ខ្លួន។

## ការបំផ្លាញ ការឃោត់ទុក និងការរក្សាទុកព័ត៌មាន

### 34 CFR §300.624; WAC 392-172A-05235

ស្រុករដ្ឋបាលសាលារបស់អ្នកចាំបាច់ត្រូវជូនដំណឹងដល់អ្នក នៅពេលព័ត៌មានអត្តសញ្ញាណផ្ទាល់ខ្លួន ដែលត្រូវបានប្រមូល រក្សា ឬប្រើ លែងមានភាពចាំបាច់សម្រាប់ការផ្តល់សេវាអប់រំដល់កូនរបស់អ្នក។

នៅពេលលែងមានភាពចាំបាច់ ព័ត៌មានចាំបាច់ត្រូវបំផ្លាញចោលតាមការស្នើសុំរបស់អ្នក។ ក៏ប៉ុន្តែ កំណត់ត្រាអចិន្ត្រៃយ៍នៃឈ្មោះ អាសយដ្ឋាន និងលេខទូរស័ព្ទរបស់កូនអ្នក និន្ទេស កំណត់ត្រាវត្តមាន មុខវិជ្ជាដែលបានចូលរៀន កម្រិតថ្នាក់ដែលបានបំពេញ និងឆ្នាំដែលបានរៀនចប់របស់គាត់ អាចត្រូវបានរក្សាទុកដោយគ្មានពេលកំណត់។

ច្បាប់រដ្ឋស្តីពីការឃោត់ទុកកំណត់ត្រាមានចែងក្នុងជំពូក 40.14 RCW ។ នីតិវិធីសម្រាប់កំណត់រយៈពេលដែលស្រុករដ្ឋបាលមួយចាំបាច់ត្រូវឃោត់ទុកកំណត់ត្រាត្រូវបានបោះផ្សាយដោយ នាយកដ្ឋានគ្រប់គ្រងកាលប្បវត្តិ និងកំណត់ត្រា នៃលេខាធិការដ្ឋានរដ្ឋវ៉ាស៊ីនតោន។

## នីតិវិធីដោះស្រាយវិវាទការអប់រំពិសេស

អ្នកគឺជាអ្នកចូលរួមដ៏សំខាន់ម្នាក់ក្នុងគ្រប់ទិដ្ឋភាពនៃកម្មវិធីអប់រំពិសេសរបស់កូនអ្នក។ ការចូលរួមនេះចាប់ផ្តើមពីការបញ្ជូនកូនអ្នកនាគ្រាដំបូង។ អ្នក និងស្រុករដ្ឋបាលរបស់អ្នក ត្រូវបានលើកទឹកចិត្តឲ្យធ្វើការជាមួយគ្នាដើម្បីព្យាយាមដោះស្រាយរាល់ការខ្វែងគំនិតគ្នាដែលប៉ះពាល់ដល់កម្មវិធីអប់រំពិសេសរបស់កូនអ្នក។ នៅពេលដែលអ្នក និងស្រុករដ្ឋបាលសាលារបស់អ្នកមិនអាចដោះស្រាយការខ្វែងគំនិតគ្នាបាន យើងមានជម្រើសស្រាប់ដែលមានលក្ខណៈផ្លូវការជាងសម្រាប់ដោះស្រាយវិវាទ។ ជម្រើសទាំងនេះមាន ការសម្រុះសម្រួល បណ្តឹងរបស់ពលរដ្ឋ និងសវនការនីតិវិធីត្រឹមត្រូវតាមច្បាប់ដែលមានមិនលំអៀង។

## ការសម្រុះសម្រួល

### 34 CFR § 300.506; WAC 392-172A-05060–05075

**ទូទៅ**

សេវាសម្រុះសម្រួលមានផ្តល់ជូនដោយឥតគិតថ្លៃដល់អ្នក ឬស្រុករដ្ឋបាលដើម្បីជួយដោះស្រាយបញ្ហាពាក់ព័ន្ធនឹងអត្តសញ្ញាណកម្ម ការវាយតម្លៃ ការកំណត់ទីកន្លែងអប់រំ និងការផ្តល់ជូន FAPE ដល់កូនរបស់អ្នក និងនៅរាល់ពេលដែលសវនការនីតិវិធីត្រឹមត្រូវតាមច្បាប់ ត្រូវបានសំណូមពរឲ្យធ្វើឡើង។ ការសម្រុះសម្រួលមានលក្ខណៈស្ម័គ្រចិត្ត និងមិនអាចប្រើដើម្បីច្រានចោល ឬពន្យារសិទ្ធិរបស់អ្នក ក្នុងស្នើសុំឲ្យមានសវនការនីតិវិធីត្រឹមត្រូវតាមច្បាប់ ឬច្រានចោលនូវសិទ្ធិណាមួយផ្សេងទៀតដែលផ្តល់ជូនក្រោម Part B នៃ IDEA ។ ដំណើរការសម្រុះសម្រួលត្រូវបានរៀបចំយ៉ាងទៀងទាត់នៅទីតាំងមួយដែលងាយស្រួលសម្រាប់អ្នក និងស្រុករដ្ឋបាល។

ស្រុករដ្ឋបាលសាលាអាចបង្កើតនីតិវិធីដែលផ្តល់ជូនឪពុកម្តាយដែលជ្រើសរើសមិនប្រើដំណើរការសម្រុះសម្រួល នូវឱកាសក្នុងការជួប នៅក្នុងពេលវេលា និងនៅទីតាំងមួយដែលងាយស្រួលសម្រាប់អ្នក ជាមួយនឹងភាគីគ្មានភាពលំអៀង ៖

1. ដែលស្ថិតក្រោមកិច្ចសន្យាជាមួយនឹងស្ថាប័នដោះស្រាយវិវាទផ្សេងទៀតដែលសមស្រប ឬមជ្ឈមណ្ឌលបណ្តុះបណ្តាល និងព័ត៌មានឪពុកម្តាយ ឬមជ្ឈមណ្ឌលធនធានឪពុកម្តាយក្នុងសហគមន៍ ក្នុងរដ្ឋ **<u>និង</u>**
2. ដែលនឹងធ្វើការពន្យល់ប្រាប់ពីអត្ថប្រយោជន៍ និងលើកទឹកចិត្តអ្នកឲ្យប្រើដំណើរការសម្រុះសម្រួល ។

## <u>ភាពមិនលំអៀងនៃអ្នកសម្របសម្រួល</u>

ការសម្របសម្រួលត្រូវបានធ្វើឡើងដោយបុគ្គលដែលមានសមត្ថភាព មិនលំអៀង និងឆ្លងកាត់ការបណ្តុះបណ្តាលអំពីបច្ចេកទេសសម្រុះសម្រួលប្រកបដោយប្រសិទ្ធភាព។ បុគ្គលនោះចាំបាច់ត្រូវមានចំណេះដឹងច្បាប់ និងបទបញ្ញាពាក់ព័ន្ធនឹងការផ្តល់ការអប់រំពិសេស និងសេវាពាក់ព័ន្ធផងដែរ។ OSPI ចុះកិច្ចសន្យាជាមួយនឹងទីភ្នាក់ងារខាងក្រៅដើម្បីធ្វើការសម្រុះសម្រួល។ ទីភ្នាក់ងារនោះជាអ្នករក្សាបញ្ជីឈ្មោះអ្នកសម្រុះសម្រួល។ អ្នកសម្រុះសម្រួលត្រូវបានបែងចែកការងារឈរលើមូលដ្ឋានព្រាវវិលជុំ ឬមូលដ្ឋានមិនលំអៀងផ្សេងទៀត។ អ្នកសម្រុះសម្រួល (១) អាចមិនមែនជានិយោជិតនៃ OSPI ស្រុករដ្ឋបាល ឬទីភ្នាក់ងាររដ្ឋផ្សេងទៀតដែលកំពុងផ្តល់សេវាផ្ទាល់ដល់កុមារដែលជាកម្មវត្ថុនៃដំណើរការសម្រុះសម្រួល និង (២) អាចគ្មានទំនាស់ផលប្រយោជន៍ផ្ទាល់ខ្លួន ឬវិជ្ជាជីវៈ។ ដំណើរការសម្រុះសម្រួលត្រូវបានរៀបចំយ៉ាងទៀងទាត់នៅទីតាំងដែលងាយស្រួលសម្រាប់អ្នក និងស្រុករដ្ឋបាល។

### កិច្ចព្រមព្រៀងធ្វើឡើងក្នុងដំណើរការសម្រុះសម្រួល

ប្រសិនបើអ្នក និងស្រុករដ្ឋបាលមានការព្រមព្រៀងគ្នា ការព្រមព្រៀងនោះចាំបាច់ត្រូវរៀបចំជាកិច្ចព្រមព្រៀងសម្រុះសម្រួលជាលាយលក្ខណ៍អក្សរដែលត្រូវចុះហត្ថលេខាដោយអ្នក និងតំណាងនៃស្រុករដ្ឋបាលដែលត្រូវបានផ្តល់សិទ្ធិឲ្យចុះកិច្ចព្រមព្រៀងភ្ជាប់កាតព្វកិច្ចផ្លូវច្បាប់។ កិច្ចពិភាក្សាក្នុងដំណើរការសម្រុះសម្រួល ត្រូវរក្សាការសម្ងាត់ និងមិនអាចត្រូវបានប្រើជាភ័ស្តុតាងក្នុងសវនការនីតិវិធីត្រឹមត្រូវតាមច្បាប់ណាមួយ ឬនីតិវិធីស៊ីវិលណាមួយនៃតុលាការសហព័ន្ធ ឬតុលាការរដ្ឋវ៉ាស៊ីនតោនឡើយ។ ប្រការនេះចាំបាច់ត្រូវចែងក្នុងកិច្ចព្រមព្រៀងលាយលក្ខណ៍អក្សរ។ ក៏ប៉ុន្តែ កិច្ច-ព្រមព្រៀងសម្រុះសម្រួល មិនអាចប្រើជាភ័ស្តុតាងឡើយ។ កិច្ចព្រមព្រៀងសម្រុះសម្រួលភ្ជាប់កាតព្វកិច្ចផ្លូវច្បាប់ និងអាចអនុវត្តបានក្នុងដែនសមត្ថកិច្ចនៃតុលាការរដ្ឋណាមួយ ឬដោយតុលាការតំបន់ នៃសហរដ្ឋអាមេរិក។

## ភាពខុសគ្នារវាងការស៊ើបអង្កេត និងសវនការនីតិវិធីត្រឹមត្រូវតាមច្បាប់ស្តីពីបណ្តឹងការអប់រំពិសេស របស់ពលរដ្ឋ

បទបញ្ញានៃ Part B នៃ IDEA មាននីតិវិធីខុសៗគ្នាសម្រាប់បណ្តឹងរដ្ឋ (បណ្តឹងពលរដ្ឋ) និងសវនការនីតិវិធីត្រឹមត្រូវតាមច្បាប់។ បណ្តឹងពលរដ្ឋមួយអាចត្រូវបានដាក់ជូន OSPI ដោយបុគ្គល ឬស្ថាប័នមួយដែលធ្វើការចោទប្រកាន់ស្រុករដ្ឋបាលសាលា OSPI ឬទីភ្នាក់ងារសាធារណៈណាមួយផ្សេងទៀតដែលបានរំលោភទៅលើលក្ខខណ្ឌតម្រូវក្នុង Part B វិធានសហព័ន្ធដែលមានក្នុង 34 CFR  Part 300 ឬ បទបញ្ញារដ្ឋសម្រាប់អនុវត្ត Part B នៃ IDEA។ បណ្តឹងពលរដ្ឋត្រូវបានស៊ើបអង្កេតដោយ OSPI ផ្អែក តាមព័ត៌មានអំពីការរំលោភបំពានដែលផ្តល់ជូនដោយបុគ្គលដាក់ពាក្យបណ្តឹង និងស្រុករដ្ឋបាលសាលា ឬទីភ្នាក់ងារផ្សេងទៀតដែលឆ្លើយតបទៅនឹងបណ្តឹង។ បណ្តឹងពលរដ្ឋចាំបាច់ត្រូវដាក់ក្នុងរយៈពេលមួយឆ្នាំក្រោយការរំលោភដែលត្រូវបានចោទប្រកាន់នោះ។

សំណើសុំសវនការនីតិវិធីត្រឹមត្រូវតាមច្បាប់អាចត្រូវបានដាក់ដោយអ្នកឬស្រុករដ្ឋបាលសាលារបស់អ្នកចំពោះបញ្ហាណាមួយពាក់ព័ន្ធនឹងអត្តសញ្ញាណកម្ម ការវាយតម្លៃ ឬការកំណត់ទីតាំងអប់រំកូនរបស់អ្នក ឬការផ្តល់ការអប់រំសាធារណៈសមរម្យដោយឥតគិតថ្លៃ (FAPE)ដល់កូនអ្នកតែប៉ុណ្ណោះ។ សវនការនីតិវិធីត្រឹមត្រូវតាមច្បាប់ត្រូវធ្វើឡើងដោយចៅក្រមច្បាប់រដ្ឋបាល(ALJ) ដែលបម្រើការងារជូនការិយាល័យសវនការរដ្ឋបាល ដែលជាទីភ្នាក់ងាររដ្ឋឯករាជ្យ។ សវនការនីតិវិធីត្រឹមត្រូវតាមច្បាប់ជាទូទៅ រួមមានការផ្តល់សក្ខីភាពដោយសាក្សី និងការបង្ហាញភ័ស្តុតាង។ សំណើសុំធ្វើសវនការ

នីតិវិធីត្រឹមត្រូវតាមច្បាប់ចាំបាច់ត្រូវដាក់ក្នុងរយៈពេលពីរឆ្នាំក្រោយការរំលោភដែលត្រូវបានចោទប្រកាន់ (ករណីលើកលែងចំពោះការបង្ហាញព័ត៌មានខុស ឬការឃាត់ទុកព័ត៌មាន។)

ពេលវេលា និងនីតិវិធីសម្រាប់បណ្ដឹងពលរដ្ឋ និងសវនការនីតិវិធីត្រឹមត្រូវតាមច្បាប់ត្រូវបានពន្យល់នៅខាងក្រោម។

## <u>នីតិវិធីសម្រាប់បណ្ដឹងពលរដ្ឋ</u>

### <u>34 CFR §§300.151 – 300.153; WAC 392-172A-05025–05045</u>

OSPI មាននីតិវិធីសម្រាប់ដោះស្រាយបណ្ដឹងរដ្ឋ។ នីតិវិធីទាំងនោះមានបញ្ជាក់ក្នុងបទបញ្ជារដ្ឋ និងព័ត៌មានស្ដីពីបណ្ដឹងរដ្ឋត្រូវបានរក្សាទុកនៅលើវែបសាយត៍។

ប្រសិនបើអ្នក បុគ្គល ស្ថាប័នណាមួយ ជឿជាក់ថាស្រុករដ្ឋបាលមួយ OSPI ឬស្ថាប័នអប់រំណាមួយផ្សេងទៀតដែលស្ថិតក្រោមការគ្រប់គ្រងរបស់ IDEA បានរំលោភទៅលើ Part B នៃ IDEA បទបញ្ជាអនុវត្ត Part B ឬបទបញ្ជារដ្ឋពាក់ព័ន្ធ អ្នកអាចដាក់ពាក្យបណ្ដឹងជាលាយលក្ខណ៍អក្សរនៅ Office of Superintendent of Public Instruction (OSPI) , Special Education, PO Box 47200, Olympia, WA 98504-7200។ អ្នកចាំបាច់ត្រូវផ្ដល់សំណៅចម្លងមួយច្បាប់នៃពាក្យបណ្ដឹងនោះដល់ស្រុករដ្ឋបាលសាលា ឬទីភ្នាក់ងារផ្សេងទៀតដែលអ្នកដាក់ពាក្យបណ្ដឹងប្រឆាំង។

### <u>ការដាក់ពាក្យបណ្ដឹង</u>

ពាក្យបណ្ដឹងចាំបាច់ត្រូវចុះហត្ថលេខាដោយអ្នក ឬបុគ្គល ឬស្ថាប័នដែលជាអ្នកដាក់ពាក្យបណ្ដឹង ហើយចាំបាច់ត្រូវមានព័ត៌មានដូចខាងក្រោម ៖

- ការថ្លែងថាស្រុករដ្ឋបាល ឬទីភ្នាក់ងារដទៃទៀតបានរំលោភទៅលើលក្ខខណ្ឌតម្រូវមួយនៃ Part B នៃ IDEA បទបញ្ជាអនុវត្ត Part B ច្បាប់រដ្ឋ ឬបទបញ្ជាពាក់ព័ន្ធ ឬការថ្លែងថាស្រុករដ្ឋបាល ឬទីភ្នាក់ងារដទៃទៀត មិនបានអនុវត្តការសម្រុះសម្រួល ឬកិច្ចព្រមព្រៀងដោះស្រាយ។
- ឈ្មោះ និងអាសយដ្ឋាននៃស្រុករដ្ឋបាល ឬទីភ្នាល់ងារដទៃទៀត។
- ឈ្មោះសិស្ស ប្រសិនបើពាក្យបណ្ដឹងមានភាពជាក់លាក់ចំពោះសិស្សម្នាក់ និងព័ត៌មានទំនាក់ទំនង ប្រសិនបើសិស្សនោះគ្មានទីជម្រក។
- ការរៀបរាប់អំពីបញ្ហាដោយផ្ដល់ជូននូវការពិតជាក់លាក់។

- ការស្នើឡើងនូវដំណោះស្រាយបញ្ហាតាមព័ត៌មានអ្នកមាន និងបានដឹង នៅពេលដែលអ្នកដាក់ពាក្យបណ្ដឹង <u>**និង**</u>
- ឈ្មោះ អាសយដ្ឋាន និងលេខទូរស័ព្ទរបស់អ្នក។

ការរំលោភមិនអាចកើតឡើងក្នុងរយៈពេលច្រើនជាង <u>មួយឆ្នាំ</u> មុនកាលបរិច្ឆេទដែលពាក្យបណ្ដឹងត្រូវបានទទួលយកឡើយ។

OSPI បានបង្កើតទម្រង់ជំនួសមួយដែលអ្នកអាចប្រើដើម្បីដាក់ពាក្យបណ្ដឹង។ ទម្រង់នេះមានផ្ដល់ជូននៅលើទំព័រវេបសាយត៍ការអប់រំពិសេសរបស់ OSPI។ អ្នកមិនត្រូវបានតម្រូវឲ្យប្រើទម្រង់នេះឡើយ។

## <u>ការស៊ើបអង្កេតពីបណ្ដឹង</u>

OSPI ចាំបាច់ត្រូវស៊ើបអង្កេត និងចេញសេចក្ដីសម្រេចជាលាយលក្ខណ៍អក្សរក្នុងរយៈពេល៦០ថ្ងៃនៃថ្ងៃប្រក្រតិទិន ក្រោយពេលទទួលបានពាក្យបណ្ដឹង លើកលែងមានហេតុផលសមស្របសម្រាប់ការពន្យារពេល។ ក្នុងរយៈពេល៦០ថ្ងៃនេះ OSPI (១) តម្រូវឲ្យស្រុករដ្ឋបាលផ្ដល់ការឆ្លើយតបចំពោះបណ្ដឹង (២) ផ្ដល់ជូនអ្នក ឬដើមបណ្ដឹងនូវឱកាសដាក់ជូននូវព័ត៌មានបន្ថែមអំពីការចោទប្រកាន់ ក្នុងពាក្យបណ្ដឹង (៣) អាចធ្វើការស៊ើបអង្កេតឯករាជ្យនៅនឹងកន្លែង ប្រសិនបើ OSPI យល់ឃើញថាវាមានភាពចាំបាច់ និង (៤) ពិនិត្យឡើងវិញនូវព័ត៌មានពាក់ព័ន្ធទាំងអស់ ហើយធ្វើការកំណត់ឯករាជ្យថាតើស្រុករដ្ឋបាល ឬទីភ្នាក់ងារដទៃទៀតកំពុងរំលោភទៅលើលក្ខខណ្ឌតម្រូវពាក់ព័ន្ធទៅនឹង Part B នៃ IDEA ឬយ៉ាងណា។

## <u>ការស៊ើបអង្កេត ការពន្យារពេល សេចក្ដីសម្រេចជាលាយលក្ខណ៍អក្សរ</u>

រយៈពេលកំណត់៦០ថ្ងៃអាចត្រូវបានពន្យារបន្តតែក្នុងករណី ៖ (១) កាលៈទេសៈលើកលែងពាក់ព័ន្ធនឹងបណ្ដឹងជាក់លាក់មួយ <u>**ឬ**</u> (២) អ្នក និងស្រុករដ្ឋបាលរបស់អ្នកយល់ព្រមដោយស្ម័គ្រចិត្តជាលាយលក្ខណ៍អក្សរធ្វើការពន្យារពេលដោះស្រាយបណ្ដឹង តាមរយៈការសម្រុះសម្រួល ឬវិធីផ្សេងទៀត ដើម្បីដោះស្រាយវិវាទ។

សេចក្ដីសម្រេចជាលាយលក្ខណ៍អក្សរត្រូវផ្ញើជូនអ្នក ឬបុគ្គលដាក់ពាក្យបណ្ដឹង និងទៅកាន់ស្រុក រដ្ឋបាលសាលា។ សេចក្ដីសម្រេចជាលាយលក្ខណ៍អក្សរនឹងគ្របដណ្ដប់លើការចោទប្រកាន់នីមួយៗ។ ចំពោះការចោទប្រកាន់នីមួយៗ សេចក្ដីសម្រេចជាលាយលក្ខណ៍អក្សរនឹងបញ្ជាក់ពីលទ្ធផលនៃការស្វែងរកការពិត សេចក្ដីសន្និដ្ឋាន មូលហេតុនៃសេចក្ដីសម្រេច និងវិធានការកែតម្រូវ សមហេតុផល

ណាមួយដែលត្រូវបានចាត់ទុកថាចាំបាច់ដើម្បីដោះស្រាយពាក្យបណ្តឹង ប្រសិនបើការរំលោភបានកើតឡើង។

## ឧបាស្រ័យបណ្តឹង

នៅពេល OSPI រកឃើញការរំលោភ ឬការខកខានមិនបានផ្តល់សេវាសមស្របតាមរយៈដំណើរការបណ្តឹងរបស់ខ្លួន សេចក្តីសម្រេចនឹងគ្របដណ្តប់លើ៖

1. របៀបដោះស្រាយករបដិសេធផ្តល់សេវាទាំងនោះ រួមមាន ការផ្តល់សំណងហិរញ្ញវត្ថុសមរម្យ ឬ ការ ចាត់វិធានការកែតម្រូវសមស្របផ្សេងទៀតតាមតម្រូវការរបស់សិស្ស **និង**
2. រផ្តល់យ៉ាងសមរម្យនូវសេវាអប់រំពិសេសដល់សិស្សទាំងអស់នាពេលអនាគត។

## បណ្តឹងអប់រំពិសេសរបស់ពលរដ្ឋ និងសវនការនីតិវិធីត្រឹមត្រូវតាមច្បាប់

ប្រសិនបើបណ្តឹងពលរដ្ឋមួយត្រូវបានទទួលយក ដែលជាកម្មវត្ថុនៃសនវការនីតិវិធីត្រឹមត្រូវតាមច្បាប់ ឬបណ្តឹងនោះមានបញ្ហាច្រើន ហើយបញ្ហាមួយ ឬច្រើនជាងមួយនៃបញ្ហាទាំងនោះគឺជាផ្នែកមួយនៃសវនការនីតិវិធីត្រឹមត្រូវតាមច្បាប់ OSPI ចាំបាច់ត្រូវញែកចេញ (មិនស៊ើបអង្កេត) នូវផ្នែកណាមួយ នៃបណ្តឹងដែលកំពុងត្រូវបានដោះស្រាយក្នុងសវនការនីតិវិធីត្រឹមត្រូវតាមច្បាប់ រហូតដល់ចប់សវនការ។ បញ្ហាណាមួយក្នុងបណ្តឹងដែលមិនមែនជាផ្នែកមួយនៃសកម្មភាពនីតិវិធីត្រឹមត្រូវតាមច្បាប់ ចាំបាច់ត្រូវដោះស្រាយក្នុងកាលកំណត់នៃពាក្យបណ្តឹង។

ប្រសិនបើបញ្ហាមួយដែលត្រូវបានលើកឡើងក្នុងពាក្យបណ្តឹងត្រូវបានសម្រេចរួចក្នុងសវនការ នីតិវិធីត្រឹមត្រូវតាមច្បាប់ ដែលពាក់ព័ន្ធនឹងគូភាគីដដែល សេចក្តីសម្រេចសវនការនោះត្រូវមានអានុភាពភ្ជាប់កាតព្វកិច្ច ហើយ OSPI ចាំបាច់ត្រូវជូនដំណឹងដល់ដើមបណ្តឹងថាខ្លួននឹងមិនស៊ើបអង្កេតលើបញ្ហានោះទេ។

OSPI ចាំបាច់ត្រូវដោះស្រាយបណ្តឹងដែលចោទប្រកាន់ថាស្រុករដ្ឋបាលមួយបានខកខានមិនបានអនុវត្តតាមសេចក្តីសម្រេចរបស់សវនការនីតិវិធីត្រឹមត្រូវតាមច្បាប់។

# នីតិវិធីនៃសវនាការត្រឹមត្រូវតាមផ្លូវច្បាប់

## 34 CFR §§300.507 – 300.513; WAC 392-172A-05080–05125

## ទូទៅ

អ្នក ឬស្រុករដ្ឋបាលសាលាអាចដាក់សំណើសុំសវនាការត្រឹមត្រូវតាមផ្លូវច្បាប់លើបញ្ហាណាមួយដែលពាក់ព័ន្ធនឹងអត្តសញ្ញាណកម្ម ការវាយតម្លៃ ឬការកំណត់សិទ្ធិទទួលសេវាអប់រំរបស់កូនអ្នក ឬការផ្តល់ការអប់រំសាធារណៈសមស្របដោយឥតគិតថ្លៃ (FAPE) ដល់កូនអ្នក។ ស្រុករដ្ឋបាលសាលាត្រូវតែជូនដំណឹងអ្នកពីសេវាផ្នែកច្បាប់ដោយឥតគិតថ្លៃ ឬមានតម្លៃទាបណាមួយ និងសេវាពាក់ព័ន្ធផ្សេងទៀតដែលមាននៅក្នុងតំបន់ នៅពេលដែលសំណើសុំសវនាការត្រឹមត្រូវតាមផ្លូវច្បាប់ត្រូវបានដាក់ជូន ឬនៅពេលដែលអ្នកស្នើសុំព័ត៌មាននេះ។ សម្រាប់នីតិវិធីនៃសវនាការត្រឹមត្រូវតាមផ្លូវច្បាប់ "អ្នក" រួមមានមេធាវីរបស់អ្នក ប្រសិនបើអ្នកបានជួលមេធាវីម្នាក់ ហើយ "ស្រុករដ្ឋបាលសាលា" រួមមានមេធាវីស្រុករដ្ឋបាលសាលាប្រសិនបើវាត្រូវបានតំណាងដោយមេធាវី។

## ការដាក់សំណើសុំ

ដើម្បីស្នើសុំសវនាការមួយ អ្នក ឬស្រុករដ្ឋបាលសាលាត្រូវតែដាក់សំណើសុំសវនាការត្រឹមត្រូវតាមផ្លូវច្បាប់ ទៅភាគីម្ខាងទៀត។ សំណើសុំនេះ ត្រូវមានព័ត៌មានទាំងអស់ដូចខាងក្រោម និងត្រូវរក្សាជាការសម្ងាត់។

អ្នក ឬស្រុករដ្ឋបាលសាលា មិនថានរណាម្នាក់ដាក់សំណើសុំនោះទេ ក៏ត្រូវតែផ្តល់ជូន OSPI សេវាធនធានរដ្ឋបាលនូវសំណើសុំសវនាការមួយច្បាប់តាមអាសយដ្ឋានដូចខាងក្រោម ៖

Office of Superintendent of Public Instruction
Administrative Resource Services
Old Capitol Building
PO Box 47200
Olympia, WA  98504-7200
ទូរសារ: 360-753-4201

សំណើសុំសវនាការត្រឹមត្រូវតាមផ្លូវច្បាប់ត្រូវមាន ៖

1. ឈ្មោះសិស្ស
2. អាសយដ្ឋាននៃទីលំនៅរបស់សិស្ស
3. ឈ្មោះសាលារបស់សិស្ស
4. ប្រសិនបើសិស្សជាកុមារ ឬយុវជនដែលគ្មានផ្ទះសំបែង ត្រូវផ្តល់ព័ត៌មានទំនាក់ទំនងរបស់សិស្សនោះ

5. ការបរិយាយពីសភាពនៃបញ្ហារួមមាន អង្គហេតុទាក់ទិននឹងបញ្ហា **<u>និង</u>**
6. ដំណោះស្រាយដែលបានស្នើឡើងនៃបញ្ហា ដល់កម្រិតដែលបានដឹង និងមានសម្រាប់អ្នក ឬស្រុករដ្ឋបាលសាលានៅពេលនោះ។

***<u>សេចក្តីជូនដំណឹងដែលចាំបាច់មុនសវនាការលើសំណើសុំសវនាការត្រឹមត្រូវតាមផ្លូវច្បាប់</u>***

អ្នក ឬស្រុករដ្ឋបាលសាលាមិនអាចមានសវនាការត្រឹមត្រូវតាមផ្លូវច្បាប់ រហូតទាល់តែអ្នក ឬស្រុករដ្ឋបាលសាលាដាក់សំណើសុំសវនាការត្រឹមត្រូវតាមផ្លូវច្បាប់ ជាមួយនឹងភាគីម្ខាងទៀត និងផ្តល់ OSPI នូវសំណើសុំមួយច្បាប់ដែលមានព័ត៌មានដូចបានរៀបរាប់ខាងលើ។

***<u>ភាពគ្រប់គ្រាន់នៃសំណើសុំសវនាការ</u>***

ដើម្បីឲ្យសំណើសុំសវនាការត្រឹមត្រូវតាមផ្លូវច្បាប់មានដំណើរការទៅមុខ សំណើសុំនេះ ត្រូវបានចាត់ទុកថាគ្រប់គ្រាន់។ *គ្រប់គ្រាន់* មានន័យថា សំណើសុំនេះ បំពេញទៅតាមលក្ខខណ្ឌតម្រូវនានាដែលបញ្ជាក់ខាងលើនៅក្នុងផ្នែក ***"ការដាក់សំណើសុំ"***។ សំណើសុំសវនាការត្រឹមត្រូវតាមផ្លូវច្បាប់នឹងត្រូវចាត់ទុកថា គ្រប់គ្រាន់ លុះត្រាតែភាគីដែលទទួលបានសំណើសុំសវនាការត្រឹមត្រូវតាមផ្លូវច្បាប់នោះជូនដំណឹងទៅមន្ត្រីរដ្ឋបាលសវនាការ និងភាគីម្ខាងទៀតជាលាយលក្ខណ៍អក្សរនៅក្នុងរយៈពេល15ថ្ងៃប្រតិទិនថា ភាគីទទួលជឿជាក់ថា សំណើសុំសវនាការត្រឹមត្រូវតាមផ្លូវច្បាប់គឺ មិនគ្រប់គ្រាន់។

នៅក្នុងរយៈពេលប្រាំថ្ងៃប្រតិទិនក្រោយពេលទទួលបានការជូនដំណឹងពីភាពមិនគ្រប់គ្រាន់ហើយ មន្ត្រីរដ្ឋបាលសវនាការ (ALJ) ត្រូវសម្រេចថាតើសំណើសុំសវនាការត្រឹមត្រូវតាមផ្លូវច្បាប់នេះ បំពេញទៅតាមលក្ខខណ្ឌតម្រូវដូចមានរៀបរាប់ខាងលើឬទេ ហើយជូនដំណឹងដល់អ្នក និងស្រុករដ្ឋបាលសាលាជាលាយលក្ខណ៍អក្សរភ្លាមៗ។

***<u>ការកែប្រែសំណើសុំសវនាការ</u>***

អ្នក ឬស្រុករដ្ឋបាលសាលាអាចធ្វើការកែប្រែសំណើសុំសវនាការបានតែក្នុងករណី ៖

1. ភាគីម្ខាងទៀតយល់ស្របចំពោះការកែប្រែជាលាយលក្ខណ៍អក្សរ ហើយផ្តល់ឱកាសឲ្យដោះស្រាយសំណើសុំសវនាការនេះ តាមរយៈការប្រជុំស្វែងរកដំណោះស្រាយ (ប្រសិនបើអ្នកដែលជាមាតាបិតាបានស្នើសុំសវនាការត្រឹមត្រូវតាមផ្លូវច្បាប់) ដូចមានចែងខាងក្រោម **<u>ឬ</u>**

2. មិនឲ្យលើសពីរយៈពេលប្រាំថ្ងៃមុនសវនាការត្រឹមត្រូវតាមផ្លូវច្បាប់ចាប់ផ្ដើម មន្ត្រីសវនាការផ្ដល់ការអនុញ្ញាតឲ្យធ្វើការកែប្រែ។

ប្រសិនបើអ្នកជាភាគីស្នើសុំសវនាការ ហើយអ្នកធ្វើការកែប្រែចំពោះសំណើសុំសវនាការត្រឹមត្រូវតាមផ្លូវច្បាប់ ពេលវេលាកំណត់សម្រាប់ការប្រជុំស្វែងរកដំណោះស្រាយ និងរយៈពេលសម្រាប់ដំណោះស្រាយ (មើល ៖ ***ដំណើរការនៃការដោះស្រាយ***) ចាប់ផ្ដើមម្ដងទៀតនៅកាលបរិច្ឆេទដាក់សំណើសុំដែលបានកែប្រែ ឬកាលបរិច្ឆេទដែល ALJ ទទួលសំណើសុំ។

## ការឆ្លើយតបរបស់ស្រុករដ្ឋបាលសាលាចំពោះសំណើសុំសវនាការត្រឹមត្រូវតាមផ្លូវច្បាប់

ប្រសិនបើស្រុករដ្ឋបាលសាលាមិនបានផ្ញើសេចក្ដីជូនដំណឹងជាមុនជាលាយលក្ខណ៍អក្សរឲ្យអ្នក ដូចមានចែងនៅក្នុងផ្នែកស្ដីពី ***សេចក្ដីជូនដំណឹងជាមុនជាលាយលក្ខណ៍អក្សរ*** ទាក់ទងនឹងបញ្ហាដែលមាននៅក្នុងសំណើសុំសវនាការត្រឹមត្រូវតាមផ្លូវច្បាប់របស់អ្នកទេ ក្នុងរយៈពេល 10ថ្ងៃប្រតិទិនក្រោយពេលទទួលបានសំណើសុំសវនាការត្រឹមត្រូវតាមផ្លូវច្បាប់ ស្រុករដ្ឋបាលសាលាត្រូវតែផ្ញើជូនអ្នកនូវការឆ្លើយតបមួយដែលមាន ៖

1. ការពន្យល់ពីមូលហេតុដែលស្រុករដ្ឋបាលសាលាបានស្នើ ឬបដិសេធមិនចាត់វិធានការដែលបានលើកឡើងនៅក្នុងសំណើសុំសវនាការត្រឹមត្រូវតាមផ្លូវច្បាប់។
2. ការបរិយាយពីជម្រើសផ្សេងទៀតដែលក្រុម IEP របស់កូនអ្នកបានពិចារណា និងពីមូលហេតុដែលជម្រើសទាំងនោះត្រូវបានបដិសេធ។
3. ការបរិយាយពីនីតិវិធីក្នុងការវាយតម្លៃ ប៉ាន់ប្រមាណ ឯកសារ ឬរបាយការណ៍នីមួយៗ ដែលស្រុករដ្ឋបាលសាលាប្រើប្រាស់ជាមូលដ្ឋានសម្រាប់វិធានការដែលបានស្នើ ឬបដិសេធ **និង**
4. ការបរិយាយពីកត្តាផ្សេងទៀតដែលពាក់ព័ន្ធនឹងវិធានការដែលបានស្នើ ឬបដិសេធរបស់ស្រុករដ្ឋបាលសាលា។

ស្រុករដ្ឋបាលសាលានៅតែអាចអះអាងថា សំណើសុំសវនាការត្រឹមត្រូវតាមផ្លូវច្បាប់របស់អ្នកមិនគ្រប់គ្រាន់ ទោះបីជាវាផ្ដល់ឲ្យអ្នកនូវព័ត៌មាននៅក្នុងចំណុចទី 1-4 ខាងលើក៏ដោយ។

## ការឆ្លើយតបរបស់ភាគីម្ខាងទៀតចំពោះសំណើសុំសវនាការត្រឹមត្រូវតាមផ្លូវច្បាប់

លើកលែងចំពោះសវនាការត្រឹមត្រូវតាមផ្លូវច្បាប់ដែលមានលក្ខណៈប្រញាប់សម្រាប់វិន័យ ដូចមានពិភាក្សានៅក្នុងផ្នែកខាងក្រោមស្ដីពី ***នីតិវិធីនៃសវនាការត្រឹមត្រូវតាមផ្លូវច្បាប់សម្រាប់វិន័យ*** ភាគីទទួល

សំណើសុំសវនាការត្រឹមត្រូវតាមផ្លូវច្បាប់ត្រូវផ្ញើឲ្យភាគីម្ខាងទៀត នូវការឆ្លើយតបដែលបញ្ជាក់ជាក់លាក់ពីបញ្ហានៅក្នុងសំណើសុំ ក្នុងរយៈពេល10ថ្ងៃប្រតិទិនក្រោយពេលទទួលបានសំណើសុំនេះ។ គាគីនីមួយៗនៅតែអាចអះអាងថា សំណើសុំសវនាការត្រឹមត្រូវតាមផ្លូវច្បាប់មិនគ្រប់គ្រាន់ដដែល។

## ពាក្យសុំគំរូ

### 34 CFR §300.509; WAC 392-172A-05085

OSPI បានបង្កើតពាក្យសុំគំរូនៃសវនាការត្រឹមត្រូវតាមផ្លូវច្បាប់មួយ ដើម្បីជួយអ្នកក្នុងការបំពេញពាក្យស្នើសុំសម្រាប់សវនាការត្រឹមត្រូវតាមផ្លូវច្បាប់។ ពាក្យសុំនេះ អាចស្វែងរកបាននៅលើគេហទំព័រខាងក្រោម ៖

http://www.k12.wa.us/ProfPractices/adminresources/forms.aspx
http://www.k12.wa.us/SpecialEd/DisputeResolution/DueProcess.aspx

អ្នកមិនតម្រូវឲ្យប្រើប្រាស់ពាក្យសុំនេះឡើយ។ ប៉ុន្តែសិទ្ធិរបស់អ្នកក្នុងការទទួលបានសវនាការត្រឹមត្រូវតាមផ្លូវច្បាប់អាចបដិសេធ ឬពន្យារពេលបាន ប្រសិនបើសំណើសុំសវនាការត្រឹមត្រូវតាមផ្លូវច្បាប់នេះមិនបញ្ចូលព័ត៌មានដែលត្រូវការទាំងអស់។ អ្នកក៏អាចទទួលបានពាក្យស្នើសុំសវនាការមួយច្បាប់ពីនាយកដ្ឋានអប់រំពិសេសរបស់ស្រុករដ្ឋបាលសាលាអ្នកផងដែរ។

## ការកំណត់សិទ្ធិទទួលសេវាអប់រំរបស់សិស្សក្នុងពេលរង់ចាំសវនាការត្រឹមត្រូវតាមផ្លូវច្បាប់

### 34 CFR §300.518; WAC 392-172A-05125

លើកលែងតែមានការចែងនៅក្នុងផ្នែកស្តីពី ***នីតិវិធីនៅពេលដាក់វិន័យសិស្សដែលមានពិការភាព*** នៅពេលដែលសំណើសុំសវនាការត្រឹមត្រូវតាមផ្លូវច្បាប់ត្រូវបានបញ្ជូនទៅឲ្យភាគីម្ខាងទៀតក្នុងរយៈពេលនៃដំណើរការដោះស្រាយ និងអំឡុងពេលរង់ចាំសេចក្តីសម្រេចរបស់សវនាការមិនលំអៀងត្រឹមត្រូវតាមផ្លូវច្បាប់ ឬនីតិវិធីតុលាការណាមួយដែលពាក់ព័ន្ធនឹងបណ្តឹងតវ៉ាលើសេចក្តីសម្រេចរបស់ ALJ កូនអ្នកត្រូវតែស្ថិតនៅក្នុងការកំណត់សិទ្ធិទទួលសេវាអប់រំបច្ចុប្បន្នរបស់ពួកគេ លុះត្រាតែអ្នក ឬស្រុករដ្ឋបាលសាលាព្រមព្រៀងគ្នាផ្សេងពីនេះ។

ដោយមានការយល់ស្របពីអ្នក កូនអ្នកត្រូវតែដាក់នៅក្នុងកម្មវិធីសាលារដ្ឋទូទៅ រហូតដល់បញ្ចប់ការជំនុំជម្រះទាំងអស់នេះ ប្រសិនបើសំណើសុំសវនាការត្រឹមត្រូវតាមផ្លូវច្បាប់មានពាក់ព័ន្ធនឹងពាក្យសុំចុះឈ្មោះដំបូងទៅក្នុងសាលារដ្ឋ។

ប្រសិនបើសំណើសុំសវនាការត្រឹមត្រូវតាមផ្លូវច្បាប់ពាក់ព័ន្ធនឹងការផ្តល់សេវាដំបូងក្រោម Part B នៃ IDEA សម្រាប់កូនអ្នកដែលកំពុងបញ្ជូនពីសេវាកម្មនៅក្រោម Part C នៃ IDEA ទៅ Part B នៃ IDEA និងដែលលែងមានសិទ្ធិទទួលបានសេវាកម្ម Part C ដោយសារតែកូនអ្នកមានអាយុបីឆ្នាំនោះ ស្រុករដ្ឋបាលសាលាមិនតម្រូវឲ្យផ្តល់សេវាកម្ម Part C ដែលកូនអ្នកកំពុងទទួលបាននោះទេ។ ប្រសិនបើកូនអ្នកមានសិទ្ធិទទួលបានសេវាកម្មក្រោម Part B នៃ IDEA ហើយអ្នកយល់ស្របឲ្យកូនរបស់អ្នកទទួលបានការអប់រំពិសេស និងសេវាកម្មពាក់ព័ន្ធជាលើកដំបូង ដោយរង់ចាំស្តាប់លទ្ធផលជំនុំជម្រះ នោះស្រុករដ្ឋបាលសាលាត្រូវតែផ្តល់ការអប់រំពិសេស និងសេវាពាក់ព័ន្ធទាំងនោះ ដែលមិនស្ថិតនៅក្នុងវិវាទរវាងអ្នក និងស្រុករដ្ឋបាលសាលា។

ប្រសិនបើ ALJ ឈានដល់ការសម្រេចថា ការកែប្រែការកំណត់សិទ្ធិទទួលសេវាអប់រំមានលក្ខណៈសមស្រប សេចក្តីសម្រេចទាក់ទិននឹងការកំណត់សិទ្ធិនោះ ត្រូវតែចាត់ទុកជាការព្រមព្រៀងគ្នារវាងអ្នក និងស្រុករដ្ឋបាលសាលាសម្រាប់គោលបំណងកំណត់សិទ្ធិទទួលសេវាអប់រំ ក្នុងអំឡុងពេលនៃបណ្តឹងតវ៉ាណាមួយលើសេចក្តីសម្រេចត្រឹមត្រូវតាមផ្លូវច្បាប់។

## ដំណើរការដោះស្រាយ

## 34 CFR §300.510; WAC 392-172A-05090

### ការប្រជុំស្វែងរកដំណោះស្រាយ

នៅក្នុងរយៈពេល 15ថ្ងៃក្រោយពេលដែលអ្នកបានដាក់សំណើសុំសវនាការត្រឹមត្រូវតាមផ្លូវច្បាប់របស់អ្នកជាមួយនឹងស្រុករដ្ឋបាលសាលា និង OSPI ស្រុករដ្ឋបាលសាលាត្រូវតែកោះប្រជុំជាមួយអ្នក និងសមាជិកពាក់ព័ន្ធ ឬសមាជិកនៃក្រុម IEP ដែលមានចំណេះដឹងជាក់លាក់ពីអង្គហេតុដែលបានកំណត់នៅក្នុងសំណើសុំសវនាការត្រឹមត្រូវតាមផ្លូវច្បាប់របស់អ្នក។ កិច្ចប្រជុំនេះ ត្រូវតែធ្វើឡើងមុនពេលដែលពេលកំណត់នៃសវនាការត្រឹមត្រូវតាមផ្លូវច្បាប់ចាប់ផ្ដើម លុះត្រាតែអ្នក និងស្រុករដ្ឋបាលសាលាឯកភាពធ្វើការសម្រុះសម្រួល ឬឯកភាពបោះបង់ការប្រជុំស្វែងរកដំណោះស្រាយ។ ការប្រជុំនេះ ៖

1. ត្រូវតែមានតំណាងស្រុករដ្ឋបាលសាលាម្នាក់ដែលមានអំណាចក្នុងការធ្វើសេចក្ដីសម្រេចជំនួសឲ្យស្រុករដ្ឋបាលសាលា **និង**
2. មិនអាចមានមេធាវីស្រុករដ្ឋបាលសាលា លុះត្រាតែអ្នកត្រូវបានអមដំណើរដោយមេធាវី។

គោលបំណងនៃការប្រជុំគឺ សម្រាប់ឲ្យអ្នកពិភាក្សាពីសំណើសុំសវនាការត្រឹមត្រូវតាមផ្លូវច្បាប់របស់អ្នក និងពីអង្គហេតុដែលបង្កើតជាមូលដ្ឋាននៃសំណើសុំ ដើម្បីឲ្យស្រុករដ្ឋបាលសាលាមានឱកាសដោះស្រាយវិវាទ។ អ្នក និងស្រុករដ្ឋបាលសាលាកំណត់ពីសមាជិកពាក់ព័ន្ធនៃក្រុម IEP សម្រាប់ចូលរួមនៅក្នុងការប្រជុំស្វែងរកដំណោះស្រាយ។

ការប្រជុំស្វែងរកដំណោះស្រាយមិនចាំបាច់មាននោះទេ ប្រសិនបើ ៖

1. អ្នក និងស្រុករដ្ឋបាលសាលាព្រមព្រៀងគ្នាជាលាយលក្ខណ៍អក្សរ ក្នុងការបះបង់ការប្រជុំនេះ **ឬ**
2. អ្នក និងស្រុករដ្ឋបាលសាលាព្រមព្រៀងគ្នាប្រើប្រាស់ដំណើរការសម្រុះសម្រួល ដូចមានចែងនៅក្នុងផ្នែក ***ការសម្រុះសម្រួល***។

### រយៈពេលរកដោះស្រាយ

ប្រសិនបើស្រុករដ្ឋបាលសាលាមិនបានដោះស្រាយសំណើសុំសវនាការត្រឹមត្រូវតាមផ្លូវច្បាប់ ទៅតាមការចង់បានរបស់អ្នក នៅក្នុងរយៈពេល 30ថ្ងៃប្រតិទិនក្រោយពេលដែលអ្នកបានដាក់សំណើសុំនេះទៅស្រុករដ្ឋបាលសាលា និង OSPI សវនាការត្រឹមត្រូវតាមផ្លូវច្បាប់អាចនឹងកើតឡើង។

រយៈពេលកំណត់ 45ថ្ងៃប្រតិទិនសម្រាប់ការចេញសេចក្តីសម្រេចចុងក្រោយ ចាប់ផ្តើមនៅពេលបញ្ចប់រយៈពេលរកដំណោះស្រាយ 30ថ្ងៃប្រតិទិន ដោយមានការលើកលែងខ្លះសម្រាប់ការកែសម្រួលដែលធ្វើឡើងចំពោះរយៈពេលរកដំណោះស្រាយ 30ថ្ងៃប្រតិទិននេះ ដូចមានចែងខាងក្រោម។

លុះត្រាតែអ្នក និងស្រុករដ្ឋបាលសាលាបានព្រមព្រៀងគ្នាបោះបង់ដំណើរការដោះស្រាយ ឬប្រើប្រាស់ការសម្រុះសម្រួល ការខកខានមិនបានចូលរួមនៅក្នុងការប្រជុំស្វែងរកដំណោះស្រាយរបស់អ្នក នឹងពន្យារពេលដល់រយៈពេលកំណត់នៃដំណើរការដោះស្រាយ និងសវនាការត្រឹមត្រូវតាមផ្លូវច្បាប់ទាល់តែអ្នកព្រមព្រៀងចូលរួមនៅក្នុងការប្រជុំ។

ប្រសិនបើស្រុករដ្ឋបាលសាលាមិនអាចទទួលបានការចូលរួមរបស់អ្នកនៅក្នុងការប្រជុំស្វែងរកដំណោះស្រាយបន្ទាប់ពីបានខិតខំប្រឹងប្រែងសមស្រប និងកត់ត្រាការប្រឹងប្រែងទាំងនេះ ស្រុករដ្ឋបាលសាលាអាចនឹងស្នើសុំឲ្យ ALJ ច្រានចោលសំណើសុំសវនាការត្រឹមត្រូវតាមផ្លូវច្បាប់របស់អ្នក នៅពេលបញ្ចប់រយៈពេលរកដំណោះស្រាយ 30ថ្ងៃប្រតិទិន។ ស្រុករដ្ឋបាលសាលាត្រូវតែកត់ត្រាទុកនូវការប៉ុនប៉ងរបស់ខ្លួនក្នុងការរៀបចំពេល និងទីកន្លែងដែលបានឯកភាពគ្នាទៅវិញទៅមកសម្រាប់ការប្រជុំស្វែងរកដំណោះស្រាយ។ ការកត់ត្រានេះ រួមមានការប៉ុនប៉ងដូចជា ៖

1. កំណត់ត្រាពិស្តារនៃការហៅទូរស័ព្ទដែលបានធ្វើឡើង ឬប៉ុនប៉ងធ្វើ និងពីលទ្ធផលនៃការហៅទាំងនេះ
2. ច្បាប់ចតចម្លងនៃលិខិតឆ្លើយឆ្លងដែលបានផ្ញើមកកាន់អ្នក និងការឆ្លើយតបដែលបានទទួល **<u>និង</u>**
3. កំណត់ត្រាពិស្តារនៃការមកលេងផ្ទះឬកន្លែងធ្វើការអ្នកនិងពីលទ្ធផលនានានៃការមកលេងទាំងនេះ។

ប្រសិនបើស្រុករដ្ឋបាលសាលាខកខានមិនបានរៀបចំការប្រជុំស្វែងរកដំណោះស្រាយនៅក្នុងរយៈពេល 15ថ្ងៃប្រតិទិនក្រោយពេលដែលអ្នកបានផ្តល់សំណើសុំសវនាការត្រឹមត្រូវតាមផ្លូវច្បាប់ ដល់ស្រុករដ្ឋបាលសាលា និង OSPI របស់អ្នកហើយ **<u>ឬ</u>**ស្រុករដ្ឋបាលសាលាខកខានមិនបានចូលរួមនៅក្នុងការប្រជុំស្វែងរកដំណោះស្រាយ អ្នកអាចស្នើសុំឲ្យ ALJ ចេញដីកាបង្គាប់ឲ្យចាប់ផ្តើមរយៈពេលកំណត់ 45ថ្ងៃប្រតិទិននៃសវនាការត្រឹមត្រូវតាមផ្លូវច្បាប់។

## ការកែសម្រួលចំពោះរយៈពេលរកដំណោះស្រាយ 30ថ្ងៃប្រតិទិន

ប្រសិនបើអ្នក និងស្រុករដ្ឋបាលសាលាព្រមព្រៀងគ្នាជាលាយលក្ខណ៍អក្សរក្នុងការបោះបង់ការប្រជុំស្វែងរកដំណោះស្រាយ នោះរយៈពេលកំណត់ 45ថ្ងៃប្រតិទិនសម្រាប់សវនាការត្រឹមត្រូវតាមផ្លូវច្បាប់ចាប់ផ្តើមនៅថ្ងៃបន្ទាប់។

ក្រោយពេលចាប់ផ្តើមធ្វើការសម្រុះសម្រួល ឬការប្រជុំស្វែងរកដំណោះស្រាយ និងមុនពេលបញ្ចប់រយៈពេលរកដំណោះស្រាយ 30ថ្ងៃប្រតិទិនហើយ ប្រសិនបើអ្នក និងស្រុករដ្ឋបាលសាលាព្រមព្រៀងគ្នាជាលាយលក្ខណ៍អក្សរថា គ្មានកិច្ចព្រមព្រៀងណាមួយត្រូវធ្វើឡើង នោះរយៈពេលកំណត់ 45ថ្ងៃប្រតិទិនសម្រាប់សវនាការត្រឹមត្រូវតាមផ្លូវច្បាប់ចាប់ផ្តើមនៅថ្ងៃបន្ទាប់។

ប្រសិនបើអ្នក និងស្រុករដ្ឋបាលសាលាព្រមព្រៀងប្រើប្រាស់ដំណើរការសម្រុះសម្រួល ប៉ុន្តែមិនទាន់ឈានដល់ការព្រមព្រៀងគ្នា នៅពេលបញ្ចប់រយៈពេលរកដំណោះស្រាយ 30ថ្ងៃប្រតិទិន ភាគីទាំងពីរអាចព្រមព្រៀងជាលាយលក្ខណ៍អក្សរដើម្បីបន្តការសម្រុះសម្រួល រហូតឈានទៅដល់ការព្រមព្រៀងមួយ។ ប៉ុន្តែប្រសិនបើអ្នក ឬស្រុករដ្ឋបាលសាលាដកខ្លួនចេញពីដំណើរការសម្រុះសម្រួល នោះរយៈពេលកំណត់ 45ថ្ងៃប្រតិទិនសម្រាប់សវនាការត្រឹមត្រូវតាមផ្លូវច្បាប់ចាប់ផ្តើមនៅថ្ងៃបន្ទាប់។

### កិច្ចព្រមព្រៀងនៃដំណោះស្រាយជាលាយលក្ខណ៍អក្សរ

ប្រសិនបើអ្នក និងស្រុករដ្ឋបាលសាលាដោះស្រាយជម្លោះនៅក្នុងកិច្ចប្រជុំស្វែងរកដំណោះស្រាយ នោះអ្នក និងស្រុករដ្ឋបាលសាលាត្រូវធ្វើកិច្ចព្រមព្រៀងតាមផ្លូវច្បាប់មួយដែល ៖

1. ចុះហត្ថលេខាដោយអ្នក និងតំណាងស្រុករដ្ឋបាលសាលាម្នាក់ដែលមានសិទ្ធិអំណាចចងភ្ជាប់កាតព្វកិច្ចចំពោះស្រុករដ្ឋបាលសាលា **និង**
2. អាចអនុវត្តបាននៅក្នុងតុលាការកំពូល Washington State ណាមួយនៃយុត្តាធិការមានសមត្ថកិច្ច ឬនៅក្នុងតុលាការស្រុកនៃសហរដ្ឋអាមេរិក។

### រយៈពេលត្រួតពិនិត្យកិច្ចព្រមព្រៀង

ប្រសិនបើអ្នក និងស្រុករដ្ឋបាលសាលាធ្វើកិច្ចព្រមព្រៀងមួយ ជាលទ្ធផលនៃកិច្ចប្រជុំស្វែងរកដំណោះស្រាយ មិនថាជាអ្នក ឬស្រុករដ្ឋបាលសាលានោះទេ អាចទុកកិច្ចព្រមព្រៀងនោះជាមោឃៈនៅក្នុងរយៈពេល 3ថ្ងៃធ្វើការចាប់ពីពេលដែលភាគីទាំងសងខាងចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ។

## សវនាការត្រឹមត្រូវតាមផ្លូវច្បាប់ឥតលំអៀង

## 34 CFR §300.511; WAC 392-172A-05080–05095

### ទូទៅ

នៅពេលដែលសំណើសុំសវនាការត្រឹមត្រូវតាមផ្លូវច្បាប់មួយត្រូវបានដាក់ អ្នក ឬស្រុករដ្ឋបាលសាលាដែលពាក់ព័ន្ធនៅក្នុងជម្លោះត្រូវតែមានឱកាសសម្រាប់សវនាការត្រឹមត្រូវតាមផ្លូវច្បាប់ដោយឥតលំអៀង។

### មន្ត្រីរដ្ឋបាលសវនាការ (ALJ)

សវនាការនឹងត្រូវធ្វើឡើងដោយ ALJ ឯករាជ្យដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលបម្រើការឲ្យការិយាល័យសវនាការផ្នែករដ្ឋបាល (Office of Administrative Hearings (OAH))។

មន្ត្រីរដ្ឋបាលសវនាការ យ៉ាងហោចណាស់៖

1. មិនត្រូវជាបុគ្គលិក OSPI ឬស្រុករដ្ឋបាលសាលាដែលពាក់ព័ន្ធនៅក្នុងការអប់រំ ឬថែទាំកុមារ។ ប៉ុន្តែបុគ្គលនេះ មិនមែនជានិយោជិតរបស់ទីភ្នាក់ងារដោយសារតែពួកគេត្រូវបានជួលដោយទីភ្នាក់ងារ ឲ្យធ្វើជា ALJ នោះឡើយ។

2. មិនត្រូវមានផលប្រយោជន៍ផ្ទាល់ខ្លួន ឬអាជីពដែលមានជម្លោះជាមួយនឹងភាពមិនលំអៀងរបស់ ALJ នៅក្នុងសវនាការ។
3. ត្រូវតែមានចំណេះដឹងជ្រៅជ្រះ និងយល់ពីបញ្ញត្តិនានារបស់ IDEA និងបទបញ្ញត្តិសហព័ន្ធ និងរដ្ឋទាក់ទិននឹង IDEA ក៏ដូចជាការបកស្រាយផ្លូវច្បាប់នៃ IDEA ដោយតុលាការសហព័ន្ធ និងរដ្ឋប<u>**និង**</u>
4. ត្រូវមានចំណេះដឹងជ្រៅជ្រះ និងមានសមត្ថភាពដឹកនាំសវនាការ ធ្វើ និងសរសេរសេចក្តីសម្រេចស្របទៅតាមការអនុវត្តច្បាប់សមស្របជាបទដ្ឋាន។

ស្រុករដ្ឋបាលសាលានីមួយៗត្រូវតែរក្សាទុកនូវបញ្ជីឈ្មោះបុគ្គលដែលបម្រើជា ALJ ដោយមានការរៀបរាប់ពីលក្ខណៈសម្បត្តិរបស់ ALJ នីមួយៗ។ បញ្ជីឈ្មោះ ALJ ក៏មាននៅលើគេហទំព័ររបស់ OSPI ផងដែរ។

## <u>កម្មវត្ថុនៃសវនាការត្រឹមត្រូវតាមផ្លូវច្បាប់</u>

ភាគីដែលស្នើសុំសវនាការត្រឹមត្រូវតាមផ្លូវច្បាប់មិនអាចលើកពីបញ្ហានានានៅក្នុងសវនាការត្រឹមត្រូវតាមផ្លូវច្បាប់ដែលមិនត្រូវបានបង្ហាញនៅក្នុងសំណើសុំសវនាការនោះឡើយ លុះត្រាតែភាគីម្ខាងទៀតយល់ព្រម។

## <u>ពេលកំណត់សម្រាប់ការស្នើសុំសវនាការ</u>

អ្នក ឬស្រុករដ្ឋបាលសាលាត្រូវតែដាក់ពាក្យសុំសវនាការត្រឹមត្រូវតាមផ្លូវច្បាប់នៅក្នុងរយៈពេលពីរឆ្នាំគិតចាប់ពីកាលបរិច្ឆេទដែលអ្នក ឬស្រុករដ្ឋបាលសាលាបានដឹង ឬគួរបានដឹងអំពីបញ្ហាដែលបានលើកឡើងនៅក្នុងសំណើសុំសវនាការ។

## <u>ករណីលើកលែងសម្រាប់ពេលកំណត់</u>

ពេលកំណត់ខាងលើមិនយកជាការប្រសិនបើអ្នកមិនអាចដាក់សំណើសុំសវនាការត្រឹមត្រូវតាមផ្លូវច្បាប់ដោយសារ៖

1. ស្រុករដ្ឋបាលសាលាបានថ្លែងមិនពិតថា ខ្លួនបានដោះស្រាយបញ្ហា ឬរឿងរ៉ាវដែលអ្នកលើកឡើងនៅក្នុងសំណើសុំសវនាការរបស់អ្នក <u>**ឬ**</u>
2. ស្រុករដ្ឋបាលសាលាបិទបាំងព័ត៌មានពីអ្នក ដែលខ្លួនត្រូវផ្តល់ជូនអ្នកក្រោម Part B នៃ IDEA។

# <u>សិទ្ធិសវនាការនានា</u>

## <u>34 CFR §300.512; WAC 392-172A-05100</u>

### <u>ទូទៅ</u>

អ្នកមានសិទ្ធិតំណាងឲ្យខ្លួនអ្នកនៅសវនាការត្រឹមត្រូវតាមផ្លូវច្បាប់ (រួមទាំងសវនាការទាក់ទងនឹងនីតិវិធីដាក់វិន័យ)។ អ្នក និងស្រុករដ្ឋបាលសាលាដែលជាភាគីសវនាការត្រឹមត្រូវតាមផ្លូវច្បាប់ (រួមទាំងសវនាការទាក់ទងនឹងនីតិវិធីដាក់វិន័យ) មានសិទ្ធិ ៖

1. ក្នុងការតំណាងដោយមេធាវី និងអមដំណើរ និងផ្តល់ប្រឹក្សាយោបល់ដោយបុគ្គលដែលមានចំណេះដឹង ឬការបណ្តុះបណ្តាលពិសេសទាក់ទងនឹងបញ្ហានានារបស់សិស្សមានពិការភាព។
2. បង្ហាញភស្តុតាង និងប្រឈមមុខ សួរចម្លើយ និងស្នើសុំវត្តមានសាក្សី។
3. ហាមឃាត់ការបង្ហាញពីភស្តុតាងណាមួយនៅសវនាការដែលមិនត្រូវបានបង្ហាញដល់ភាគីម្ខាងទៀត យ៉ាងហោចណាស់ក៏ប្រាំថ្ងៃធ្វើការមុនសវនាការ។
4. យកឯកសារសវនាការដែលបានកត់ត្រាគ្រប់ពាក្យ ជាលាយលក្ខណ៍អក្សរ ឬជាអេឡិចត្រូនិកទៅតាមជម្រើសរបស់អ្នក។ **<u>និង</u>**
5. យកលទ្ធផលនៃអង្គហេតុ និងសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរ ឬជាអេឡិចត្រូនិកទៅតាមជម្រើសរបស់អ្នក។

### <u>ការបង្ហាញព័ត៌មានបន្ថែម</u>

យ៉ាងហោចណាស់ក៏ប្រាំថ្ងៃធ្វើការមុនសវនាការត្រឹមត្រូវតាមផ្លូវច្បាប់ អ្នកនិងស្រុករដ្ឋបាលសាលាត្រូវតែបង្ហាញឲ្យគ្នាទៅវិញទៅមក នូវការវាយតម្លៃទាំងអស់ដែលបានធ្វើឡើងនៅកាលបរិច្ឆេទនោះ និងអនុសាសន៍នានាផ្អែកលើការវាយតម្លៃទាំងឡាយដែលអ្នក ឬស្រុករដ្ឋបាលសាលាចង់ប្រើប្រាស់នៅក្នុងសវនាការ។

ALJ អាចនឹងរារាំងភាគីណាមួយដែលខកខានមិនបានអនុវត្តតាមលក្ខខណ្ឌនេះ មិនឲ្យបង្ហាញការវាយតម្លៃ ឬអនុសាសន៍ពាក់ព័ន្ធនៅសវនាការ ដោយគ្មានការយល់ព្រមពីភាគីម្ខាងទៀត។

### សិទ្ធិរបស់មាតាបិតានៅក្នុងសវនាការ

អ្នកត្រូវបានផ្តល់សិទ្ធិឲ្យ ៖

1. មានវត្តមានកូនអ្នក
2. បើកសវនាការជាសាធារណៈ និង
3. មានឯកសារសវនាការ លទ្ធផលនៃអង្គហេតុ និងសេចក្តីសម្រេចដែលបានផ្តល់ជូនអ្នកដោយឥតគិតថ្លៃ។

## ពេលកំណត់ និងភាពសមរម្យនៃសវនាការ

### 34 CFR §300.515; WAC 392-172-05110

មិនឲ្យលើសពី 45ថ្ងៃប្រតិទិនក្រោយពេលបញ្ចប់រយៈពេលកំណត់ 30ថ្ងៃប្រតិទិនសម្រាប់កិច្ចប្រជុំស្វែងរកដំណោះស្រាយ **ឬ** មិនឲ្យលើសពី 45ថ្ងៃប្រតិទិនក្រោយពេលបញ្ចប់រយៈពេលកំណត់នៃរយៈពេលដោះស្រាយដែលបានកែប្រែ ៖

1. សេចក្តីសម្រេចចុងក្រោយត្រូវបានសម្រេចនៅក្នុងសវនាការ ហើយ
2. សេចក្តីសម្រេចមួយច្បាប់ត្រូវបានផ្ញើជូនភាគីនីមួយៗ។

ALJ អាចផ្តល់ការពន្យារពេលជាក់លាក់លើសពីរយៈពេលកំណត់ 45ថ្ងៃប្រតិទិន ដូចមានរៀបរាប់ខាងលើទៅតាមការស្នើសុំរបស់ភាគីណាមួយៗ។

សវនាការនីមួយៗត្រូវតែធ្វើឡើងនៅម៉ោង និងទីកន្លែងដែលសមរម្យសម្រាប់អ្នក និងកូនអ្នក។

## សេចក្តីសម្រេចនៃសវនាការ

### 34 CFR § 300.513; WAC 392-172-05105

#### សេចក្តីសម្រេចរបស់មន្ត្រីរដ្ឋបាលសវនាការ (ALJ)

សេចក្តីសម្រេចរបស់មន្ត្រីរដ្ឋបាលសវនាការថាតើកូនអ្នកទទួលបានការអប់រំសាធារណៈសមស្របដោយឥតគិតថ្លៃ (FAPE) ឬយ៉ាងណានោះ ត្រូវតែផ្អែកលើមូលដ្ឋានច្បាស់លាស់។

នៅក្នុងសវនាការដែលអ្នកចោទប្រកាន់ថា ស្រុករដ្ឋបាលសាលាបានរំលោភនីតិវិធី ALJ អាចរកឃើញ ថាកូនអ្នកមិនបានទទួល FAPE ក្នុងករណីដែលភាពមិនគ្រប់គ្រាន់នៃនីតិវិធី ៖

1. ជ្រៀតជ្រែកសិទ្ធិរបស់កូនអ្នកក្នុងការទទួលបាន FAPE
2. ជ្រៀតជ្រែកយ៉ាងខ្លាំងលើឱកាសក្នុងការចូលរួមនៅក្នុងដំណើរការធ្វើសេចក្តីសម្រេចទាក់ទងនឹងការផ្តល់ FAPE ដល់កូនអ្នក **ឬ**
3. ធ្វើឲ្យមានការដកហូតអត្ថប្រយោជន៍នៃការអប់រំ។

**ខតាមការសន្មត់នៃច្បាប់**

ទោះបីមន្ត្រី ALJ មិនរកឃើញថា មានការរំលោភលើ FAPE ក៏ដោយ ក៏មន្ត្រី ALJ នៅតែអាចបង្គាប់ឲ្យស្រុករដ្ឋបាលសាលាអនុវត្តតាមលក្ខខណ្ឌតម្រូវទាំងឡាយក្នុងផ្នែកទាក់ទងនឹងនីតិវិធីទទួលបានកិច្ចការពារនៃបទប្បញ្ញត្តិរដ្ឋសហព័ន្ធ ក្រោម Part B នៃ IDEA (34 CFR §§ 300.500 រហូតដល់ 300.536)។

**សំណើដោយឡែកសុំធ្វើសវនាការលើកិច្ចដំណើរការត្រឹមត្រូវតាមច្បាប់**

លោកអ្នកអាចដាក់សំណើដោយឡែកមួយសុំធ្វើសវនាការលើកិច្ចដំណើរការត្រឹមត្រូវតាមច្បាប់ទាក់ទងនឹងបញ្ហាមួយដាច់ដោយឡែកពីសំណើសុំធ្វើសវនាការលើកិច្ចដំណើរត្រឹមត្រូវតាមច្បាប់ ដែលបានដាក់រួចហើយ។

**លទ្ធផល និងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាយោបល់ និងសាធារណៈជនទូទៅ**

OSPI លុបចោលព័ត៌មានអត្តសញ្ញាណផ្ទាល់ខ្លួនណាមួយ និង៖

1. ផ្តល់លទ្ធផលនិងសេចក្តីសម្រេចនៅក្នុងសវនាការអំពីកិច្ចដំណើរការត្រឹមត្រូវតាមច្បាប់ជូនដល់គណៈកម្មាធិការប្រឹក្សាយោបល់លើការអប់រំពិសេសនៃរដ្ឋវ៉ាស៊ីនតោន (SEAC) **និង**
2. ផ្សព្វផ្សាយលទ្ធផល និងសេចក្តីសម្រេចទាំងនោះជូនសាធារណៈជន។

## សេចក្តីសម្រេចស្ថាពរ, បណ្តឹងឧទ្ធរណ៍

### 34 CFR §300.514; WAC 392-172A-05115

សេចក្តីសម្រេចដែលបានធ្វើឡើងនៅក្នុងសវនាការអំពីកិច្ចដំណើរការត្រឹមត្រូវតាមច្បាប់ (រួមទាំងសវនាការទាក់ទងនឹងនីតិវិធីវិន័យ) គឺជាសេចក្តីសម្រេចស្ថាបរ វៀរលែងតែភាគីណាមួយ (លោកអ្នក

ឬស្រុករដ្ឋបាលសាលា) មានការពាក់ព័ន្ធក្នុងសវនាការ ប្តឹងឧទ្ធរណ៍លើសេចក្តីសម្រេច តាមរយៈការធ្វើបណ្តឹងរដ្ឋប្បវេណីទៅតុលាការ ដូចបានរៀបរាប់ខាងក្រោម។

## បណ្តឹងរដ្ឋប្បវេណី រួមទាំងរយៈពេលនៃការដាក់បណ្តឹងទាំងនោះ

### 34 CFR §300.516; WAC 392-172A-05115

**ទូទៅ**

ប្រសិនបើភាគីណាមួយជំទាស់ទៅនឹងលទ្ធផល និងសេចក្តីសម្រេច ដែលធ្វើឡើងនៅក្នុងសវនាការអំពីកិច្ចដំណើរការត្រឹមត្រូវតាមច្បាប់ (រួមទាំងសវនាការទាក់ទងនឹងនីតិវិធីវិន័យផង) ភាគីនោះមានសិទ្ធិធ្វើបណ្តឹងរដ្ឋប្បវេណី ទាក់ទងនឹងបញ្ហាដែលជាកម្មវត្ថុនៃសវនាការលើកិច្ចដំណើរការត្រឹមត្រូវតាមច្បាប់។ បណ្តឹងនោះអាចធ្វើឡើងនៅតុលាការរដ្ឋដែលមានយុត្តាធិការ (តុលាការរដ្ឋដែលមានសមត្ថកិច្ចធ្វើសវនាការលើរឿងក្តីប្រភេទនេះ) ឬនៅតុលាការស្រុកនៃសហរដ្ឋអាមេរិក។ តុលាការស្រុកសហរដ្ឋអាមេរិក មានសិទ្ធិអំណាចក្នុងការសម្រេចលើបណ្តឹងទាំងឡាយដែលធ្វើឡើងក្រោម Part B នៃ IDEA ដោយមិនគិតអំពីបរិមាណនៃវិវាទ។

**អាជ្ញាយុកាល**

ភាគីដែលប្តឹងនឹងមានរយៈពេល **90**ថ្ងៃតាមប្រតិទិន ចាប់ពីថ្ងៃនៃការធ្វើសេចក្តីសម្រេចរបស់មន្ត្រី ALJ ដើម្បីដាក់បណ្តឹងរដ្ឋប្បវេណី។

**<u>នីតិវិធីបន្ថែម</u>**

នៅក្នុងបណ្តឹងរដ្ឋប្បវេណី តុលាការះ

1. ទទួលកំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីរដ្ឋបាល។
2. សវនាការលើភស្តុតាងបន្ថែម តាមការស្នើសុំរបស់លោកអ្នក ឬតាមការស្នើសុំរបស់ស្រុករដ្ឋបាលសាលា **<u>និង</u>**
3. សំអាងលើសេចក្តីសម្រេចរបស់ខ្លួន ស្តីអំពីភាពលើសលុបនៃភស្តុតាង និងផ្តល់វិធានការដំណោះស្រាយដែលតុលាការយល់ឃើញថាសមស្រប។

**<u>វិធាននៃការបកស្រាយ</u>**

Part B នៃ IDEA មិនដាក់កម្រិត ឬកំណត់សិទ្ធិ នីតិវិធី និងដំណោះស្រាយ ដែលមានក្រោមរដ្ឋធម្មនុញ្ញនៃសហរដ្ឋអាមេរិក ច្បាប់ស្តីពីជនជាតិអាមេរិកមានពិការភាពឆ្នាំ 1990 ចំណងជើង V នៃច្បាប់ស្តីពីការស្តារនីតិវិធីសម្បទា ឆ្នាំ1973 (Part 504) ឬច្បាប់ផ្សេងទៀតនៃរដ្ឋសហព័ន្ធ ដែលការពារសិទ្ធិសិស្សនិស្សិតមានពិការភាព។ ទោះយ៉ាងណាក៏ដោយ ប្រសិនបើលោកអ្នកដាក់បណ្តឹងរដ្ឋប្បវេណីក្រោមច្បាប់ទាំងនេះ ហើយលោកអ្នកស្វែងរកដំណោះស្រាយ ដែលមានចែងក្រោម Part B នៃ IDEA ផង ដែរនោះ នីតិវិធីស្តីអំពីសវនាការលើកិច្ចដំណើរត្រឹមត្រូវតាមច្បាប់ ដែលបានរៀបរាប់ខាងលើ ត្រូវតែឈប់ប្រើដូចគ្នានឹងការតម្រូវមួយ ប្រសិនបើលោកអ្នកដាក់បណ្តឹង ក្រោម Part B នៃ IDEA។ នេះមានន័យថា លោកអ្នកអាចមានដំណោះស្រាយ ក្រោមច្បាប់ផ្សេងទៀត ដែលជាន់គ្នាជាមួយនឹងដំណោះស្រាយ ដែលស្ថិតក្រោម IDEA ប៉ុន្តែជាទូទៅ ដើម្បីទទួលបានដំណោះស្រាយក្រោមច្បាប់ដទៃទៀតទាំងនោះ លោកអ្នកត្រូវតែប្រើនីតិវិធីសវនាការលើកិច្ចដំណើរការតាមផ្លូវច្បាប់ឥតលំអៀង ដើម្បីទទួលបានដំណោះស្រាយ ដែលមានក្រោម IDEA មុនប្តឹងទៅតុលាការដោយផ្ទាល់។

# <u>ប្រាក់ថ្លៃឈ្នួលមេធាវី</u>

## <u>34 CFR §300.517; WAC 392-172A-05120</u>

**<u>ទូទៅ</u>**

ប្រសិនបើលោកអ្នកឈ្នះក្តីក្នុងរឿងរដ្ឋប្បវេណី ហើយមានមេធាវីជាតំណាងនោះ តាមឆន្ទានុសិទ្ធិរបស់ខ្លួន តុលាការអាចសម្រេចឲ្យភាគីចាញ់ក្តីបង់ប្រាក់ថ្លៃឈ្នួលមេធាវីសមស្របឲ្យលោកអ្នក។

នៅក្នុងបណ្ដឹង ឬកិច្ចដំណើរការនីតិវិធីណាមួយ ដែលធ្វើឡើងក្រោម Part B នៃ IDEA តាមឆន្ទានុសិទ្ធិរបស់ខ្លួន តុលាការអាចសម្រេចឲ្យមេធាវីរបស់លោកអ្នកបង់ប្រាក់ថ្លៃឈ្នួលមេធាវីសមស្របឲ្យស្រុករដ្ឋបាលសាលា ឬ OSPI ដែលឈ្នះក្ដី ប្រសិនបើមេធាវីៈ (ក) ដែលបានប្ដឹង ឬរឿងក្ដីដែលតុលាការរកឃើញនោះជារឿងក្ដីគ្មានខ្លឹមសារ មិនសមហេតុផល ឬគ្មានមូលដ្ឋានច្បាស់លាស់ ឬ (ខ) បានបន្តប្ដឹងក្រោយពេលដែលបណ្ដឹងនោះបានបង្ហាញកាន់ច្បាស់នូវភាពគ្មានខ្លឹមសារ គ្មានហេតុផល សមស្រប ឬគ្មានមូលដ្ឋានច្បាស់លាស់ **ឬ**

នៅក្នុងបណ្ដឹង ឬកិច្ចដំណើរការនីតិវិធីណាមួយ ដែលធ្វើឡើងក្រោម Part B នៃ IDEA តាមឆន្ទានុសិទ្ធិរបស់ខ្លួន តុលាការអាចសម្រេចឲ្យលោកអ្នក ឬមេធាវីរបស់លោកអ្នកបង់ប្រាក់ថ្លៃឈ្នួលមេធាវីសមស្របឲ្យស្រុករដ្ឋបាលសាលា ឬ OSPI ដែលឈ្នះក្ដី ប្រសិនបើសំណើរបស់លោកអ្នកសុំធ្វើសវនាការលើកិច្ចដំណើការត្រឹមត្រូវតាមច្បាប់នោះ ឬរឿងក្ដីនោះត្រូវបានបង្ហាញឲ្យឃើញនូវបំណងមិនសមស្របក្រោយមក ដូចជាក្នុងបំណងយាយី បង្កការយឺតយ៉ាងមិនចាំបាច់ ឬបង្កើនការចំណាយមិនចាំបាច់លើបណ្ដឹង ឬកិច្ចដំណើរការនីតិវិធី។

## <u>ការសម្រេចអំពីប្រាក់ថ្លៃឈ្នួលមេធាវី</u>

ប្រាក់ថ្លៃឈ្នួលមេធាវី ត្រូវតែផ្អែកលើថ្លៃឈ្នួលទូទៅនៅក្នុងសហគមន៍ ដែលបណ្ដឹង ឬសវនាការនោះធ្វើឡើងទាក់ទងនឹងប្រភេទ និងគុណភាពសេវាដែលបានផ្ដល់។ ប្រាក់បន្ថែម ឬមេគុណមិន ត្រូវប្រើប្រាស់នៅក្នុងការគណនាប្រាក់ថ្លៃឈ្នួលមេធាវី ដែលបានសម្រេចហើយនោះទេ។

ប្រាក់ថ្លៃឈ្នួលមេធាវី មិនអាចត្រូវបានផ្ដល់ ហើយការចំណាយពាក់ព័ន្ធ មិនអាចត្រូវបានសងវិញទៅនៅក្នុងបណ្ដឹង ឬកិច្ចដំណើរការនីតិវិធីក្រោម Part B នៃ IDEA ទាក់ទងនឹងសេវាដែលបានប្រើប្រាស់បន្ទាប់ពីផ្ដល់ដំណោះស្រាយជាលាយលក្ខណ៍អក្សរជូនលោកអ្នក ប្រសិនបើៈ

1. ការផ្ដល់ដំណោះស្រាយនោះធ្វើឡើងក្នុងរយៈពេល ដែលមានចែងក្នុងវិធាន 68 នៃវិធាននីតិវិធីរដ្ឋប្បវេណីនៃរដ្ឋសហព័ន្ធ ឬ ក្នុងករណីសវនាការលើកិច្ចដំណើរការត្រឹមត្រូវតាមច្បាប់ ឬការពិនិត្យឡើងវិញកម្រិតរដ្ឋ ក្នុងរយៈពេលណាមួយច្រើនជាង10ថ្ងៃតាមប្រតិទិន មុនកិច្ចដំណើរការនីតិវិធីចាប់ផ្ដើម។
2. ការផ្ដល់ដំណោះស្រាយនោះមិនត្រូវបានទទួលយកក្នុងរយៈពេល 10ថ្ងៃតាមប្រតិទិន និង

3. តុលាការ ឬមន្ត្រី ALJ រកឃើញថា សំណាងដែលលោកអ្នកបានទទួលជាចុងក្រោយនោះ មិនសមស្របសម្រាប់លោកអ្នកជាងការផ្តល់ដំណោះស្រាយ។

ថ្វីត្បិតតែមានការកម្រិតទាំងនេះ តុលាការអាចសម្រេចឲ្យផ្តល់ប្រាក់ថ្លៃឈ្នួលមេធាវី និងការចំណាយពាក់ព័ន្ធដល់លោកអ្នកបាន ប្រសិនបើលោកអ្នកឈ្នះក្តី ហើយលោកអ្នកមានហេតុផលសមស្របក្នុងការច្រានចោលការផ្តល់ដំណោះស្រាយ។

ប្រាក់ថ្លៃឈ្នួលមេធាវីមិនអាចសម្រេចផ្តល់ជូនបានទេ ទាក់ទងនឹងការប្រជុំណាមួយរបស់ក្រុមការងារ IEP វៀរលែងតែការប្រជុំនោះធ្វើឡើងដោយសារកិច្ចដំណើរការរដ្ឋបាល ឬចំណាត់ការរបស់តុលាការ។

ការប្រជុំស្តីអំពីដំណោះស្រាយមួយ ដែលតម្រូវក្រោមនីតិវិធីសវនាការលើកិច្ចដំណើរការត្រឹមត្រូវតាមច្បាប់ មិនត្រូវចាត់ទុកជាការកោះប្រជុំដោយសារសវនាការរដ្ឋបាល ឬចំណាត់ការតុលាការ ហើយក៏មិនត្រូវចាត់ទុកជាសវនាការរដ្ឋបាល ឬចំណាត់ការតុលាការ ដើម្បីផ្តល់ប្រាក់ថ្លៃឈ្នួលមេធាវីទេ។

តុលាការអាចកាត់បន្ថយបរិមាណប្រាក់ថ្លៃឈ្នួលមេធាវីសមស្របដែលបានសម្រេចផ្តល់ឲ្យ ក្រោម Part B នៃ IDEA ប្រសិនបើតុលាការរកឃើញថា៖

1. ក្នុងអំឡុងពេលបណ្តឹង ឬកិច្ចដំណើរការនីតិវិធី លោកអ្នក ឬមេធាវីរបស់លោកអ្នកបានធ្វើឲ្យយឺតយ៉ាងដល់សេចក្តីសម្រេចចុងក្រោយនៃវិវាទដោយមិនសមហេតុផល។
2. បរិមាណប្រាក់ថ្លៃឈ្នួលមេធាវីដែលសម្រេចឲ្យផ្តល់ មានចំនួនលើសមិនសមស្របនឹងថ្លៃឈ្នួលគិតជាម៉ោង ដែលគិតជាទូទៅនៅក្នុងសហគមន៍ សម្រាប់សេវាស្រដៀងគ្នា នៃមេធាវីដែលមានជំនាញ កិត្តិនាម និងបទពិសោធន៍សមស្របស្រដៀងគ្នា។
3. ពេលវេលាដែលបានចំណាយ និងសេវាច្បាប់ដែលបានផ្តល់ មានកម្រិតច្រើនលើសលប់បើពិនិត្យអំពីលក្ខណៈនៃបណ្តឹង ឬកិច្ចដំណើរការនីតិវិធី **ឬ**
4. មេធាវីដែលធ្វើជាតំណាងឲ្យលោកអ្នក មិនបានផ្តល់ឲ្យស្រុករដ្ឋបាលសាលានូវព័ត៌មានសមស្របនៅក្នុងការជូនដំណឹងអំពីសំណើសុំកិច្ចដំណើរការត្រឹមត្រូវតាមច្បាប់ ដូចបានរៀបរាប់ក្រោមចំនុច ***សំណើសុំសវនាការលើកិច្ចដំណើរការត្រឹមត្រូវតាមច្បាប់***។

ទោះយ៉ាងណាក៏ដោយ តុលាការមិនអាចកាត់បន្ថយប្រាក់ថ្លៃឈ្នួលមេធាវីបានទេ ប្រសិនបើតុលាការរកឃើញថា រដ្ឋ ឬ ស្រុករដ្ឋបាលសាលា បានធ្វើឲ្យយឺតយ៉ាវមិនសមហេតុផលដល់សេចក្តីសម្រេចចុងក្រោយនៃបណ្តឹង ឬកិច្ចដំណើរការនីតិវិធី ឬមានការរំលោភបំពានមួយ ក្រោមខនៃនីតិវិធីទទួលបានកិច្ចការពារនៃ Part B នៃ IDEA។

## នីតិវិធីដាក់វិន័យសម្រាប់សិស្សដែលមានសិទ្ធិទទួលបានការអប់រំពិសេស

កូនរបស់អ្នកត្រូវបានផ្តល់ការការពារសម្រាប់ការអប់រំពិសេស នៅពេលដែលពួកគាត់ត្រូវបានដាក់វិន័យ។ ការការពារទាំងនេះ រួមបញ្ចូលទាំងនីតិវិធីនៃការដាក់វិន័យ ដែលអនុវត្តចំពោះសិស្សទាំងអស់ផងដែរ។ ការការពារទាំងនេះ ក៏អនុវត្តចំពោះសិស្សដែលមិនទាន់ត្រូវបានរកឃើញថា មានសិទ្ធិទទួលបានការអប់រំពិសេសផងដែរ ប្រសិនបើស្រុករដ្ឋបាលសាលាបានដឹងថា សិស្សនោះនឹងមានសិទ្ធិទទួលបាន។

## សិទ្ធិអំណាចរបស់បុគ្គលិកសាលា

### 34 CFR §300.530; WAC 392-172A-05145

#### ការកំណត់ករណីនីមួយៗដាច់ដោយឡែក

បុគ្គលិកសាលាអាចពិចារណាស្ថានភាពពិសេសណាមួយតាមគោលការណ៍មួយករណីម្តងៗ នៅពេលកំណត់ថាតើការផ្លាស់ប្តូរការកំណត់សិទ្ធិទទួលបានសេវាអប់រំ ដែលធ្វើឡើងស្របតាមលក្ខខណ្ឌតម្រូវខាងក្រោមទាក់ទងនឹងវិន័យ មានលក្ខណៈសមស្របសម្រាប់កូនអ្នក ដែលរំលោភបំពានលើក្រមប្រតិបត្តិរបស់សាលា ឬយ៉ាងណា។

#### ទូទៅ

ដូចគ្នានឹងកម្រិតមួយដែលពួកគេចាត់វិធានបែបនេះសម្រាប់សិស្សគ្មានពិការភាព បុគ្គលិកសាលាអាចដកកូនរបស់អ្នកចេញពីការកំណត់សិទ្ធិទទួលបានសេវាអប់រំបច្ចុប្បន្នរបស់ពួកគេមិនឲ្យលើសពីរយៈពេល **10ថ្ងៃសិក្សា**ជាបន្តបន្ទាប់ ទៅដាក់ក្នុងបរិយាកាសអប់រំបណ្តោះអាសន្នសមស្របផ្សេងទៀត ដែលជាបរិយាកាសមួយផ្សេងទៀត ឬផ្អាកកូនរបស់អ្នកនៅពេលដែលពួកគេរំលោភបំពានក្រមសីលធម៌សិស្ស។ បុគ្គលិកសាលា ក៏អាចដកកូនអ្នកបន្ថែមទៀតផងដែរចំពោះការប្រព្រឹត្តខុសឆ្គងដាច់ដោយឡែកនៅក្នុងឆ្នាំសិក្សាដដែលនេះ មិនឲ្យលើសពីរយៈពេល **10ថ្ងៃសិក្សា**ជាបន្តបន្ទាប់ ដរាបណាការដកទាំងនោះមិនធ្វើឲ្យផ្លាស់ប្តូរការកំណត់សិទ្ធិទទួលសេវាអប់រំ (មើល***ការផ្លាស់ប្តូរការកំណត់សិទ្ធិទទួលសេវាអប់រំដោយសារចំណាត់ការវិន័យ*** សម្រាប់និយមន័យខាងក្រោម)។

នៅពេលកូនអ្នកត្រូវបានដកចេញពីការកំណត់សិទ្ធិទទួលសេវាអប់រំបច្ចុប្បន្នរបស់ពួកគេ សម្រាប់រយៈពេលសរុប **10ថ្ងៃសិក្សា**នៅក្នុងឆ្នាំសិក្សាដដែលនេះ ស្រុករដ្ឋបាលសាលាត្រូវតែផ្តល់សេវាក្នុងកម្រិតមួយដូចបានតម្រូវខាងក្រោមក្នុងចំណើងជើងរងស្តីពី***សេវាកម្មនានា*** ក្នុងអំឡុងពេលថ្ងៃបន្តបន្ទាប់នៃការដកចេញនៅក្នុងឆ្នាំសិក្សាដដែលនោះ។

**អំណាចបន្ថែម**

ប្រសិនបើអាកប្បកិរិយាដែលរំលោភបំពានលើក្រមសីលធម៌សិស្សមិនមែនជាអាការៈនៃពិការភាពរបស់កូនអ្នកទេ (មើល ***ការកំណត់ពីអាការៈនៃពិការភាព (Manifestation Determination)*** ខាងក្រោម) ហើយការផ្លាស់ប្តូរការកំណត់សិទ្ធិទទួលបានសេវាអប់រំដោយសារវិន័យ មានរយៈពេលលើសពី **10ថ្ងៃសិក្សា**ជាបន្តបន្ទាប់ បុគ្គលិកសាលាអាចអនុវត្តនីតិវិធីដាក់វិន័យចំពោះកូនអ្នកតាមវិធីដូចគ្នា និងសម្រាប់រយៈពេលដូចគ្នានឹងការអនុវត្តចំពោះសិស្សគ្មានពិការភាពដែរ លើកលែងតែសាលាត្រូវផ្តល់សេវាឲ្យកូនអ្នកដូចបានរៀបរាប់ខាងក្រោមផ្នែកស្តីពី***សេវាកម្មនានា***។ ក្រុមការងារ IEP របស់កូនអ្នកកំណត់ពីបរិយាកាសអប់រំបណ្តោះអាសន្នផ្សេងទៀតដើម្បីផ្តល់សេវាជូនកូនអ្នកនៅក្នុងស្ថានភាពនេះ។

**សេវាកម្មនានា**

សេវាដែលត្រូវផ្តល់ឲ្យកូនអ្នកនៅពេលដែលពួកគេត្រូវបានដកចេញពីការកំណត់សិទ្ធិទទួលសេវាអប់រំបច្ចុប្បន្នរបស់ពួកគេ អាចផ្តល់ឲ្យនៅក្នុងបរិយាកាសអប់រំបណ្តោះអាសន្នមួយផ្សេងទៀត។

ស្រុករដ្ឋបាលសាលាមិនតម្រូវឲ្យផ្តល់សេវានានាដល់កូនអ្នកទេ ប្រសិនបើពួកគេត្រូវបានដកចេញពីការកំណត់សិទ្ធិទទួលសេវាអប់រំបច្ចុប្បន្នរបស់ពួកគេ**សម្រាប់រយៈពេល 10ថ្ងៃសិក្សា ឬតិចជាងនេះ** នៅក្នុងឆ្នាំសិក្សានោះ លុះត្រាតែវាផ្តល់សេវាដល់សិស្សគ្មានពិការភាព ដែលត្រូវបានដកចេញស្រដៀងគ្នានេះ។ ប្រសិនបើកូនអ្នកត្រូវបានដកចេញពីការកំណត់សិទ្ធិទទួលសេវាអប់រំបច្ចុប្បន្នរបស់ពួកគេសម្រាប់រយៈពេល**លើសពី 10ថ្ងៃសិក្សា** កូនអ្នកត្រូវតែ៖

1. បន្តទទួលសេវាអប់រំ ដើម្បីឲ្យកូនអ្នកអាចបន្តចូលរួមក្នុងកម្មវិធីអប់រំទូទៅ ទោះបីស្ថិតនៅក្នុងបរិយាកាសមួយផ្សេងទៀត និងដើម្បីឲ្យរីកចម្រើនឈានទៅរកការសម្រេចគោលដៅដែលបានកំណត់នៅក្នុង IEP របស់ពួកគេ **និង**
2. ប្រសិនបើអាកប្បកិរិយាកូនអ្នកមិនមែនជាអាការៈពិការភាពរបស់ពួកគេ នោះពួកគេត្រូវតែទទួលបានការវាយតម្លៃពីអាកប្បកិរិយាមុខងារ និងសេវាអន្តរាគមន៍អាកប្បកិរិយា និងការកែ

សម្រួលដែលបានបង្កើតឡើងសម្រាប់ដោះស្រាយការរំលោភបំពានលើអាកប្បកិរិយា ដើម្បីកុំឲ្យកើតឡើងម្តងទៀត តាមលក្ខណៈសមស្រប។

បន្ទាប់ពីកូនអ្នកត្រូវបានដកចេញពីការកំណត់សិទ្ធិទទួលសេវាអប់រំបច្ចុប្បន្នរបស់ពួកគេ នៅក្នុងឆ្នាំសិក្សាដដែលសម្រាប់រយៈពេល**10ថ្ងៃសិក្សា** និង__**ប្រសិនបើ**__ការដកនេះមានរយៈពេល **10ថ្ងៃសិក្សា**ជាបន្តបន្ទាប់ ឬតិចជាងនេះ __**និង**__ប្រសិនបើការដកនេះ មិនត្រូវបានកំណត់ថាជាការផ្លាស់ប្តូរការកំណត់សិទ្ធិទទួលសេវាអប់រំ (មើលនិយមន័យខាងក្រោម) __**នោះ**__ បុគ្គលិកសាលា ដោយមានការប្រឹក្សាយោបល់ជាមួយគ្រូរបស់កុមារយ៉ាងតិចម្នាក់ នឹងកំណត់ពីទំហំនៃតម្រូវការរបស់សេវាដើម្បីឲ្យកូនអ្នកអាចបន្តចូលរួមក្នុងកម្មវិធីសិក្សាអប់រំទូទៅ ទោះបីស្ថិតនៅក្នុងបរិយាកាសមួយផ្សេងទៀត និងដើម្បីឲ្យរីកចម្រើនឈានទៅរកការសម្រេចគោលដៅ ដែលបានកំណត់នៅក្នុង IEP របស់កូនអ្នក។

ប្រសិនបើការដកនេះ គឺជាការផ្លាស់ប្តូរការកំណត់សិទ្ធិទទួលសេវាអប់រំ (មើលនិយមន័យខាងក្រោម) ក្រុមការងារ IEP របស់កូនអ្នកកំណត់យកសេវាសមស្របដើម្បីឲ្យកូនអ្នកអាចបន្តចូលរួមក្នុងកម្មវិធីសិក្សាអប់រំទូទៅ ទោះបីស្ថិតក្នុងបរិយាកាសមួយផ្សេងទៀត និងដើម្បីឲ្យរីកចម្រើនឈានទៅរកការសម្រេចគោលដៅដែលបានកំណត់នៅក្នុង IEP របស់ពួកគេ។

## __ការផ្លាស់ប្តូរការកំណត់សិទ្ធិទទួលសេវាអប់រំដោយសារចំណាត់ការវិន័យ__

### __34 CFR §300.536; WAC 392-172A-05155__

ការដកកូនរបស់អ្នកចេញពីការកំណត់សិទ្ធិទទួលសេវាអប់រំបច្ចុប្បន្នរបស់ពួកគេ គឺជា**ការផ្លាស់ប្តូរការកំណត់សិទ្ធិទទួលសេវាអប់រំ**ប្រសិនបើ៖

1. ការដកនោះមានរយៈពេលលើសពី 10ថ្ងៃសិក្សាជាបន្តបន្ទាប់ __**ឬ**__
2. កូនអ្នកស្ថិតក្រោមការដកចេញជាបន្តបន្ទាប់ ដែលបង្កើតជាគំរូមួយដោយសារ៖
   a. ការដកជាបន្តបន្ទាប់សរុបមានរយៈពេលលើសពី 10ថ្ងៃសិក្សានៅក្នុងឆ្នាំសិក្សាមួយ។
   b. អាកប្បកិរិយារបស់កូនអ្នកមានលក្ខណៈស្រដៀងគ្នាយ៉ាងខ្លាំងទៅនឹងឧប្បត្តិហេតុកន្លងមករបស់ពួកគេ ដែលនាំឲ្យមានការដកជាបន្តបន្ទាប់ __**និង**__
   c. មានកត្តាបន្ថែមទៀតដែលយកមកពិចារណាដូចជា រយៈពេលនៃការដកមួយលើកៗ រយៈពេលសរុបដែលកូនអ្នកត្រូវបានដកចេញ និងគម្លាតនៃការដកពីមួយទៅមួយ។

ស្រុករដ្ឋបាលសាលាកំណត់ថាតើគំរូនៃការដកនោះធ្វើឲ្យមានការផ្លាស់ប្តូរការកំណត់សិទ្ធិទទួលសេវាអប់រំតាមគោលការណ៍មួយករណីម្តងៗ ឬយ៉ាងណា និងស្ថិតក្រោមការត្រួតពិនិត្យឡើងវិញតាមសវនាការត្រឹមត្រូវតាមច្បាប់ និងនីតិវិធីតុលាការប្រសិនបើអ្នកមិនយល់ស្រប។

## ការជូនដំណឹង

នៅថ្ងៃដែលស្រុករដ្ឋបាលសាលាធ្វើសេចក្តីសម្រេចដកចេញដែលជាការផ្លាស់ប្តូរការកំណត់សិទ្ធិទទួលសេវាអប់រំសម្រាប់កូនអ្នក ដោយសារការរំលោភបំពានលើក្រមសីលធម៌សិស្ស ស្រុករដ្ឋបាលសាលាត្រូវតែជូនដំណឹងអ្នកអំពីសេចក្តីសម្រេចនោះ ហើយផ្តល់សេចក្តីជូនដំណឹងស្តីពីកិច្ចការពារតាមនីតិវិធីដល់អ្នក។

## ការកំណត់ពីអាការៈនៃពិការភាព

នៅក្នុងរយៈពេល **10ថ្ងៃសិក្សា**នៃការសម្រេចណាមួយចំពោះការផ្លាស់ប្តូរការកំណត់សិទ្ធិទទួលសេវាអប់រំ (មើល ***ការផ្លាស់ប្តូរការកំណត់សិទ្ធិទទួលសេវាអប់រំដោយសារចំណាត់ការវិន័យ***) របស់កូនអ្នក ដោយសារការរំលោភក្រមសីលធម៌សិស្ស ស្រុករដ្ឋបាលសាលា និងសមាជិកពាក់ព័ន្ធនៃក្រុមការងារកម្មវិធី IEP ដែលកំណត់ដោយអ្នក និងស្រុករដ្ឋបាលសាលាត្រូវតែពិនិត្យឡើងវិញលើគ្រប់ព័ត៌មានពាក់ព័ន្ធទាំងអស់នៅក្នុងឯកសារកូនអ្នក រួមទាំងកម្មវិធី IEP របស់ពួកគេ ការអង្កេតរបស់គ្រូណាម្នាក់ និងព័ត៌មានពាក់ព័ន្ធណាមួយ ដែលបានផ្តល់ដោយអ្នកសម្រាប់កំណត់៖

1. ថាតើការប្រព្រឹត្តនោះបង្កឡើងដោយ ឬមានទំនាក់ទំនងដោយផ្ទាល់ និងសំខាន់ទៅនឹងពិការភាពរបស់កូនអ្នកឬយ៉ាងណា **ឬ**
2. ថាតើការប្រព្រឹត្តនោះគឺជាលទ្ធផលផ្ទាល់នៃការខកខានរបស់ស្រុករដ្ឋបាលសាលាក្នុងការអនុវត្តកម្មវិធី IEP របស់កូនអ្នកឬយ៉ាងណា។

ប្រសិនបើសមាជិកពាក់ព័ន្ធនៃក្រុមការងារកម្មវិធី IEP នៃកូនរបស់លោកអ្នក រួមទាំងលោកអ្នក កំណត់ថា បានបំពេញលក្ខខណ្ឌទាំងនោះហើយ ការប្រព្រឹត្តនោះត្រូវតែកំណត់ថា ជាសញ្ញាណបណ្តាលមកពីពិការភាពរបស់លោកអ្នក។

ប្រសិនបើក្រុមការងារដែលបានរៀបរាប់ខាងលើ សម្រេចចិត្តថា ការប្រព្រឹត្តនោះគឺជាលទ្ធផលដោយផ្ទាល់នៃការខកខានរបស់ស្រុករដ្ឋបាលសាលាក្នុងការអនុវត្តកម្មវិធី IEP ស្រុករដ្ឋបាលសាលាត្រូវតែចាត់វិធានការណ៍ជាបន្ទាន់ ដើម្បីដោះស្រាយភាពចន្លោះប្រហោងទាំងនោះ។

## ការកំណត់ឥរិយាបទដែលជាសញ្ញាណបណ្ដាលមកពីពិការភាពរបស់សិស្ស

នៅពេលក្រុមការងារនេះ រួមទាំងលោកអ្នកផង សម្រេចថា ការប្រព្រឹត្តនោះគឺជាសញ្ញាណ បណ្ដាលមកពីពិការភាពនៃកូនរបស់លោកអ្នក ក្រុមការងារ IEP ត្រូវតែ៖

1. ធ្វើការវាយតម្លៃមុខងារឥរិយាបទ លុះត្រាតែស្រុករដ្ឋបាលសាលាបានបញ្ចប់ការងារវាយតម្លៃមុខងារឥរិយាបទ មុនពេលឥរិយាបទដែលនាំឲ្យមានការផ្លាស់ប្ដូរនូវការកំណត់សិទ្ធិទទួលសេវាអប់រំនោះបានកើតឡើង និងអនុវត្តផែនការអន្តរាគមន៍ឥរិយាបទសម្រាប់កូនលោកអ្នក **ឬ**
2. ប្រសិនបើផែនការអន្តរាគមន៍ឥរិយាបទ ត្រូវបានបង្កើតរួចហើយ ចូរពិនិត្យឡើងវិញនូវ ផែនការអន្តរាគមន៍ឥរិយាបទ ហើយកែសម្រួលវាតាមការចាំបាច់ ដើម្បីដោះស្រាយឥរិយាបទកូនរបស់លោកអ្នក។

លើកលែងតែបានរៀបរាប់ខាងក្រោម ក្រោមចំណងជើងរងអំពី ***ស្ថានភាពពិសេស*** ស្រុករដ្ឋបាលសាលាត្រូវបញ្ជូលកូនរបស់លោកអ្នកត្រឡប់ទៅកាន់ការកំណត់សិទ្ធិទទួលសេវាអប់រំ ដែលគាត់ត្រូវបានដកចេញកន្លងមក វៀរលែងតែលោកអ្នក និងស្រុករដ្ឋបាលសាលាយល់ព្រមទៅនឹងការផ្លាស់ប្ដូរការកំណត់សិទ្ធិទទួលការអប់រំថាវាជាផ្នែកមួយនៃការកែប្រែផែនការអន្តរាគមន៍ឥរិយាបទ។

## ស្ថានភាពពិសេស

បុគ្គលិកសាលាអាចដកកូនរបស់លោកអ្នកទៅដាក់ក្នុងបរិយាកាសអប់រំជម្រើសបណ្ដោះអាសន្នមួយ (ដែលកំណត់ដោយក្រុមការងារកម្មវិធី IEP របស់សិស្ស) សម្រាប់រយៈពេលរហូតដល់ 45ថ្ងៃនៃថ្ងៃសិក្សា ដោយមិនគិតអំពីថា តើឥរិយាបទកូនរបស់លោកអ្នកស្ដែងចេញពីសញ្ញាណមួយនៃពិការភាពរបស់ខ្លួនឬអត់ ប្រសិនបើគាត់៖

1. កាន់អាវុធ (ចូរមើលនិយមន័យខាងក្រោម) ចូលសាលា ឬមានអាវុធនៅសាលា នៅក្នុងបរិវេណសាលា ឬនៅក្នុងពិធីផ្លូវការរបស់សាលា ក្រោមយុត្តាធិការរបស់ស្រុករដ្ឋបាលសាលា។
2. មាន ឬដឹងពីការប្រើប្រាស់គ្រឿងញៀនខុសច្បាប់ (ចូរមើលនិយមន័យខាងក្រោម) ឬលក់ ឬស្នើឲ្យលក់សារធាតុហាមឃាត់ (ចូរមើលនិយមន័យខាងក្រោម) ខណៈពេលនៅក្នុងសាលា នៅក្នុងបរិវេណសាលា ឬក្នុងពីធីផ្លូវការរបស់សាលា ក្រោមយុត្តាធិការរបស់ស្រុករដ្ឋបាលសាលា **ឬ**
3. បានបង្ករបួសស្នាមរាងកាយធ្ងន់ធ្ងរ (ចូរមើលនិយមន័យខាងក្រោម) ទៅលើបុគ្គលម្នាក់ផ្សេងទៀត ខណៈពេលនៅសាលា នៅក្នុងបរិវេណសាលា ឬក្នុងពិធីផ្លូវការរបស់សាលា ក្រោមយុត្តាធិការរបស់ស្រុករដ្ឋបាលសាលា។

## <u>និយមន័យ</u>

- *សារធាតុហាមឃាត់* មានន័យថា គ្រឿងញៀន ឬសារធាតុផ្សេងទៀត ដែលកំណត់ក្រោមតារាង I, II, III, IV ឬ V ក្នុង Part 202 (c) នៃច្បាប់ស្តីពីសារធាតុហាមឃាត់ (21 U.S.C. 812 (c))។
- *គ្រឿងញៀនខុសច្បាប់* មានន័យថា សារធាតុហាមឃាត់ ប៉ុន្តែមិនរួមបញ្ចូលសារធាតុហាមឃាត់ណា ដែលត្រូវបានគ្រប់គ្រងស្របច្បាប់ ឬបានប្រើប្រាស់ក្រោមការត្រួតពិនិត្យពីអ្នកជំនាញថែទាំសុខភាពមានអាជ្ញាប័ណ្ណ ឬត្រូវបានគ្រប់គ្រងស្របច្បាប់ ឬបានប្រើប្រាស់ក្រោមអាជ្ញាធរផ្សេងទៀតក្រោមច្បាប់នោះ ឬក្រោមខប្បញ្ញត្តិទាំងឡាយផ្សេងទៀតនៃច្បាប់សហព័ន្ធទេ។
- *ការបង្ករបួសស្នាមរាងកាយធ្ងន់ធ្ងរ* មានន័យថា របួសស្នាមរាងកាយ ដែលទាក់ទងនឹងគ្រោះថ្នាក់ដល់ស្លាប់ ការឈឺចុកចាប់រាងកាយធ្ងន់ធ្ងរ ការធ្វើឲ្យពិការរាងកាយជាក់ស្តែងយូរអង្វែង ឬការបាត់បង់ ឬធ្វើឲ្យចុះខ្សោយមុខងារនៃអវៈយវៈនៃរាងកាយ រាងកាយ ឬសមត្ថភាពសតិបញ្ញាស្មារតីយូរអង្វែង។
- *អាវុធ* មានន័យថា អាវុធ ឧបករណ៍ បរិក្ខារ សម្ភារៈ ឬសារធាតុ អ្វីដែលមានជីវិត ឬគ្មានជីវិត ដែលត្រូវបានប្រើប្រាស់សម្រាប់ ឬអាចបណ្តាលឲ្យស្លាប់ ឬបង្ករបួសស្នាមរាងកាយធ្ងន់ធ្ងរ លើកលែងតែកាំបិតដាក់ក្នុងហោប៉ៅ មានផ្លែប្រវែងខ្លីជាងពីរអ៊ីងកន្លះ។

## <u>ការកំណត់បរិយាកាស</u>

### <u>34 CFR § 300.531; WAC 392-172A-05150</u>

ក្រុមការងារ IEP ត្រូវតែកំណត់បរិយាកាសអប់រំជម្រើសបណ្តោះអាសន្ន ដើម្បីការដេកសិស្សចេញដែលជា**ការផ្លាស់ប្តូរការកំណត់សិទ្ធិទទួលសេវាអប់រំ** និងការដេកសិស្សក្រោមផ្នែកនិយាយអំពី ***សិទ្ធិសម្រេចបន្ថែម*** និង ***ស្ថានភាពពិសេស*** ខាងលើ។

## <u>នីតិវិធីសវនាការលើកិច្ចដំណើរការត្រឹមត្រូវតាមច្បាប់សម្រាប់វិន័យ</u>

### <u>34 CFR § 300.532; WAC 392-172A-05160</u>

លោកអ្នកអាចស្នើសុំសវនាការលើកិច្ចដំណើរការត្រឹមត្រូវតាមច្បាប់ ប្រសិនបើលោកអ្នកមិនយល់ព្រមជាមួយនឹង៖

1. សេចក្តីសម្រេចណាមួយទាក់ទងនឹងការកំណត់សិទ្ធិទទួលសេវាអប់រំ ដែលបានធ្វើឡើងក្រោមឧប្បញ្ញត្តិនានានៃវិន័យ **ឬ**
2. កិច្ចដំណើការកំណត់ឥរិយាបទសិស្សបណ្តាលមកពីពិការភាពដែលបានរៀបរាប់ខាងលើ។

ស្រុករដ្ឋបាលសាលា អាចធ្វើសំណើសុំសវនាការលើកិច្ចដំណើរការត្រឹមត្រូវតាមច្បាប់ ប្រសិនបើខ្លួនជឿជាក់ថា ការរក្សាការកំណត់សិទ្ធិទទួលសេវាអប់រំបច្ចុប្បន្នរបស់កូនលោកអ្នក ទំនងជាបង្កឲ្យមានរបួសស្នាមដល់កូនលោកអ្នក ឬអ្នកដទៃ។

សូមមើលផ្នែក៖ **នីតិវិធីសវនាការលើកិច្ចដំណើរការត្រឹមត្រូវតាមច្បាប់** សម្រាប់ព័ត៌មានបន្ថែមស្តីពីការដាក់សំណើសុំធ្វើសវនាការលើកិច្ចដំណើរការត្រឹមត្រូវតាមច្បាប់។

## <u>សិទ្ធិអំណាចរបស់មន្ត្រីរដ្ឋបាលសវនាការ (ALJ)</u>

ALJ មួយរូប ត្រូវដំណើរការសវនាការលើកិច្ចដំណើរការត្រឹមត្រូវតាមច្បាប់ និងធ្វើសេចក្តីសម្រេចចិត្ត។ មន្ត្រី ALJ អាច៖

1. បញ្ជូនកូនរបស់លោកអ្នកត្រឡប់កាន់ការកំណត់សិទ្ធិទទួលសេវាអប់រំ ដែលគាត់ឬនាងត្រូវបានដកកន្លងមក ប្រសិនបើមន្ត្រី ALJ កំណត់ថា ការដកនោះរំលោភបំពានដល់លក្ខខណ្ឌតម្រូវដែលបានរៀបរាប់ ក្រោមចំនុច ***សិទ្ធិអំណាចរបស់បុគ្គលិកសាលា*** ឬប្រសិនបើមន្ត្រី ALJ កំណត់ថាឥរិយាបទកូនរបស់លោកអ្នក បង្ហាញពីសញ្ញាណមួយបណ្តាលមកពីពិការភាពរបស់នាង ឬរបស់គាត់ **ឬ**
2. ចេញសេចក្តីបង្គាប់ឲ្យផ្លាស់ប្តូរការកំណត់សិទ្ធិទទួលសេវាអប់រំនៃកូនរបស់លោកអ្នកទៅដាក់ក្នុងបរិយាកាសអប់រំជម្រើសបណ្តោះអាសន្នសមស្របមួយ សម្រាប់រយៈពេលជាង 45ថ្ងៃនៃថ្ងៃសិក្សា ប្រសិនបើមន្ត្រី ALJ នោះកំណត់ថា ការរក្សាការកំណត់សិទ្ធិទទួលសេវាអប់រំបច្ចុប្បន្ននៃរបស់កូនលោកអ្នក ទំនងជាបង្កឲ្យមានរបួសស្នាមដល់កូនលោកអ្នក ឬអ្នកដទៃ។

នីតិវិធីសវនាការទាំងនេះ អាចធ្វើឡើងដដែលៗ ប្រសិនបើស្រុករដ្ឋបាលសាលាជឿជាក់ថា ការបញ្ជូនកូនលោកអ្នកត្រឡប់ទៅកាន់ការកំណត់សិទ្ធិទទួលសេវាអប់រំដំបូង ទំនងជាបង្កឲ្យមានរបួសស្នាមដល់កូនលោកអ្នក ឬអ្នកដទៃ។

នៅពេលលោកអ្នក ឬស្រុករដ្ឋបាលសាលា ស្នើសុំសវនាការលើកិច្ចដំណើរការត្រឹមត្រូវតាមច្បាប់ សំណើនោះ ត្រូវគោរពតាមលក្ខខណ្ឌតម្រូវ ដែលបានរៀបរាប់ក្រោមចំនុច ***នីតិវិធីនៃសំណើសុំធ្វើ***

*សវនាការលើកិច្ច ដំណើរការត្រឹមត្រូវតាមច្បាប់ និងសវនាការលើកិច្ចដំណើរការត្រឹមត្រូវតាមច្បាប់* លើកលែងតែ៖

1. សវនាការលើកិច្ចដំណើរការត្រឹមត្រូវតាមច្បាប់នោះ ត្រូវបានពន្លឿន ហើយត្រូវកើតឡើងក្នុងរយៈពេល **<u>20</u>**ថ្ងៃសិក្សានៃថ្ងៃស្នើសុំសវនាការ។ មន្ត្រី ALJ ត្រូវចេញសេចក្តីសម្រេចក្នុងរយៈពេល **<u>10</u>**ថ្ងៃនៃថ្ងៃសិក្សា បន្ទាប់ពីសវនាការ។
2. លុះត្រាតែលោកអ្នក ឬស្រុករដ្ឋបាលសាលា យល់ព្រមជាលាយលក្ខណ៍អក្សរក្នុងការបោះបង់សិទ្ធិចូលរួមប្រជុំ ឬយល់ព្រមប្រើប្រាស់ការសម្រុះសម្រួល ការប្រជុំរកដំណោះស្រាយមួយត្រូវតែធ្វើឡើងក្នុងរយៈពេល**<u>ប្រាំពីរ</u>**ថ្ងៃតាមប្រតិទិន គិតចាប់ពីថ្ងៃដែលលោកអ្នកដាក់សំណើសុំសវនាការលើកិច្ចដំណើរការត្រឹមត្រូវតាមច្បាប់ជាមួយ OSPI និងស្រុករដ្ឋបាលសាលា។ សវនាការអាចដំណើរការទៅបាន លុះត្រាបញ្ហាត្រូវបានដោះស្រាយដោយការពេញចិត្តពីភាគីទាំងពីរ ក្នុងរយៈពេល **<u>15</u>**ថ្ងៃចាប់ពីថ្ងៃទទួលបានសំណើសុំសវនាការលើកិច្ចដំណើរការត្រឹមត្រូវតាមច្បាប់។
3. OSPI បានកំណត់ពេលវេលា **<u>2</u>**ថ្ងៃនៃថ្ងៃធ្វើការ សម្រាប់ការបង្ហាញភ័ស្តុតាងបញ្ជាក់ នៅពេលលោកអ្នក ឬស្រុករដ្ឋបាលសាលាដាក់សំណើសុំពន្លឿនសវនាការលើកិច្ចដំណើការត្រឹមត្រូវតាមច្បាប់ (សម្រាប់វិន័យ)។

លោកអ្នក ឬ ស្រុករដ្ឋបាលសាលា អាចផ្តួចផ្តើមឲ្យមានចំណាត់ការស៊ីវិលមួយ ជំទាស់ទៅនឹងការសម្រេចធ្វើឡើងនៅក្នុងសវនាការលើកិច្ចដំណើការត្រឹមត្រូវតាមច្បាប់ដែលបានពន្លឿន ដូចគ្នានឹងអ្វីដែលពួកគេជំទាស់នឹងការសម្រេចធ្វើឡើងនៅក្នុងសវនាការលើកិច្ចដំណើរការត្រឹមត្រូវតាមច្បាប់ ទាក់ទងនឹងចំណាត់ការវិន័យនៃការអប់រំពិសេស។ (ចូរមើល ***ការតវ៉ាមិនសុខចិត្ត*** ខាងលើ)។

## កន្លែងអប់រំកូនអ្នកក្នុងពេលធ្វើសវនការនីតិវិធីត្រឹមត្រូវតាមច្បាប់ឆាប់រហ័ស

### 34 CFR §300.533; WAC 392-172A-05165

នៅពេលអ្នក ឬស្រុករដ្ឋបាលបានដាក់សំណើធ្វើសវនការនីតិវិធីត្រឹមត្រូវតាមច្បាប់ពាក់ព័ន្ធនឹងបញ្ហាវិន័យ លើកលែងករណីអ្នក និងស្រុករដ្ឋបាលមានការយល់ព្រមផ្សេងពីនេះ កូនអ្នកចាំបាច់ត្រូវបន្តទទួលការអប់រំជំនួសបណ្ដោះអាសន្ន ដោយរង់ចាំសេចក្ដីសម្រេចរបស់មន្ត្រីសវនការ ឬរហូតដល់ពេលផុតកំណត់រយៈពេលដកចេញពីសាលា ដូចត្រូវបានរៀបរាប់ក្រោមសារបាន ***សិទ្ធិអំណាចរបស់បុគ្គលិកសាលារៀន*** ដោយត្រូវអនុវត្តតាមករណីមួយណាដែលកើតឡើងមុន។

## កិច្ចការពារសម្រាប់សិស្សដែលមិនគ្រប់លក្ខណៈសម្បត្តិទទួលការអប់រំពិសេស និងសេវាពាក់ព័ន្ធ ផ្សេងៗ

### 34 CFR §300.534; WAC 392-172A-05170

**ទូទៅ**

ប្រសិនបើកូណអ្នកមិនទាន់ត្រូវបានកំណត់ថាគ្រប់លក្ខណៈសម្បត្តិទទួលការអប់រំពិសេស និងសេវាពាក់ព័ន្ធផ្សេងៗ ហើយបានរំលោភទៅលើក្រមសីលធម៌សិស្ស អ្នកអាចបញ្ជាក់ពីកិច្ចការពារតាមនីតិវិធីជូនកូនអ្នក ប្រសិនបើមានការកំណត់ថាស្រុករដ្ឋបាលបានដឹងថាកូនអ្នកគប្បីត្រូវបានវាយតម្លៃ និងកំណត់ថាគ្រប់លក្ខណៈសម្បត្តិទទួលសេវាអប់រំពិសេស មុនពេលការប្រព្រឹត្តដែលនាំដល់ការចាត់វិធានការវិន័យ។

**មូលដ្ឋាននៃការដឹងឮសម្រាប់បញ្ហាវិន័យ**

ស្រុករដ្ឋបាលចាំបាច់ត្រូវបានចាត់ទុកថាបានដឹងថាកូនអ្នកគ្រប់លក្ខណៈសម្បត្តិទទួលការអប់រំពិសេស ប្រសិនបើមុនពេលការប្រព្រឹត្តដែលនាំដល់ការចាត់វិធានការវិន័យ ៖

1. អ្នកបានបង្ហាញពីក្ដីបារម្ភជាលាយលក្ខណ៍អក្សរថាកូនអ្នកត្រូវការការអប់រំពិសេស និងសេវាពាក់ព័ន្ធ ទៅកាន់បុគ្គលិកត្រួតពិនិត្យ ឬរដ្ឋបាលនៃស្រុករដ្ឋបាលសាលា ឬទៅកាន់គ្រូបង្រៀនរបស់កូនអ្នក។

2. អ្នកបានស្នើសុំធ្វើការវាយតម្លៃពាក់ព័ន្ធនឹងលក្ខណៈសម្បត្តិសម្រាប់ការអប់រំពិសេស និងសេវាពាក់ព័ន្ធផ្សេងៗ ក្រោយម Part B នៃ IDEA **ឬ**
3. គ្រូបង្រៀនរបស់កូនអ្នក ឬបុគ្គលិកស្រុករដ្ឋបាលផ្សេងទៀត បានបង្ហាញពីក្តីបារម្ភពីទម្រង់ឥរិយាបថរបស់កូនអ្នក ដោយផ្ទាល់ទៅកាន់នាយកផ្នែកអប់រំពិសេសនៃស្រុករដ្ឋបាល ឬទៅកាន់ បុគ្គលិកត្រួតពិនិត្យនៃស្រុករដ្ឋបាល។

## <u>ករណីលើកលែង</u>

ស្រុករដ្ឋបាលនឹងមិនត្រូវចាត់ទុកថាបានដឹងឮ ប្រសិនបើ ៖

1. អ្នកមិនបានអនុញ្ញាតឲ្យធ្វើការវាយតម្លៃកូនអ្នក ឬអ្នកបានបដិសេធមិនទទួលយកសេវាអប់រំពិសេស **ឬ**
2. កូនអ្នកត្រូវបានវាយតម្លៃ ហើយកំណត់ថាមិនគ្រប់លក្ខណៈសម្បត្តិទទួលសេវាអប់រំពិសេស។

## <u>លក្ខខណ្ឌត្រូវអនុវត្តក្នុងករណីគ្មានមូលដ្ឋាននៃការដឹងឮ</u>

ប្រសិនបើស្រុករដ្ឋបាលមិនបានដឹងថាកូនអ្នកគ្រប់លក្ខណៈសម្បត្តិទទួលការអប់រំពិសេស មុនពេលចាត់វិធានការវិន័យចំពោះកូនអ្នក ដូចត្រូវបានរៀបរាប់ខាងលើក្រោមអនុសារបាន ***មូលដ្ឋាននៃការដឹងឮសម្រាប់បញ្ហាវិន័យ*** និង***ករណីលើកលែង*** នោះកូនអ្នកអាចត្រូវទទួលរងការចាត់វិធានការវិន័យដែលត្រូវអនុវត្តចំពោះសិស្សគ្មានពិការភាព ដែលបានចូលរួមក្នុងការប្រព្រឹត្តប្រភេទដូចគ្នា។

ក៏ប៉ុន្តែ ប្រសិនបើអ្នក ឬស្រុករដ្ឋបាលស្នើសុំធ្វើការវាយតម្លៃកូនអ្នកក្នុងពេលដែលកូនអ្នកទទួលរង ការចាត់វិធានការវិន័យ នោះការវាយតម្លៃចាំបាច់ត្រូវធ្វើឡើងយ៉ាងឆាប់រហ័ស។

រហូតដល់ពេលការវាយតម្លៃត្រូវបានបញ្ចប់ កូនអ្នកត្រូវបន្តទទួលការអប់រំតាមការកំណត់ដោយថ្នាក់ដឹកនាំសាលារៀន ដែលអាចរួមមានការផ្អាក ឬបណ្តេញកូនអ្នកចេញពីសាលាដោយគ្មានការផ្តល់សេវាអប់រំ។

ប្រសិនបើកូនអ្នកត្រូវបានកំណត់ថាគ្រប់លក្ខណៈសម្បត្តិទទួលសេវាអប់រំពិសេស ដោយពិចារណាទៅលើព័ត៌មានទទួលបានពីការវាយតម្លៃដែលធ្វើឡើងដោយស្រុករដ្ឋបាល និងព័ត៌មានដែលអ្នកបានផ្តល់ជូន នោះស្រុករដ្ឋបាលចាំបាច់ត្រូវផ្តល់ការអប់រំពិសេស និងសេវាពាក់ព័ន្ធដល់កូនអ្នក ហើយត្រូវអនុវត្តតាមលក្ខខណ្ឌតម្រូវផ្នែកវិន័យដែលត្រូវបានរៀបរាប់ខាងលើ។

## <u>ការបញ្ជូនបន្ត និងវិធានការរបស់អាជ្ញាធរអនុវត្តច្បាប់ និងអាជ្ញាធរយុត្តិធម៌</u>

### <u>34 CFR §300.535; WAC 392-172A-05175</u>

Part B នៃ IDEA មិនបាន ៖

1. ហាមឃាត់មិនអោយស្រុករដ្ឋបាលសាលារាយការណ៍អំពីបទល្មើសប្រព្រឹត្តដោយកូនអ្នក ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីទទួលការអប់រំពិសេស ទៅកាន់អាជ្ញាធរពាក់ព័ន្ធសមស្រប <u>ឬ</u>
2. ទប់ស្កាត់អាជ្ញាធរអនុវត្តច្បាប់ និងអាជ្ញាធរយុត្តិធម៌របស់រដ្ឋពីការអនុវត្តការទទួលខុសត្រូវរបស់ពួក គេពាក់ព័ន្ធការអនុវត្តច្បាប់សហព័ន្ធ និងច្បាប់រដ្ឋចំពោះបទល្មើសដែលប្រព្រឹត្តដោយកូនអ្នក។.

<u>ការបញ្ជូនកំណត់ត្រា</u>

ប្រសិនបើស្រុករដ្ឋបាលរាយការណ៍ពីបទល្មើសណាមួយដែលប្រព្រឹត្តដោយកូនអ្នក ស្រុករដ្ឋបាល ៖

1. ចាំបាច់ត្រូវធានាថាសំណៅចម្លងនៃកំណត់ត្រានៃការអប់រំពិសេស និងកំណត់ត្រាផ្នែកវិន័យរបស់ កូនអ្នកត្រូវបានបញ្ជូនចេញជាមូលដ្ឋានពិចារណាដោយអាជ្ញាធរដែលស្រុករដ្ឋបាលធ្វើការរាយការណ៍ជូន **<u>និង</u>**
2. អាចបញ្ជូនសំណៅចម្លងនៃកំណត់ត្រានៃការអប់រំពិសេស និងកំណត់ត្រាផ្នែកវិន័យរបស់កូនអ្នក ក្នុងកម្រិតមួយដែលត្រូវបានអនុញ្ញាតដោយ FERPA តែប៉ុណ្ណោះ។

## <u>លក្ខខណ្ឌតម្រូវនៃការស្វែងរកទីកន្លែងសិក្សាដោយឪពុកម្តាយរបស់សិស្សក្នុងសាលាឯកជន ដោយ ការចំណាយសាធារណៈ</u>

### <u>CFR § 300.148; WAC 392-172A-04115</u>

ប្រសិនបើអ្នកយល់ឃើញថាស្រុករដ្ឋបាលសាលារបស់អ្នកមិនអាចផ្តល់ FAPE ដល់កូនអ្នក ហើយអ្នកជ្រើសរើសចុះឈ្មោះអោយកូនអ្នកចូលរៀនក្នុងសាលាឯកជន ដោយគ្មានការយល់ព្រមរបស់ស្រុករដ្ឋបាល អ្នកចាំបាច់ត្រូវអនុវត្តតាមជំហានជាក់លាក់មួយចំនួនដើម្បីស្នើសុំការសងប្រាក់ពីស្រុករដ្ឋបាល សម្រាប់ការចុះឈ្មោះចូលរៀននៅសាលាឯកជននោះ។

## ការសងប្រាក់សម្រាប់ការចុះឈ្មោះចូលរៀននៅសាលាឯកជន

ប្រសិនបើកាលពីគ្រាមុន កូនអ្នកបានទទួលការអប់រំពិសេស និងសេវាពាក់ព័ន្ធនានាពីស្រុករដ្ឋបាលសាលា ហើយអ្នកជ្រើសរើសចុះឈ្មោះអោយកូនអ្នកចូលរៀនក្នុងសាលាឯកជន កម្រិតបឋមសិក្សា ឬ មធ្យមសិក្សា ដោយគ្មានការយល់ព្រម ឬបញ្ជូនបន្តរបស់ស្រុករដ្ឋបាល តុលាការ ឬ ALJ អាចស្នើសុំអោយស្រុករដ្ឋបាលសងប្រាក់ជូនអ្នកសម្រាប់ការចំណាយលើការចុះឈ្មោះចូលរៀនរបស់កូនអ្នក ប្រសិនបើតុលាការ ឬ ALJ រកឃើញថាស្រុករដ្ឋបាលសាលាមិនបានផ្តល់ FAPE ដល់កូនអ្នកទាន់ពេលវេលា មុនពេលចុះឈ្មោះចូលរៀននេះ ហើយការចុះឈ្មោះចូលរៀននៅសាលាឯកជននេះមានលក្ខណៈសមស្រប។ តុលាការ ឬ ALJ អាចកំណត់ថាការចុះឈ្មោះចូលរៀននៅសាលាឯកជនរបស់កូនអ្នកមានលក្ខណៈសមស្រប បើទោះបីជាការធ្វើបែបនេះមិនសមស្របតាមស្តង់ដាររដ្ឋ ដែលគ្របដណ្តប់លើការអប់រំដែលផ្តល់ជូនដោយស្រុករដ្ឋបាលក៏ដោយ។

## កម្រិតនៃការសងប្រាក់

ចំនួននៃការសងប្រាក់ដូចមានរៀបរាប់ក្នុងកថាខ័ណ្ឌខាងលើ អាចត្រូវបានកាត់បន្ថយ ឬបដិសេធ ៖

1. ប្រសិនបើ ៖ (ក) នៅក្នុងកិច្ចប្រជុំ IEP ចុងក្រោយដែលអ្នកបានចូលរួមមុនពេលអ្នកឈប់អោយកូនអ្នកទៅរៀននៅសាលាសាររដ្ឋ អ្នកមិនបានប្រាប់ក្រុមការងារ IEP ថាអ្នកបានច្រានចោលការរកកន្លែងសិក្សាជូនកូនអ្នកដែលត្រូវបានស្នើឡើងដោយស្រុករដ្ឋបាលដើម្បីផ្តល់ FAPE ដល់កូនអ្នក រួមមាន ការថ្លែងប្រាប់ពីក្តីបារម្ភរបស់អ្នក និងគោលបំណងរបស់អ្នកក្នុងការចុះឈ្មោះអោយកូនអ្នកចូលរៀន ក្នុងសាលាឯកជន ក្រោមបន្ទុកចំណាយរបស់រដ្ឋ ឬ (ខ) យ៉ាងហោចណាស់រយៈពេល១០ថ្ងៃនៃថ្ងៃធ្វើការ (រាប់បញ្ចូលទាំងថ្ងៃឈប់សម្រាកចំថ្ងៃធ្វើការ) មុនពេលអ្នកឈប់អោយកូនអ្នកទៅរៀននៅសាលារដ្ឋ អ្នកមិនបានផ្តល់ការជូនដំណឹងអំពីព័ត៌មាននោះជាលាយលក្ខណ៍អក្សរដល់ស្រុករដ្ឋបាល។
2. ប្រសិនបើមុនពេលអ្នកឈប់អោយកូនអ្នកទៅរៀននៅសាលារដ្ឋ ស្រុករដ្ឋបាលបានផ្តល់ជូនដំណឹងជាលាយលក្ខណ៍អក្សរដល់អ្នក អំពីគោលបំណងធ្វើការវាយតម្លៃកូនរបស់អ្នក (រួមមានការថ្លែងអំពីគោលបំណងនៃការវាយតម្លៃដែលមានលក្ខណៈសមស្រប និងសមហេតុផល) ប៉ុន្តែអ្នកមិនបានបញ្ជូន កូនអ្នកអោយគេវាយតម្លៃ **ឬ**
3. នៅពេលដែលតុលាការរកឃើញថាសកម្មភាពរបស់អ្នកមិនសមហេតុផល។

ក៏ប៉ុន្តែ ចំនួននៃការសងប្រាក់ ៖

1. មិនអាចកាត់បន្ថយ ឬបដិសេធដាច់ខាត ដោយសារការខកខានមិនបានផ្តល់ការជូនដំណឹង ប្រសិនបើ ៖ (ក) សាលាបានរាំងស្ទះមិនអោយអ្នកផ្តល់ការជូនដំណឹង (ខ) អ្នកមិនបានទទួលការជូនដំណឹងអំពី ការទទួលខុសត្រូវរបស់អ្នកក្នុងការផ្តល់ការជូនដំណឹងដូចមានរៀបរាប់ខាងលើ ឬ (គ) អនុលោមភាព ជាមួយនឹងលក្ខខណ្ឌតម្រូវខាងលើ អាចនឹងបណ្តាលអោយមានគ្រោះថ្នាក់ដល់រាងកាយកូនអ្នក **និង**
2. មិនអាចត្រូវបានកាត់បន្ថយ ឬបដិសេធ តាមឆន្ទានុសិទ្ធិនៃតុលាការ ALJ ដោយសារការខកខានរបស់អ្នកក្នុងការផ្តល់ការជូនដំណឹងតាមការតម្រូវ ប្រសិនបើ ៖ (ក) អ្នកមិនចេះអក្សរ ឬមិនអាចសរសេរភាសាអង់គ្លេស ឬ (ខ) អនុលោមភាពជាមួយនឹងលក្ខខណ្ឌតម្រូវខាងលើ អាចបណ្តាលអោយមានផលប៉ះពាល់ផ្លូវចិត្តធ្ងន់ធ្ងរដល់កូនអ្នក។

# ប្រភពជំនួយ

ប្រសិនបើលោកអ្នកមានសំណួរអំពីនីតិវិធីទទួលបានកិច្ចការពារ សូមអញ្ជើញទាក់ទងស្រុករដ្ឋបាលសាលា ឬ **OSPI** សម្រាប់ព័ត៌មានបន្ថែម

**OSPI**
**P.O Box 47200**
**Olympia, Washington 98504**
**(360)725-6075**
**speced@k12.wa.us**
**http://www.k12.wa.us/SpecialEd/default.aspx**
**http://www.k12.wa.us/SpecialEd/Families/Assistance.aspx**

អង្គការទទួលមូលនិធិពីសាធារណៈជនទាំងនេះ អាចផ្តល់ព័ត៌មានបន្ថែមអំពីសេវាអប់រំពិសេសនៅរដ្ឋវ៉ាស៊ីងតោន (Washington State)៖

- Partnerships for Action Voices for Empowerment (PAVE)
  6316 So. 12th St.
  Tacoma, WA 98465
  (800) 5-PARENT (v/tty)
  អ៊ីម៉ែល: pave@wapave.org
  វែបសាយ: http://www.wapave.org/

- The Office of the Education Ombuds
  155 N.E. 100th St. #210
  Seattle, WA 98125
  (866) 297-2597
  អ៊ីម៉ែល: OEOinfo@gov.wa.gov
  វែបសាយ: http://www.governor.wa.gov/oeo/